ខែវិច្ឆិកា ឆ្នាំ២០២៣

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# ស្ថានភាពនៃសេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាននៅកម្ពុជា

របាយការណ៍ប្រចាំឆ្នាំ៖ ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២២ ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៣




ស្កេនដើម្បីអាន

## អំពីមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") គឺជាអង្គការមិនមែនរដ្ឋាភិបាល មិនចូលបក្សសម្ព័ន្ធ និងឯករាជ្យ ("អង្គការ") ដែលធ្វើការដើម្បីលើកកម្ពស់និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា("កម្ពុជា")។ ចក្ខុវិស័យរបស់ ម.ស.ម.ក គឺចង់ឃើញប្រទេសកម្ពុជាមានសន្តិភាព ដែលពលរដ្ឋគ្រប់រូបអាចអនុវត្តសិទ្ធិមនុស្សមូលដ្ឋានដែលខ្លួនមានពីកំណើត ទទួលបាននីតិរដ្ឋដោយគ្មាននិទណ្ឌភាព ទទួលបានការគោរពស្មើភាពគ្នាដោយគ្មានការរើសអើង ទទួលបានការពង្រឹងភាពអង់អាចក្លាហានដើម្បីចូលរួមយ៉ាងពេញលេញក្នុងដំណើរការលទ្ធិប្រជាធិបតេយ្យ ព្រមទាំងទទួលបានចំណែកនៃអត្ថប្រយោជន៍ពីការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយនិរន្តរភាពរបស់ប្រទេសកម្ពុជា។ ស្លាកសញ្ញារបស់ ម.ស.ម.ក មានរូបសត្វស្លាបពណ៌ស ហើរចេញពីរង្វង់មូលផ្ទៃពណ៌ផ្ទៃមេឃដែលមានន័យថា គឺការទាមទារសេរីភាពនៅកម្ពុជា។ សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់ www.cchrcambodia.org ។

## អំពីរបាយការណ៍

របាយការណ៍នេះគឺជាលទ្ធផលរួមគ្នានៃ *គម្រោងបង្កើនការគោរពសិទ្ធិនៅកម្ពុជា* និង *គម្រោងគាំទ្រប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងសេរីភាពមូលដ្ឋាននៅកម្ពុជា ដំណាក់កាលទី២*។ គម្រោងបង្កើនការគោរពសិទ្ធិនៅកម្ពុជា ត្រូវបានចាប់ផ្តើមអនុវត្តនៅខែកញ្ញា ឆ្នាំ២០២០ ក្នុងគោលបំណងពង្រឹង ក៏ដូចជាលើកកម្ពស់សិទ្ធិទទួលព័ត៌មាន និងសេរីភាពសារព័ត៌មាននៅកម្ពុជា។ គម្រោងគាំទ្រប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងសេរីភាពមូលដ្ឋាននៅកម្ពុជា ដំណាក់កាលទី២ ចាប់ផ្តើមអនុវត្តសកម្មភាពរបស់ខ្លួននៅខែមករា ឆ្នាំ២០២៣ ក្នុងគោលបំណងពង្រីកលំហសិទ្ធិពលរដ្ឋដើម្បីលើកកម្ពស់ និងការពារសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាននៅក្នុងប្រទេសកម្ពុជា។

នេះជារបាយការណ៍ប្រចាំឆ្នាំលើកទីបី ដែលគម្រោងបង្កើនការគោរពសិទ្ធិនៅកម្ពុជា និងគម្រោងគាំទ្រប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងសេរីភាពមូលដ្ឋាននៅកម្ពុជាបានផលិតឡើង។ របាយការណ៍ប្រចាំឆ្នាំលើកទីមួយ និងលើកទីពីរ ត្រូវបានចេញផ្សាយក្នុងខែមេសា និងខែវិច្ឆិកា ឆ្នាំ២០២២ ដែលអាចរកបាននៅលើគេហទំព័ររបស់ ម.ស.ម.ក។

## ចម្ងល់ និងមតិចូលរួម

ប្រសិនបើអ្នកមានសំណួរ ឬចង់ផ្តល់មតិចូលរួមទៅលើរបាយការណ៍នេះ សូមផ្ញើអ៊ីម៉ែលមកកាន់ ម.ស.ម.ក តាមរយៈ info@cchrcambodia.org ។ របាយការណ៍នេះ ក៏ដូចជាឯកសារបោះពុម្ពផ្សាយផ្សេងៗទៀតរបស់ ម.ស.ម.ក អាចស្វែងរកបាននៅលើគេហទំព័ររបស់ ម.ស.ម.ក. www.cchrcambodia.org ឬនៅលើគេហទំព័រសិទ្ធិមនុស្សកម្ពុជា www.sithi.org របស់ ម.ស.ម.ក ដែលទទួលបានពានរង្វាន់។

ព័ត៌មានបន្ថែម សូមទាក់ទងមកកាន់ ម.ស.ម.ក តាមរយៈអាសយដ្ឋាន៖ ផ្ទះលេខ ៧៩៨ ផ្លូវ ៩៩ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរសព្ទ៖ +៨៥៥ (០) ២៣ ៧២ ៦៩ ០១ ។

# មាតិកា


មាតិកា i

បញ្ជីអក្សរកាត់ និងពាក្យបំព្រួញ ii

វិសាលភាព និងវិធីសាស្ត្រស្រាវជ្រាវ ១

ខ្លឹមសារសង្ខេប ៣

សេចក្តីផ្តើម ៥

I. សារៈសំខាន់នៃសេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាន ៧

II. ក្របខណ្ឌច្បាប់ស្តីពីសេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាន ១០

២.១. ច្បាប់អន្តរជាតិទាក់ទងនឹងសេរីភាពខាងការបញ្ចេញមតិ ១០

២.២. ច្បាប់កម្ពុជាទាក់ទងនឹងសេរីភាពខាងការបញ្ចេញមតិ ១២

III. ការវិភាគផ្នែកច្បាប់ទៅលើបញ្ញត្តិច្បាប់ចុងក្រោយ ១៦

IV. ស្ថានភាពនៃសេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាននៅកម្ពុជា ២០

៤.១. ស្ថានភាពនៃសេរីភាពសារព័ត៌មាន ២១

៤.២. ស្ថានភាពនៃសេរីភាពខាងការបញ្ចេញមតិរបស់អ្នកការពារសិទ្ធិមនុស្ស ៣៩

៤.៣. ស្ថានភាពនៃការទទួលព័ត៌មាន ៥០

V. សេចក្តីសន្និដ្ឋាន និងអនុសាសន៍ ៥៩

VI. ឧបសម្ព័ន្ធ ៦២

# បញ្ជីអក្សរកាត់ និងពាក្យបំព្រួញ

| | |
|---|---|
| **កម្ពុជា** | ព្រះរាជាណាចក្រកម្ពុជា |
| **រដ្ឋធម្មនុញ្ញ** | រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា |
| **ម.ស.ម.ក** | មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា |
| **គ.ក.ស.ក** | គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា |
| **ក.អ.ស.ព.ន** | កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ |
| **ក.ប.ទ** | ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |
| **ការិយាល័យឧត្តមស្នងការ** | ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស |
| **រដ្ឋាភិបាល** | រាជរដ្ឋាភិបាលកម្ពុជា |
| **និយ័តករ** | និយ័តករទូរគមនាគមន៍កម្ពុជា |
| **ស.ស.ស.ម** | សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស |
| **អ.ស.ប** | អង្គការសហប្រជាជាតិ |
| **យូណេស្កូ** | អង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌របស់អង្គការសហប្រជាជាតិ |
| **គ.ស.ម.អ.ស.ប** | គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ |
| **វីអូអេ** | វិទ្យុសំឡេងសហរដ្ឋអាមេរិក |
| **វីអូឌី** | វិទ្យុសំឡេងប្រជាធិបតេយ្យ |

# វិសាលភាព និងវិធីសាស្ត្រស្រាវជ្រាវ

## វិសាលភាព

របាយការណ៍នេះបង្ហាញពីព័ត៌មានសំខាន់ៗពាក់ព័ន្ធនឹងសិទ្ធិសេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន សិទ្ធិទទួលព័ត៌មាន និងរបកគំហើញទាក់ទងនឹងស្ថានភាពនៃសិទ្ធិទាំងនេះនៅក្នុងព្រះរាជាណាចក្រកម្ពុជា («កម្ពុជា») ក្នុងរយៈពេលមួយឆ្នាំចាប់ពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២២ ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៣ («អំឡុងពេលនៃរបាយការណ៍»)។ របាយការណ៍ប្រចាំឆ្នាំនេះ ផ្តោតជាពិសេសទៅលើសិទ្ធិសេរីភាពខាងការបញ្ចេញមតិរបស់អ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្ស ក៏ដូចជាសិទ្ធិទទួលព័ត៌មានរបស់អ្នកសារព័ត៌មាន និងសាធារណជននៅកម្ពុជា។

## វិធីសាស្ត្រស្រាវជ្រាវ

ព័ត៌មានដែលមាននៅក្នុងរបាយការណ៍នេះត្រូវបានចងក្រង ដោយប្រើប្រាស់ទិន្នន័យកត់ត្រាជាលក្ខណៈប្រព័ន្ធដែលបានមកពីប្រភពជាច្រើនផ្សេងគ្នា។ ដើម្បីធ្វើរបាយការណ៍អំពីស្ថានភាពបច្ចុប្បន្នភាពនៃសិទ្ធិសេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាន ការសិក្សាស្រាវជ្រាវលើទិន្នន័យដែលមានស្រាប់ត្រូវបានធ្វើឡើងដើម្បីបង្ហាញពីក្របខណ្ឌច្បាប់អន្តរជាតិ និងច្បាប់ជាតិ ដែលពាក់ព័ន្ធនឹងសិទ្ធិទាំងនេះ។ ការពិនិត្យមើល និងការវិភាគទៅលើច្បាប់ស្តីពីវិសោធនកម្មច្បាប់បោះឆ្នោត និងអនុក្រឹត្យស្តីពី ការចុះបញ្ជីអត្តសញ្ញាណឧបករណ៍ទូរគមនាគមន៍ប្រើស៊ីម ដើម្បីវាយតម្លៃពីភាពស្របគ្នាជាមួយបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។

ទិន្នន័យដែលបានប្រើក្នុងរបាយការណ៍នេះ ត្រូវបានប្រមូលតាមរយៈការតាមដានប្រព័ន្ធផ្សព្វផ្សាយប្រចាំថ្ងៃ និងការរាយការណ៍អំពីហេតុការណ៍ របស់គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាននៃ ម.ស.ម.ក។ ទិន្នន័យទាំងនេះ ត្រូវបានបំពេញបន្ថែមជាមួយគ្នានឹងទិន្នន័យដែលគម្រោងបង្កើនការគោរពសិទ្ធិនិងគម្រោងគាំទ្រប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងសេរីភាពមូលដ្ឋានបានកត់ត្រានៅពេលចាំបាច់។ របាយការណ៍នេះក៏បានបញ្ចូលផងដែរនូវករណីសិក្សាសំខាន់ៗ ស្តីពីការរំលោភលើសេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាន ដែលព័ត៌មានទាំងនេះត្រូវបានប្រមូលតាមរយៈអ៊ីនធឺណិត។

បន្ថែមពីនេះ ក៏មានការសម្ភាសន៍ជាមួយអ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្ស ដើម្បីប្រមូលនូវទស្សនៈយល់ឃើញរបស់ពួកគេលើស្ថានភាពបច្ចុប្បន្ននៃសេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាន ព្រមទាំងបទពិសោធន៍ និងបញ្ហាប្រឈមក្នុងការអនុវត្តសិទ្ធិទាំងនេះ នៅពេលដែលអនុវត្តភារកិច្ចការពាររបស់ខ្លួន។ សម្រាប់របាយការណ៍នេះ បុគ្គលិក ម.ស.ម.ក បានសម្ភាសអ្នកសារព័ត៌មានចំនួន ០៨ នាក់ ក្នុងនោះមានស្ត្រី០២ នាក់ ព្រមទាំងអ្នកការពារសិទ្ធិមនុស្ស ១០ នាក់ ក្នុងនោះមានស្ត្រីអ្នកការពារសិទ្ធិមនុស្ស០៦នាក់នៅក្នុងខែកក្កដា និងខែសីហា ឆ្នាំ២០២៣។ ការសម្ភាស ត្រូវបានធ្វើឡើងទាំងដោយជួបសម្ភាសន៍ផ្ទាល់ និងតាមប្រព័ន្ធអនឡាញ។ ឈ្មោះរបស់អ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្ស និងឈ្មោះស្ថាប័នត្រូវបានរក្សាជាការសម្ងាត់។ ទោះយ៉ាងណា សក្ខីកម្ម ដែលជាទស្សនៈ និងបទពិសោធន៍របស់ពួកគេដែលបានចែករំលែក ជាគុណតម្លៃជាជាងការបង្ហាញអត្តសញ្ញាណ។

ម.ស.ម.ក ក៏បានសម្ភាសន៍អ្នកសារព័ត៌មាន ១០ នាក់ (ក្នុងនោះមានស្ត្រីប្រាំនាក់) និងអ្នកការពារសិទ្ធិមនុស្សប្រាំនាក់ (ក្នុងនោះស្ត្រីមួយនាក់) នៅចន្លោះខែវិច្ឆិកា ឆ្នាំ២០២២ ដល់ខែមីនា ឆ្នាំ២០២៣ ដើម្បីចងក្រងជីវប្រវត្តិរបស់ពួកគេដាក់តាំងបង្ហាញក្នុងទិវាសេរីភាពសារព័ត៌មានពិភពលោក ឆ្នាំ២០២៣។ ព័ត៌មានដែលពួកគេបានផ្ដល់ ក៏ត្រូវបានយកមកដាក់បញ្ចូលនៅក្នុងរបាយការណ៍នេះផងដែរ។

## ដែនកំណត់

សូមបញ្ជាក់ផងដែរថា មិនមែនទិន្នន័យ និងករណីទាំងអស់សុទ្ធតែត្រូវបានប្រមូល និងចងក្រងនោះទេ ពីព្រោះថាមានការរំលោភបំពានលើសេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន ឬសិទ្ធិទទួលព័ត៌មានខ្លះអាចមិនត្រូវបានរាយការណ៍។

# ខ្លឹមសារសង្ខេប

សិទ្ធិសេរីភាពខាងការបញ្ចេញមតិគឺជាសិទ្ធិដែលរួមបញ្ចូលទាំងសិទ្ធិសេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាន។ សិទ្ធិទាំងបីនេះគឺជាប់ទាក់ទងគ្នានិងអាស្រ័យគ្នាទៅវិញទៅមក។ សិទ្ធិទាំងនេះគឺជាមូលដ្ឋានគ្រឹះនៃសង្គមមួយប្រកបដោយសមធម៌ និងសេរី ដែលលទ្ធិប្រជាធិបតេយ្យអាចលូតលាស់ និងរីកចម្រើន។

សេរីភាពខាងការបញ្ចេញមតិ ដែលភ្ជាប់មកជាមួយសេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មានត្រូវបានការពារដោយច្បាប់អន្តរជាតិ និងច្បាប់ជាតិកម្ពុជា។ ទោះយ៉ាងណា ច្បាប់នៅកម្ពុជាបានកំណត់ឧបសគ្គជាច្រើនដល់ការអនុវត្តឱ្យបានពេញលេញចំពោះសេរីភាពខាងការបញ្ចេញមតិនៅកម្ពុជា។ ការវិវត្តផ្នែកនីតិបញ្ញត្តិតែងបង្កផលប៉ះពាល់ដល់សេរីភាពខាងការបញ្ចេញមតិ ដោយសារតែការវិវត្តនេះមិនស្របតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។ អំឡុងពេលនៃរបាយការណ៍នេះ រាជរដ្ឋាភិបាលកម្ពុជា («រដ្ឋាភិបាល») បានអនុម័តច្បាប់ស្ដីពីវិសោធនកម្មច្បាប់បោះឆ្នោត ដែលរឹតត្បិតបន្ថែមទៀតលើសេរីភាពបញ្ចេញមតិ ផ្ទុយពីកាតព្វកិច្ចអន្តរជាតិរបស់ប្រទេសកម្ពុជា។ ដូចគ្នានេះដែរ ខណៈដែលច្បាប់ការពារសិទ្ធិទទួលព័ត៌មានត្រូវបានលើកទឹកចិត្ត សេចក្ដីព្រាងច្បាប់ស្ដីពីសិទ្ធិទទួលព័ត៌មានរបស់រដ្ឋាភិបាល មិនបានអនុលោមទៅតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិទាំងស្រុងនៅឡើយ ហើយអាចនឹងទទួលបានអត្ថប្រយោជន៍ពីវិសោធនកម្មដែលធ្វើឱ្យច្បាប់នេះកាន់តែប្រសើរឡើងស្របតាមបទដ្ឋានអន្តរជាតិ[1]។ លើសពីនេះ រដ្ឋាភិបាលនៅតែបន្តពន្យារពេលក្នុងការអនុម័តច្បាប់នេះ បើទោះបីជាមានការអំពាវនាវពីសំណាក់សង្គមស៊ីវិលឱ្យអនុម័តច្បាប់នេះឱ្យបានឆាប់ក៏ដោយ។

ច្បាប់ដែលមានលក្ខណៈរឹតត្បិត គឺគ្រាន់តែជាឧបករណ៍មួយក្នុងចំណោមឧបករណ៍ជាច្រើនទៀតដែលរដ្ឋាភិបាលបាននឹងកំពុងប្រើប្រាស់ ដើម្បីបង្ក្រាបលើសេរីភាពខាងការបញ្ចេញមតិក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ។ ការបំភិតបំភ័យ ការឃ្លាំមើល ការគំរាមកំហែង ឬការយាយីតាមប្រព័ន្ធតុលាការក៏ត្រូវបានប្រើប្រាស់ជាប្រចាំផងដែរ ដើម្បីកំណត់មុខសញ្ញាអ្នកដែលហ៊ានបញ្ចេញមតិ ជាមួយគ្នានោះ អ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្ស គឺជាគោលដៅចម្បងរបស់រដ្ឋាភិបាលជំទាស់នឹងសំឡេងរិះគន់។ សិទ្ធិសេរីភាពខាងការបញ្ចេញមតិរបស់អ្នកការពារសិទ្ធិមនុស្ស និងសេរីភាពសារព័ត៌មាន បានបន្តរងការប៉ះពាល់នៅចន្លោះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២២ ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៣ ដោយមានអ្នកសារព័ត៌មានយ៉ាងហោចណាស់ ១៦ នាក់ និងអ្នកការពារសិទ្ធិមនុស្ស ១០០ នាក់ បានទទួលរងនូវផលប៉ះពាល់ពីការបន្តតាមសង្កត់ និងរងគ្រោះដោយសារតែគោលការណ៍មិនអត់ឱនចំពោះការរិះគន់ពីសំណាក់រដ្ឋាភិបាល។ ស្រដៀងគ្នានេះដែរ កម្ពុជានៅមានកិច្ចការជាច្រើនដែលត្រូវបំពេញ មុនពេលដែលសិទ្ធិទទួលព័ត៌មានត្រូវបានប្រកាន់ខ្ជាប់យ៉ាងពេញលេញ។

របាយការណ៍នេះបង្ហាញអំពីស្ថានភាពនៃសេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មានក្នុងអំឡុងពេលនេះ។ របាយការណ៍ផ្ទុកនូវទិន្នន័យសំខាន់ៗស្តីពីស្ថានភាពសេរីភាពខាងការ

[1] សម្រាប់សេចក្ដីវិភាគពេញលេញលើសេចក្ដីព្រាងច្បាប់ស្ដីពីសិទ្ធិទទួលព័ត៌មាន សូមមើលរបាយការណ៍ប្រចាំឆ្នាំរបស់ ម.ស.ម.ក ស្ដីពីៈ ស្ថានភាពនៃសេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាននៅកម្ពុជា, ថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ២០២០ ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២១, (ម.ស.ម.ក, ខែមេសា ឆ្នាំ២០២២)។

បញ្ចេញមតិ ដែលបានប្រមូលក្នុងអំឡុងពេលនៃរបាយការណ៍នេះ បានបង្ហាញនូវករណីជាច្រើននៃការយាយីខាងផ្លូវច្បាប់លើអ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្ស ការលុបចោលនូវអាជ្ញាបណ្ណផ្សព្វផ្សាយមួយចំនួន និងបញ្ហាប្រឈមផ្សេងៗទៀតនៃសិទ្ធិទទួលព័ត៌មាននៅក្នុងប្រទេសកម្ពុជា។ របាយការណ៍នេះក៏មានសក្ខីកម្មរបស់អ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្សដែលបង្ហាញពីបញ្ហាប្រឈមដែលបានជួបប្រទះក្នុងពេលអនុវត្តការងារស្របច្បាប់ នៅក្នុងបរិយាកាសដែលកាន់តែមានសភាពគ្រោះថ្នាក់។

នៅក្នុងបរិបទនេះ របាយការណ៍នេះក៏ផ្ដល់នូវអនុសាសន៍មួយចំនួនដល់រដ្ឋាភិបាល ដើម្បីចាត់វិធានការជាក់ស្ដែង ក្នុងការបំពេញកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិរបស់ខ្លួនក្នុងការការពារ និងលើកកម្ពស់សេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាននៅកម្ពុជា។

# សេចក្តីផ្តើម

សិទ្ធិសេរីភាពខាងការបញ្ចេញមតិ គឺជាសសរស្តម្ភដ៏សំខាន់នៃលទ្ធិប្រជាធិបតេយ្យ។[2] យ៉ាងណាក៏ដោយ សិទ្ធិនេះត្រូវរងការវាយប្រហារនៅទូទាំងសកលលោកក្នុងរយៈពេល ១៧ ឆ្នាំចុងក្រោយនេះ។ ទិន្នន័យរបស់អង្គការហ្វ្រីដឹមហៅស៍ បង្ហាញថាសេរីភាពបញ្ចេញមតិ ទាំងប្រព័ន្ធផ្សព្វផ្សាយ និងបុគ្គល បានធ្លាក់ចុះជាងសិទ្ធិសេរីភាពផ្សេងទៀតរបស់ពលរដ្ឋក្នុងរយៈពេលចុងក្រោយ ហើយការរំលោភបំពានលើសេរីភាពបញ្ចេញមតិគឺជាកត្តាចម្បងមួយនៃការធ្លាក់ចុះលទ្ធិប្រជាធិបតេយ្យទូទាំងសកលលោក។[3]

ការធ្លាក់ចុះផ្នែកសេរីភាពខាងការបញ្ចេញមតិនៅកម្ពុជាមិនមែនជារឿងចម្លែកនោះទេ។ ប្រទេសនេះបន្តនិន្នាការគួរឱ្យព្រួយបារម្ភនូវគោលនយោបាយចំពោះសេរីភាពបញ្ចេញមតិ និងការបំបិទសំឡេងរិះគន់ ដែលជាការគាបសង្កត់កាន់តែខ្លាំងឡើងមុនការបោះឆ្នោតសកលក្នុងខែកក្កដា ឆ្នាំ២០២៣។ ចាប់តាំងពីឆ្នាំ២០១៧ មកស្ថានភាពសិទ្ធិមនុស្សបានបន្តធ្លាក់ចុះ ហើយសិទ្ធិពលរដ្ឋកាន់តែរួមតូច ជាមួយនឹងការដៅមុខសញ្ញារបស់រដ្ឋាភិបាលចំពោះអ្នកដែលហ៊ានបញ្ចេញទស្សនៈ និងគំនិតផ្ទុយពីថ្នាក់ដឹកនាំកម្ពុជា រួមទាំងប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងអ្នកការពារសិទ្ធិមនុស្ស។ របាយការណ៍ដែលគម្រោងឃ្លាំមើលសេរីភាពមូលដ្ឋានរបស់ ម.ស.ម.ក ទើបចេញផ្សាយថ្មីៗនេះបង្ហាញថាសេរីភាពខាងការបញ្ចេញមតិនៅក្នុងប្រទេសកម្ពុជាតែងតែរងនូវការរារាំង ដោយអ្នកសារព័ត៌មានរងការរំខានជាញឹកញាប់ នៅពេលរាយការណ៍អំពីបញ្ហាដែលមានលក្ខណៈ "រសើប" ដូចជាបញ្ហាដីធ្លី ឬរងបណ្តឹងដោយសារការអនុវត្តសេរីភាពបញ្ចេញមតិរបស់ខ្លួន។[4] លើសពីនេះ សិទ្ធិទទួលព័ត៌មាននៅកម្ពុជាមិនទាន់ត្រូវបានប្រកាន់ខ្ជាប់ពេញលេញនៅឡើយ។ ការទទួលព័ត៌មានពីស្ថាប័នសាធារណៈនៅតែជាឧបសគ្គក្នុងប្រទេសមួយដែលមានភាពស្រពិចស្រពិលក្នុងការគ្រប់គ្រង និងគណនេយ្យភាពតិចតួចរបស់ស្ថាប័នរដ្ឋាភិបាល។ ជាលទ្ធផល ប្រទេសកម្ពុជាបានជាប់ចំណាត់ថ្នាក់លេខ ១៤៧ ក្នុងចំណោម ១៨០ ប្រទេសដែលអង្គការអ្នកសារព័ត៌មានគ្មានព្រំដែនបានធ្វើការវាយតម្លៃ នៅក្នុងសន្ទស្សន៍សេរីភាពសារព័ត៌មានពិភពលោកឆ្នាំ២០២៣។[5] ស្រដៀងគ្នានេះដែរ របាយការណ៍ស្តីពីសេរីភាពពិភពលោកឆ្នាំ២០២២ របស់អង្គការហ្វ្រីដឹម

---

[2] សូមមើលគណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ, "ការយល់ឃើញលើករណីរ៉ាហ្វាអែល ម៉ាក្វែអើស (Rafael Marques) ជាមួយនឹងអង់ហ្គូឡា (Angola)"។ (ឯកសារអង្គការសហប្រជាជាតិ, CCPR/C/83/D/ 1128/2002, ២៩ មិនា ២០០៥) កថាខណ្ឌទី ៦.៨។

[3] អង្គការហ្វ្រីដឹមហៅស៍, "សេរីភាពនៅក្នុងពិភពលោកឆ្នាំ២០២៣៖ រំលឹកខួប ៥០ ឆ្នាំក្នុងការតស៊ូដើម្បីលទ្ធិប្រជាធិបតេយ្យ"។ ហ្វ្រីដឹមហៅហ៍, ២០២៣។

[4] ម.ស.ម.ក, "ការឃ្លាំមើលសេរីភាពមូលដ្ឋានកម្ពុជា៖ របាយការណ៍ប្រចាំឆ្នាំ២០២២"។ (ម.ស.ម.ក, កញ្ញា ២០២៣), ទំព័រទី២៥-២៦។

[5] សន្ទស្សន៍សេរីភាពសារព័ត៌មានពិភពលោករបស់អង្គការអ្នកសារព័ត៌មានគ្មានព្រំដែន (RSF) វាយតម្លៃលើស្ថានភាពសម្រាប់អ្នកសារព័ត៌មានជារៀងរាល់ឆ្នាំនៅក្នុងប្រទេស និងដែនដីជាងមួយរយ ដោយផ្តល់ពិន្ទុ និងចាត់ថ្នាក់ប្រទេស និងដែនដីទាំងនោះផ្សេងៗគ្នា ទៅតាមពិន្ទុក្នុងចំណោមពិន្ទុ ១០០។ សន្ទស្សន៍សេរីភាពសារព័ត៌មានពិភពលោកឆ្នាំ ២០២៣ ចាត់ថ្នាក់ស្ថានភាពសេរីភាពសារព័ត៌មានរបស់ប្រទេសដែលបានវាយតម្លៃជាប្រាំប្រភេទ៖ ល្អ ពេញចិត្ត មានបញ្ហា ពិបាក និងធ្ងន់ធ្ងរ។ សូមមើលសន្ទស្សន៍សេរីភាពសារព័ត៌មានពិភពលោកឆ្នាំ ២០២៣ សម្រាប់ព័ត៌មានលម្អិតអំពីប្រទេសកម្ពុជា។

ហៅស៍[6] បានចាត់ថ្នាក់ប្រទេសកម្ពុជាថា «មិនសេរី» ដោយបានពិន្ទុសេរីភាពជាសកល ២៤ ក្នុងចំណោម ១០០ ហើយក្នុងរបាយការណ៍ស្តីពីសេរីភាពតាមប្រព័ន្ធអ៊ីនធឺណិតឆ្នាំ២០២៣ របស់ខ្លួន[7] បានចាត់ថ្នាក់កម្ពុជាថាជាប្រទេសមាន "សេរីភាពខ្លះ" ដោយបានពិន្ទុសេរីតាមអនឡាញ ៤៤ លើ ១០០។ ជាចុងក្រោយ សន្ទស្សន៍ប្រជាធិបតេយ្យឆ្នាំ២០២២ របស់អង្គភាពស៊ើបការណ៍សេដ្ឋកិច្ច បានដាក់ចំណាត់ថ្នាក់ប្រទេសកម្ពុជានៅលេខរៀង ១២១ នៃ ១៦៧ ប្រទេសដែលត្រូវបានវាយតម្លៃ ដោយចាត់ថ្នាក់ថាជា"ប្រទេសផ្តាច់ការ"។[8] សន្ទស្សន៍ប្រជាធិបតេយ្យឆ្នាំ២០២២ ក៏បានគូសបញ្ជាក់ផងដែរអំពីការធ្លាក់ចុះនៃប្រជាធិបតេយ្យនៅកម្ពុជានៅចន្លោះឆ្នាំ២០០៦ ដល់ ឆ្នាំ ២០២២[9] ដែលឈានទៅដល់ការធ្លាក់ចេញពីរបបកូនកាត់ទៅជារបបផ្តាច់ការក្នុងទសវត្សរ៍ចុងក្រោយនេះ។



| សេរីភាពនៅលើពិភពលោក ឆ្នាំ ២០២២ | សេរីភាពនៅលើបណ្តាញ ឆ្នាំ ២០២២ | សេរីភាពសារព័ត៌មាននៅលើពិភពលោកឆ្នាំ ២០២២ | សន្ទស្សន៍ប្រជាធិបតេយ្យឆ្នាំ ២០២១ |
| --- | --- | --- | --- |
| *ពិន្ទុសេរីភាពជាសកលៈ* | *ពិន្ទុសេរីភាពតាមអ៊ីនធឺណិតៈ* | *ពិន្ទុសេរីភាពសារព័ត៌មានៈ* | *ពិន្ទុប្រជាធិបតេយ្យៈ* |
| ២៤/១០០ | ៤៣/១០០ | ៤៣.៤៨/១០០ | ២.៩០/១០ |
| មិនសេរី | សេរីដោយផ្នែក | ស្ថានភាពពិបាក | របបផ្តាច់ការ |

[6] របាយការណ៍ស្តីពីសេរីភាពពិភពលោកចេញផ្សាយរបស់ហ្វ្រីដឹមហៅវ៍ វាយតម្លៃលើសេរីភាពសកលនៃបណ្តាប្រទេស និងដែនដីជុំវិញពិភពលោក ដោយផ្តល់ពិន្ទុ និងចាត់ថ្នាក់ប្រទេស និងដែនដីទាំងនោះជាបីថ្នាក់ផ្សេងៗគ្នា ទៅតាមពិន្ទុក្នុងចំណោមពិន្ទុ ១០០ ដូចជាៈ ប្រទេសសេរី សេរីខ្លះ ឬប្រទេសមិនសេរី។ សម្រាប់ព័ត៌មានលម្អិត សូមមើលរបាយការណ៍ស្តីពីសេរីភាពឆ្នាំ២០២៣ របស់កម្ពុជានៅក្នុងរបាយការណ៍ប្រទេសក្នុងពិភពលោក។

[7] សេរីភាពនៅលើរបាយការណ៍សរុប គឺជាការអង្កេតប្រចាំឆ្នាំ និងការវិភាគអំពីសេរីភាពជុំវិញពិភពលោកតាមប្រព័ន្ធអ៊ីនធឺណិត ធ្វើឡើងដោយអង្គការហ្វ្រីដឹមហៅវ៍។ ប្រទេសដែលត្រូវបានវាយតម្លៃ ត្រូវបានផ្តល់ក្នុងចំណោមពិន្ទុ ១០០ ហើយចាត់ថ្នាក់ជាបីប្រភេទទៅតាមពិន្ទុៈ សេរី សេរីខ្លះ ឬមិនសេរី។ សម្រាប់ព័ត៌មានលម្អិត សូមមើលរបាយការណ៍ប្រចាំប្រទេសរបស់កម្ពុជាឆ្នាំ ២០២៣ ស្តីពីៈ សេរីភាពនៅលើពិភពលោក។

[8] សន្ទស្សន៍ប្រជាធិបតេយ្យចេញផ្សាយដោយអង្គភាពស៊ើបការណ៍សេដ្ឋកិច្ច (EIU) វាយតម្លៃលើស្ថានភាពប្រជាធិបតេយ្យនៅទូទាំងពិភពលោក។ សន្ទស្សន៍នេះផ្តល់ឱ្យប្រទេសដែលបានវាយតម្លៃនូវមាត្រដ្ឋានពិន្ទុពីសូន្យដល់ដប់ ហើយចាត់ថ្នាក់ជាបួនប្រភេទទៅតាមពិន្ទុៈ ប្រជាធិបតេយ្យពេញលេញ លទ្ធិប្រជាធិបតេយ្យចន្លោះប្រហោង របបកូនកាត់ និងរបបផ្តាច់ការ។ សូមមើលសន្ទស្សន៍ប្រជាធិបតេយ្យរបស់អង្គភាពស៊ើបការណ៍សេដ្ឋកិច្ចឆ្នាំ២០២២, ទំព័រទី១០។

[9] ដូចខាងលើ, ទំព័រទី១៦។

# I. សារៈសំខាន់នៃសេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាន



សិទ្ធិសេរីភាពខាងការបញ្ចេញមតិ គឺជាចង្កោមនៃសិទ្ធិមួយដែលរួមបញ្ចូលទាំងសេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាន។ សិទ្ធិទាំងបីនេះគឺជាប់ពាក់ព័ន្ធ និងអាស្រ័យគ្នាទៅវិញទៅមក មានន័យថាគ្មានសិទ្ធិណាអាចសម្រេចបាននោះទេក្នុងករណីអវត្តមានសិទ្ធិណាមួយនោះ។ ដើម្បីបង្កើតពិភពលោកមួយកាន់តែមានសមធម៌ និងសេរី ការដែលបុគ្គលម្នាក់ៗមានលទ្ធភាពក្នុងការបង្ហាញនូវគំនិត ចែករំលែក និងទទួលព័ត៌មាន គឺមានសារៈសំខាន់ណាស់។ នៅពេលដែលសង្គមមួយមានការចូលរួម លទ្ធិប្រជាធិបតេយ្យនឹងលូតលាស់ ហើយបទដ្ឋានសង្គម និងមនោគមវិជ្ជាដែលបង្កគ្រោះថ្នាក់នឹងថមថយ។ បច្ចេកវិទ្យាឌីជីថលបានពន្លឿនអត្រាបុគ្គលទទួល និងប្រើប្រាស់ព័ត៌មាន ព្រមទាំងបញ្ចេញនូវទស្សនៈរបស់ខ្លួន និងការទទួលស្គាល់នូវសិទ្ធិទាំងនេះកាន់តែសំខាន់ថែមទៀត។ ទោះយ៉ាងណា បច្ចេកវិទ្យាទាំងនេះក៏បានផ្តល់ឱកាសដ៏ច្រើនដល់រដ្ឋាភិបាលក្នុងការគាបសង្កត់ ដើម្បីកាត់បន្ថយសិទ្ធិទាំងនេះគ្មានកំណត់។

## សេរីភាពខាងការបញ្ចេញមតិ

សេរីភាពខាងការបញ្ចេញមតិគ្របដណ្តប់គ្រប់ទម្រង់នៃការបញ្ចេញមតិ រួមទាំងការបញ្ចេញមតិដោយការនិយាយ សំណេរ និងមធ្យោបាយផ្សេងទៀត ដូចជាសៀវភៅ ការបង្ហោះមាតិកា បដា សោតទស្សន៍ អេឡិចត្រូនិក និងទម្រង់នៃការបញ្ចេញមតិដែលមានមូលដ្ឋានលើអ៊ីនធឺណិតជាដើម។ សេរីភាពនេះក៏រួមបញ្ចូលផងដែរនូវសិទ្ធិរបស់បុគ្គលក្នុងការចូលរួមការពិភាក្សានានា រួមទាំងនយោបាយ សិទ្ធិមនុស្ស ឬសារព័ត៌មាន។[10] សេរីភាពខាងការបញ្ចេញមតិ គឺជាសសរស្តម្ភស្នូលនៃលទ្ធិប្រជាធិបតេយ្យដែលដំណើរការត្រឹមត្រូវ ប្រកបដោយ

[10] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ, "សេចក្តីអធិប្បាយទូទៅលេខ ៣៤ មាត្រា ១៩៖ សេរីភាពខាងមានមតិ និងសម្តែងមតិ"។ (CCPR/C/GC/៣៤, ១២ កញ្ញា ២០១១), កថាខណ្ឌទី ២, (គ.ស.ម.អ.ស.ប្រ, សេចក្តីអធិប្បាយទូទៅលេខ ៣៤)។

បរិយាប័ន្ន និងពហុនិយម ដែលអនុញ្ញាតឱ្យបុគ្គលសម្តែងនូវមតិរបស់ខ្លួនចំពោះបញ្ហាសាធារណៈសំខាន់ៗ ព្រមទាំងអាចបដិសេធជាមួយអ្នកកាន់អំណាច និងបង្ហាញអំពើពុករលួយ ឬការប្រព្រឹត្តខុស ហើយក៏ធ្វើឱ្យមានតម្លាភាពទាំងក្នុងវិស័យសាធារណៈ និងឯកជន។ នៅពេលដែលសេរីភាពខាងការបញ្ចេញមតិមិនត្រូវបានធានា ប្រជាពលរដ្ឋមិនអាចតបតនឹងរចនាសម្ព័ន្ធអំណាចរបស់រដ្ឋាភិបាល ឬស្ថាប័នសាជីវកម្មបានទេ។ សេរីភាពខាងការបញ្ចេញមតិគឺជាមូលដ្ឋានគ្រឹះសម្រាប់ការពារសិទ្ធិមនុស្សផ្សេងទៀតផងដែរ[11] ដូចជាសិទ្ធិសេរីភាពខាងគំនិតមនសិការ និងសាសនា សេរីភាពខាងការជួបប្រជុំ និងសេរីភាពខាងសមាគម។

## សេរីភាពសារព័ត៌មាន

សារព័ត៌មានដែលសេរី អនុញ្ញាតឱ្យមានការផ្សព្វផ្សាយចំណេះដឹង ទស្សនៈ និងគំនិតនានាដែលចាំបាច់សម្រាប់បុគ្គលគ្រប់រូបដើម្បីអភិវឌ្ឍទស្សនៈ ការទទួលព័ត៌មានអំពីបញ្ហាផលប្រយោជន៍សាធារណៈ និងការសម្រេចចិត្តរបស់រដ្ឋាភិបាល និងការអនុវត្តសិទ្ធិរបស់ពួកគេ។[12] កត្តាសំខាន់ គឺការធានាដល់សេរីភាពខាងការបញ្ចេញមតិ និងការលូតលាស់ទៅនៃលទ្ធិប្រជាធិបតេយ្យ។ ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងចម្រុះពឹងផ្អែកលើជំនាញរបស់អ្នកសារព័ត៌មានក្នុងការស្រាវជ្រាវ ការសរសេរ និងស៊ើបអង្កេត ដែលអនុញ្ញាតឱ្យពួកគេស្វែងរកការពិត និងផ្សព្វផ្សាយព័ត៌មានសំខាន់ៗដល់សាធារណជន។ សកម្មភាពទាំងនេះធានាថាព័ត៌មានដែលពលរដ្ឋបានទទួលគឺអាចទុកចិត្តបាន ឯករាជ្យ និងមិនលម្អៀងដោយកត្តាផលប្រយោជន៍ណាផ្សេងឡើយ។ សារព័ត៌មានសេរីមានន័យថា គ្មានប្រធានបទណាមួយត្រូវបានកម្រិតដោយសារខ្លាចការព្យាបាទ ហើយអាចផ្តល់ឱ្យប្រជាពលរដ្ឋនូវចំណេះដឹងលើបញ្ហាសង្គម នយោបាយ និងសេដ្ឋកិច្ចដែលពាក់ព័ន្ធ ហើយអនុញ្ញាតឱ្យសង្គមបញ្ចេញទស្សនៈលើបញ្ហាទាំងនេះ និងធ្វើការតស៊ូមតិដើម្បីការផ្លាស់ប្តូរដោយមិនភ័យខ្លាចពីការតបត។

ជាងនេះទៅទៀត សារព័ត៌មានដើរតួនាទីយ៉ាងសំខាន់ក្នុងនាមជាអ្នកឃ្លាំមើលរដ្ឋាភិបាល ធានានូវតម្លាភាព និងគណនេយ្យភាព ព្រមទាំងបង្ហាញពីការរំលោភបំពាន និងកំហុសឆ្គងរបស់រដ្ឋាភិបាល។[13] បើគ្មានសេរីភាពសារព័ត៌មានទេ លទ្ធភាពក្នុងការត្រួតពិនិត្យលើសកម្មភាពរបស់រដ្ឋាភិបាលអាចនឹងមានតិចតួច ឬគ្មានសោះតែម្តង ដែលអាចនាំឱ្យមានការរីករាលដាលនៃអំពើពុករលួយ ភាពអយុត្តិធម៌ និងភាពជ្រុលហួសរបស់រដ្ឋាភិបាលក្នុងការជ្រៀតជ្រែកទៅលើការរស់នៅរបស់ពលរដ្ឋ។ ដូចនេះ ប្រព័ន្ធផ្សព្វផ្សាយត្រូវមានលទ្ធភាពផ្សព្វផ្សាយព័ត៌មាន និងផ្តល់មតិទៅលើព័ត៌មាន ឬគំនិតដោយសេរី គ្មានការដាក់កំហិត ឬការរារាំង។

---

[11] ដូចខាងលើ, កថាខណ្ឌទី ១១ និង ១២។

[12] ក្រសួងការបរទេសន័រវេស, "កិច្ចខិតខំប្រឹងប្រែងអន្តរជាតិដើម្បីលើកកម្ពស់សេរីភាពខាងការបញ្ចេញមតិ និងប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ"។ (ក្រសួងការបរទេស, ៣០ វិច្ឆិកា ២០២០)។

[13] អង្គការសហប្រជាជាតិ, "សេរីភាពសារព័ត៌មានមានសារៈសំខាន់ជាងពេលណាៗទាំងអស់ខណៈដែលអង្គការសហប្រជាជាតិថ្កោលទោសឃាតកម្មបុគ្គលិកប្រព័ន្ធផ្សព្វផ្សាយចំនួន ៥៩ នាក់"។ (សារព័ត៌មានអង្គការសហប្រជាជាតិ, ២៣ ធ្នូ ២០២០)។

## សិទ្ធិទទួលព័ត៌មាន

ប្រជាពលរដ្ឋមានសិទ្ធិស្វែងរក និងទទួលព័ត៌មានសាធារណៈ។[14] សិទ្ធិទទួលព័ត៌មានក៏ធានាថា ប្រព័ន្ធផ្សព្វផ្សាយមានសិទ្ធិទទួលព័ត៌មានចំពោះកិច្ចការសាធារណៈ ឬមានសារៈសំខាន់ជាសាធារណៈ។[15] សិទ្ធិទទួលព័ត៌មានធានានូវតម្លាភាពនៃស្ថាប័នរដ្ឋាភិបាល សម្របសម្រួលការចូលរួមរបស់ប្រជាពលរដ្ឋក្នុងកិច្ចការសាធារណៈ និងបង្កើនកិច្ចសន្ទនា និងការជឿទុកចិត្តរវាងរដ្ឋាភិបាល និងសង្គម។[16] ប្រសិនបើសិទ្ធិនេះត្រូវបានកំហិត តម្លាភាព និងគណនេយ្យភាពរបស់រដ្ឋាភិបាល ឬមន្ត្រីសាធារណៈគឺមិនមាននោះទេ ហើយការចូលរួមយ៉ាងសកម្មរបស់ប្រជាពលរដ្ឋក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្តក៏ត្រូវបានរារាំង។ លទ្ធិប្រជាធិបតេយ្យត្រូវបាន ចាក់ឫសនៅក្នុងលំហូរនៃសេរីភាពព័ត៌មាន និងគំនិត ដូច្នេះសិទ្ធិទទួលព័ត៌មានជាអ្វីដែលញែករដ្ឋាភិបាលបែបប្រជាធិបតេយ្យពីរបបដែលស្វែងរកប្រតិបត្តិការដោយគ្មានតម្លាភាព និងធ្វើសកម្មភាពរបស់ខ្លួនជាមួយនឹងភាពលាក់បាំង។

[14] ហ្វ្រេង ឡា រុយ (Frank La Rue), "របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីការលើកកម្ពស់ និងការពារសិទ្ធិសេរីភាពខាងមានមតិ និងសម្តែងមតិ"។ (UN Doc A/68/362, ៤ កញ្ញា ២០១៣), កថាខណ្ឌទី២។

[15] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ, សេចក្តីអធិប្បាយទូទៅលេខ ៣៤ កថាខណ្ឌទី១៨។

[16] អេនឌ្រូ អេចក្លេស្ទោន (Andrew Ecclestone), "សំណើយុទ្ធសាស្ត្រដើម្បីសេរីភាពព័ត៌មាននៅកម្ពុជា"។ (កញ្ញា ២០០៨)។

## II. ក្របខណ្ឌច្បាប់ស្ដីពីសេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាន

លិខិតូបករណ៍អន្តរជាតិជាច្រើនដែលកម្ពុជាបានផ្ដល់សច្ចាប័ន ធានានូវសិទ្ធិសេរីភាពខាងការបញ្ចេញមតិ និងជាតុផ្សំសំខាន់ពីរនៃសិទ្ធិនេះ។ ខណៈដែលសេរីភាពខាងការបញ្ចេញមតិគឺជាគន្លឹះមួយនៃសង្គមសេរី និងប្រជាធិបតេយ្យក៏ដោយ[17] ក៏សិទ្ធិនេះមិនមានលក្ខណៈដាច់ខាតនោះទេ ហើយអាចត្រូវបានដាក់កម្រិតក្នុងកាលៈទេសៈចង្អៀតមួយចំនួនដែលកំណត់នៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ។

### ២.១. ច្បាប់អន្តរជាតិទាក់ទងនឹងសេរីភាពខាងការបញ្ចេញមតិ

| ច្បាប់អន្តរជាតិការពារសេរីភាពខាងការបញ្ចេញមតិ[18] | ច្បាប់រឹតត្បិតចំពោះសេរីភាពខាងការបញ្ចេញមតិ |
|---|---|
| មាត្រា ១៩ (២) នៃសេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស («ស.ស.ស.ម»)៖ មនុស្សគ្រប់រូបមានសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ រាប់បញ្ចូលទាំងសិទ្ធិស្វែងរក ទទួល និងផ្សព្វផ្សាយព័ត៌មាន និងគំនិតនានាគ្រប់ទីកន្លែងទោះតាមរយៈមធ្យោបាយសម្ដែងមតិណាមួយក៏ដោយ។<br><br>*«បុគ្គលគ្រប់រូបមានសិទ្ធិសេរីភាពខាងការមានមតិ និងការសម្ដែងមតិ។ សិទ្ធិនេះរាប់បញ្ចូលទាំងសេរីភាពក្នុងការប្រកាន់មតិដោយគ្មានការជ្រៀតជ្រែក និងសេរីភាពក្នុងការស្វែងរក ការទទួល និងការផ្សព្វផ្សាយព័ត៌មាន និងគំនិតនានាដោយគ្មានព្រំដែនទោះតាមរយៈមធ្យោបាយសម្ដែងមតិណាមួយក៏ដោយ»។* | មាត្រា ១៩ (៣) នៃ កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ អនុញ្ញាតឱ្យមានការរឹតត្បិតលើសេរីភាពខាងការបញ្ចេញមតិ ប្រសិនបើលក្ខខណ្ឌបន្ថែមចំនួនបីត្រូវបានបំពេញ។<br><br>*«ការអនុវត្តចែងក្នុងកថាខណ្ឌទី ២ [សិទ្ធិសេរីភាពខាងការបញ្ចេញមតិ និងសិទ្ធិទទួលព័ត៌មាន] តម្រូវឱ្យមានករណីយកិច្ច និងការទទួលខុសត្រូវពិសេស។ ដូច្នេះការប្រើប្រាស់សិទ្ធិនេះអាចមានការរឹតត្បិតមួយចំនួន ដែលត្រូវកំណត់ដាច់ខាតដោយច្បាប់ និងដែលចាំបាច់ដើម្បី៖ (ក) គោរពសិទ្ធិ ឬកិត្តិសព្ទរបស់ អ្នកដទៃ (ខ) ការពារសន្តិសុខជាតិ សណ្ដាប់ធ្នាប់ សាធារណៈសុខភាព ឬសីលធម៌សាធារណៈ។»*<br><br>ដូច្នេះរាល់ការរឹតត្បិតណាមួយលើសេរីភាពខាងការបញ្ចេញមតិ ត្រូវតែ៖[19] |

[17]គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ, សេចក្ដីអធិប្បាយទូទៅលេខ ៣៤ កថាខណ្ឌទី១។

[18] បញ្ជីច្បាប់ដែលបានផ្ដល់ក្នុងតារាងគឺមិនគ្របដណ្ដប់ទាំងស្រុងទេ។

[19] សូមមើលសេចក្ដីអធិប្បាយទូទៅលេខ ៣៤ របស់គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ។ សូមមើលផងដែរនូវរបាយការណ៍ស្ដីពី៖ស្ថានភាពនៃសេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាននៅកម្ពុជា ប្រចាំឆ្នាំ ២០២០-២០២១ របស់ ម.ស.ម.ក,ទំព័រ ១២-១៤។

មាត្រា ១៩ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ («ក.អ.ស.ព.ន»)៖ ជានាបុគ្គលគ្រប់រូបមានសិទ្ធិសេរីភាពខាងការមានមតិ និងសម្តែងមតិ រួមទាំងសិទ្ធិក្នុងការស្វែងរក ការទទួល និងការផ្សព្វផ្សាយព័ត៌មាន និងគំនិតនានាគ្រប់ទីកន្លែង និងគ្រប់ទម្រង់។

*«ជនគ្រប់រូបមានសិទ្ធិសេរីភាពខាងការបញ្ចេញមតិ។ សិទ្ធិនេះរួមមានសេរីភាពខាងការស្វែងរក ការទទួល និងការផ្សព្វផ្សាយព័ត៌មាន និងគំនិតនានាដោយគ្មានព្រំដែន ទាំងការនិយាយ ការសរសេរ ឬការបោះពុម្ពផ្សាយ ក្នុងទម្រង់សិល្បៈ ឬតាមរយៈមធ្យោបាយសម្តែងមតិផ្សេងៗតាមជម្រើសរបស់ខ្លួន»។*

- ដោយសិទ្ធិសេរីភាពខាងការបញ្ចេញមតិ មានវិសាលភាពទូលំទូលាយ គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ដែលពិនិត្យមើលការអនុវត្ត ក.អ.ស.ព.ន បានពន្យល់លម្អិតបន្ថែមទៅលើអ្វីដែលសិទ្ធិនេះមានចែង នៅក្នុង **សេចក្តីអធិប្បាយទូទៅលេខ ៣៤ របស់ខ្លួន។**[20]

១. **បញ្ញត្តិដោយច្បាប់៖** ច្បាប់ត្រូវតែមានភាពជាក់លាក់ និងច្បាស់លាស់គ្រប់គ្រាន់ នៅពេលកំណត់ថាតើប្រភេទនៃការបញ្ចេញមតិបែបណាត្រូវដាក់កម្រិត មិនត្រូវផ្តល់ការសម្រេចចិត្តដោយមិនត្រឹមត្រូវដល់អាជ្ញាធរមានសមត្ថកិច្ច និងផ្តល់ការណែនាំគ្រប់គ្រាន់ដល់អាជ្ញាធរដើម្បីឱ្យពួកគេកំណត់ដឹងថា តើការបញ្ចេញមតិប្រភេទណាត្រូវបានកម្រិត ឬអត់។ ដូច្នេះការហាមប្រាមជាទូទៅត្រូវបានហាមឃាត់។

២. **ត្រូវតែមានគោលបំណងស្របច្បាប់ក្នុងការធានានូវការគោរពសិទ្ធិ ឬកិត្តិសព្ទរបស់អ្នកដទៃ ឬការការពារសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ សុខភាព ឬសីលធម៌សាធារណៈ៖** វិធានការហាមឃាត់ការជ្រៀតជ្រែកនូវឯកជនភាពរបស់ប្រជាពលរដ្ឋ ឬការវាយប្រហារលើកេរ្តិ៍ឈ្មោះដោយខុសច្បាប់ ដូចជាច្បាប់បរិហារកេរ្តិ៍ ត្រូវបានអនុញ្ញាត ប្រសិនបើលក្ខខណ្ឌពីរផ្សេងទៀតត្រូវបានបំពេញ។ ទោះជាយ៉ាងណា វិធានការបែបនេះមិនត្រូវគាបសង្កត់សេរីភាពខាងការបញ្ចេញមតិឡើយ។ ការបរិហារកេរ្តិ៍មិនគួរដាក់ទោសទណ្ឌឡើយ ហើយច្បាប់ដែលហាមឃាត់ការបរិហារកេរ្តិ៍ ការប្រមាថ និងការគំរាមកំហែងចំពោះរាជាធិបតេយ្យ (ការប្រមាថចំពោះអង្គព្រះមហាក្សត្រ) ត្រូវតែលុបចោល។ ការហាមឃាត់ចំពោះការឃោសនាណាមួយសម្រាប់សង្គ្រាម ឬការញុះញង់ឱ្យមានការស្អប់ខ្ពើមជាតិសាសន៍ ពូជសាសន៍ ឬសាសនាត្រូវស្របជាមួយនឹងច្បាប់អន្តរជាតិ។

[20] សម្រាប់ព័ត៌មានលម្អិត សូមមើលសេចក្តីអធិប្បាយទូទៅលេខ ៣៤ របស់គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ។ សូមមើលផងដែរ "ស្ថានភាពនៃសេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាននៅកម្ពុជារបស់ ម.ស.ម.ក របាយការណ៍ប្រចាំឆ្នាំចាប់ពីថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២០ ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២១"។ (ម.ស.ម.ក, ខែមេសា ឆ្នាំ២០២២), ទំព័រ ១២-១៥។

| | |
|---|---|
| លិខិតូបករណ៍អន្តរជាតិផ្សេងទៀតដូចជា៖<br>• មាត្រា ៥ (viii) នៃអនុសញ្ញាអន្តរជាតិស្ដីពីការលុបបំបាត់គ្រប់ទម្រង់នៃការរើសអើងពូជសាសន៍។<br>• មាត្រា ២១ នៃអនុសញ្ញាស្ដីពីសិទ្ធិជនពិការ<br>• មាត្រា ១៣ នៃអនុសញ្ញាស្ដីពីសិទ្ធិកុមារ<br>• មាត្រា ១៦ នៃសេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិជនជាតិដើមភាគតិច។ | ៣. មានភាពចាំបាច់ដាច់ខាត និងសមាមាត្រទៅនឹងគោលបំណងស្របច្បាប់ ដែលត្រូវសម្រេច៖ រដ្ឋត្រូវតែបង្ហាញឱ្យបានគ្រប់គ្រាន់ថា ការរឹតត្បិតលើសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន គឺជាការចាំបាច់ដើម្បីដាក់គោលដៅជាក់លាក់លើការគំរាមកំហែង ដោយបង្កើតទំនាក់ទំនងដោយផ្ទាល់ និងភ្លាមៗរវាងការបញ្ចេញមតិ និងការគំរាមកំហែង។ លើសពីនេះ ការរឹតត្បិតមិនអាចលើសពីអ្វីដែលចាំបាច់ ដើម្បីសម្រេចបាននូវគោលបំណងស្របច្បាប់នោះទេ។ ការរឹតត្បិតហួសហេតុ ឬការហាមឃាត់ជាទូទៅលើការផ្សព្វផ្សាយព័ត៌មាន ផ្អែកលើគំនិតមិនច្បាស់លាស់ និងមិនត្រឹមត្រូវ រួមទាំង "ព័ត៌មានមិនពិត" ឬ "ព័ត៌មានលម្អៀង" គឺមិនស្របនឹងច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ |

## ២.២. ច្បាប់កម្ពុជាទាក់ទងនឹងសេរីភាពខាងការបញ្ចេញមតិ

សេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាន ក៏ត្រូវបានធានានៅក្នុងច្បាប់ជាតិកម្ពុជាផងដែរ។

**ច្បាប់ជាតិកម្ពុជាការពារសេរីភាពខាងការបញ្ចេញមតិ**

រដ្ឋធម្មនុញ្ញកម្ពុជា[21]

- មាត្រា ៤១៖ ធានាចំពោះប្រជាពលរដ្ឋខ្មែរគ្រប់រូប នូវសិទ្ធិសេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងខាងការបោះពុម្ពផ្សាយ។

*ប្រជាពលរដ្ឋខ្មែរមានសិទ្ធិសេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ និងសេរីភាពខាងការជួបប្រជុំ [...]"* ។

- មាត្រា ៣៥៖ ធានាចំពោះប្រជាពលរដ្ឋខ្មែរទាំងពីរភេទ នូវសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រទេសជាតិ។
- មាត្រា ៣១៖ អនុញ្ញាតឱ្យលិខិតូបករណ៍សិទ្ធិមនុស្សអន្តរជាតិដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័នអាចអនុវត្តដោយផ្ទាល់នៅក្នុងច្បាប់ជាតិរបស់កម្ពុជា។

[21] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

នៅឆ្នាំ២០០៧ ក្រុមប្រឹក្សាធម្មនុញ្ញកម្ពុជាបានបញ្ជាក់ថា បទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ដែលកម្ពុជាបានទទួលស្គាល់ អាចអនុវត្តដោយផ្ទាល់នៅក្នុងតុលាការកម្ពុជា។[22]

ច្បាប់ស្តីពីរបបសារព័ត៌មានឆ្នាំ ១៩៩៥[23]

- មាត្រា ១៖ ធានាសេរីភាពសារព័ត៌មាន និងសេរីភាពនៃការបោះពុម្ពផ្សាយ ស្របតាមមាត្រា ៣១ និង មាត្រា ៤១ នៃរដ្ឋធម្មនុញ្ញកម្ពុជា។
- មាត្រា ៣៖ ហាមឃាត់ការត្រួតពិនិត្យមុនពេលបោះពុម្ព។
- មាត្រា ៥៖ ធានាសិទ្ធិសម្រាប់សារព័ត៌មានក្នុងការទទួលព័ត៌មានដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាល។
- មាត្រា ២០៖ មិនទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះការបញ្ចេញមតិ។

ទោះយ៉ាងណា ក្របខណ្ឌច្បាប់កម្ពុជាក៏មានបញ្ញត្តិជាច្រើនរារាំងចំពោះសិទ្ធិទាំងនេះ ដោយច្បាប់ដែលមានលក្ខណៈរឹតត្បិតកាន់តែខ្លាំងឡើង ត្រូវបានរដ្ឋាភិបាលអនុម័តក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ។ បញ្ជីច្បាប់ដែលបានរៀបរាប់ខាងក្រោមនេះ មិនគ្របដណ្តប់ទាំងស្រុងនៅឡើយទេ គឺគ្រាន់តែគូសបញ្ជាក់ពីច្បាប់ទាំងឡាយដែលអាចប៉ះពាល់ដល់សេរីភាពខាងការបញ្ចេញមតិដែលប្រព័ន្ធផ្សព្វផ្សាយនិងអ្នកការពារសិទ្ធិមនុស្សអនុវត្ត។

**ច្បាប់កម្ពុជាដែលដាក់កំហិតដោយខុសច្បាប់លើសេរីភាពខាងការបញ្ចេញមតិ**

ច្បាប់ស្តីពីរបបសារព័ត៌មានឆ្នាំ ១៩៩៥[24]

- ហាមឃាត់ការបោះពុម្ពផ្សាយស្របច្បាប់ជាច្រើន និងប្រើប្រាស់ពាក្យដែលមិនច្បាស់លាស់ ដែលនេះអាចនាំឱ្យមានការបកស្រាយយ៉ាងទូលំទូលាយ និងការចាប់ពិរុទ្ធដោយខុសច្បាប់លើប្រព័ន្ធផ្សព្វផ្សាយ។
- ផ្តល់ឱ្យរាជរដ្ឋាភិបាលកម្ពុជានូវសិទ្ធិក្នុងការរឹបអូសភ្លាមៗ និងផ្អាកការបោះពុម្ពផ្សាយជាបណ្តោះអាសន្ន ដោយគ្មានការត្រួតពិនិត្យតាមប្រព័ន្ធតុលាការ ឬគ្មានបណ្តឹងតវ៉ា ធ្វើឱ្យច្បាប់នេះក្លាយជាឧបករណ៍ដ៏មានសក្តានុពលរបស់អាជ្ញាធរក្នុងគោលដៅនយោបាយរារាំងប្រព័ន្ធផ្សព្វផ្សាយ។
- បង្កើតនីតិវិធីផ្តល់អាជ្ញាបណ្ណសម្រាប់សារព័ត៌មានដែលគ្រប់គ្រងទាំងស្រុងដោយរាជរដ្ឋាភិបាលកម្ពុជា ហើយដែលផ្តល់ឱ្យក្រសួងព័ត៌មាន នូវអំណាចគ្មានដែនកំណត់ក្នុងការផ្តល់ និងដកហូតអាជ្ញាបណ្ណផ្សព្វផ្សាយ ដោយគ្មានយន្តការត្រួតពិនិត្យឯករាជ្យណាមួយឡើយ។

---

[22] សេចក្តីសម្រេចលេខ ០៩២/០០៣/២០០៧ របស់ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ១០ កក្កដា ២០០៧) ទំព័រ ២៖ "ពាក្យ "ច្បាប់" ដូចយោងខាងលើមានន័យថាច្បាប់ជាតិ រួមទាំងរដ្ឋធម្មនុញ្ញ ដែលជាច្បាប់កំពូល ច្បាប់ទាំងអស់ដែលនៅជាធរមាន និងច្បាប់អន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាបានទទួលស្គាល់រួចជាស្រេច"។

[23] ច្បាប់ស្តីពីរបបសារព័ត៌មាន។ នៅឆ្នាំ២០១៩ ក្រសួងព័ត៌មានបានប្រកាសថាបានចាប់ផ្តើមពិនិត្យច្បាប់ស្តីពីរបបសារព័ត៌មានដើម្បីឱ្យមាត្រាមួយចំនួន "ស្របតាមស្ថានភាពបច្ចុប្បន្ន និងតម្រូវការរបស់ប្រទេស"។ ច្បាប់នេះនៅតែស្ថិតក្រោមការកែសម្រួលរហូតមកដល់ពេលនេះ។ សូមមើល វ៉ូន ដារ៉ា "រដ្ឋាភិបាលធ្វើវិសោធនកម្មច្បាប់ស្តីពីរបបសារព័ត៌មាន ដើម្បីឱ្យស្របតាមការពិតបច្ចុប្បន្នពិតប្រាកដ"; (ភ្នំពេញប៉ុស្តិ៍, ០៦ ឧសភា ២០១៩) និង"ការពិនិត្យមើលច្បាប់ស្តីពីរបបសារព័ត៌មានចាប់ផ្តើម"។(ភ្នំពេញប៉ុស្តិ៍, ២៧ សីហា ២០១៩)។

[24] សម្រាប់ការវិភាគលម្អិតបន្ថែមទៀតលើច្បាប់សារព័ត៌មាន សូមមើល, "កំណត់ចំណាំសង្ខេបស្តីពីបទប្បញ្ញត្តិប្រព័ន្ធផ្សព្វផ្សាយ និងសេរីភាពខាងការបញ្ចេញមតិនៅកម្ពុជា" របស់ ម.ស.ម.ក។ (ម.ស.ម.ក, កុម្ភៈ ២០១៤)។

- ផ្តល់បញ្ជីមិនពេញលេញនៃករណីលើកលែងចំពោះសិទ្ធិទទួលព័ត៌មានដែលមាននៅក្នុងកំណត់ត្រាក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាលដោយមិនមានយន្តការបណ្តឹងសម្រាប់ការស្នើសុំព័ត៌មានដែលត្រូវបានបដិសេធដោយរដ្ឋាភិបាល។

ច្បាប់ស្តីពីទូរគមនាគមន៍ឆ្នាំ ២០១៥ និងប្រកាសស្តីពីការគ្រប់គ្រងការផ្សព្វផ្សាយតាមគេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គមឆ្នាំ២០១៨[25]

- ច្បាប់ស្តីពីទូរគមនាគមន៍ បានរៀបចំឱ្យមានការឃ្លាំមើលការបញ្ចេញមតិតាមប្រព័ន្ធអនឡាញ បង្កើតជាបទល្មើសព្រហ្មទណ្ឌជាបន្តបន្ទាប់ទាក់ទងនឹងការប្រើប្រាស់ឧបករណ៍ទូរគមនាគមន៍ និងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ និងការផាកពិន័យជាប្រាក់យ៉ាងធ្ងន់ធ្ងរ ដែលបណ្តាលឱ្យមានផលប៉ះពាល់យ៉ាងខ្លាំងដល់ការបញ្ចេញមតិតាមរយៈបណ្តាញទូរគមនាគមន៍។[26]
- ប្រកាសចុះឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រង ការផ្សព្វផ្សាយតាមគេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គមបានពង្រីកយ៉ាងទូលំទូលាយនូវអំណាចលើសលប់ដល់រដ្ឋាភិបាលដើម្បីតាមដានទំនាក់ទំនងទូរគមនាគមន៍ រួមទាំងការប្រើប្រាស់អ៊ីនធឺណិត។ អ្វីដែលគួរឱ្យកត់សម្គាល់គឺថាប្រកាសនេះផ្តល់សិទ្ធិអំណាចដល់ស្ថាប័ននីតិប្រតិបត្តិ ក្នុងការគ្រប់គ្រងព័ត៌មានដែលផ្សព្វផ្សាយនៅលើអ៊ីនធឺណិត និងបិទទំព័រប្រព័ន្ធផ្សព្វផ្សាយសង្គម ឬគេហទំព័រ ដែលនេះធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សេរីភាពខាងការបញ្ចេញមតិតាមប្រព័ន្ធអនឡាញ។

ក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៩[27]

- បទប្រមាថចំពោះអង្គព្រះមហាក្សត្រ ដែលត្រូវបានដាក់បញ្ចូលក្នុងក្រមព្រហ្មទណ្ឌនៅឆ្នាំ ២០១៨ (មាត្រា ៤៣៧-ស្ទួន) ហាមឃាត់បុគ្គលគ្រប់រូបពីការបរិហារកេរ្តិ៍ ប្រមាថ ឬគំរាមកំហែងព្រះមហាក្សត្រ តាមគ្រប់មធ្យោបាយនៃការបញ្ចេញមតិ។[28]
- មាត្រា ៣០៥ និង ៣០៦ ដាក់ទោសចំពោះការបរិហារកេរ្តិ៍
- មាត្រា ៤៩៤ ដល់ ៤៩៧ ដែលផ្តន្ទាទោសចំពោះការញុះញង់ មាត្រា ៥០២ ដែលដាក់ទោសចំពោះការប្រមាថ ត្រូវបានប្រើជាប្រចាំដើម្បីបំបិទសំឡេងឯករាជ្យនិងរិះគន់នៅក្នុងប្រទេសកម្ពុជា។

ច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្នឆ្នាំ ២០២០[29]

[25] ច្បាប់ស្តីពីទូរគមនាគមន៍ ប្រកាសលេខ ១៧០ប្រក/អន្តរ ស្តីពីៈ "ការត្រួតពិនិត្យការចុះផ្សាយតាមគេហទំព័រ និងដំណើរការប្រព័ន្ធផ្សព្វផ្សាយសង្គមតាមរយៈអ៊ីនធឺណិតក្នុងព្រះរាជាណាចក្រកម្ពុជា"។ (២៨ ឧសភា ២០១៨)។

[26] សម្រាប់ព័ត៌មានលម្អិត សូមមើល, "ការការពារសេរីភាពមូលដ្ឋានរបស់ម.ស.ម.កៈ ការពិនិត្យមើលទិន្នន័យតាមច្បាប់ក្នុងស្រុក និងការអនុលោមតាមច្បាប់អន្តរជាតិ"។ (ម.ស.ម.ក, ធ្នូ ២០១៩), ទំព័រ ៣៧។ សូមមើលផងដែរ "ច្បាប់ស្តីពីទូរគមនាគមន៍កម្ពុជាៈ ការវិភាគផ្នែកច្បាប់" របស់អង្គការលីកាដូ។ (លីកាដូ, មីនា ២០១៦), ទំព័រ ១-២។

[27] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

[28] សម្រាប់ព័ត៌មានលម្អិត សូមមើល, "កំណត់ត្រាសង្ខេបរបស់ ម.ស.ម.កៈ ក្រមព្រហ្មទណ្ឌក្នុងបទបរិហារកេរ្តិ៍ និងសេរីភាពខាងការបញ្ចេញមតិនៅកម្ពុជា"។ (ម.ស.ម.ក, ឧសភា ២០១៤)។

[29] សម្រាប់ព័ត៌មានលម្អិត សូមមើល, "របាយការណ៍ប្រចាំឆ្នាំទីប្រាំសម្រាប់ខែមេសា ដល់ខែធ្នូ ឆ្នាំ ២០២០ ស្តីពីការឃ្លាំមើលសេរីភាពមូលដ្ឋាននៅកម្ពុជា" របស់ ម.ស.ម.ក។ (ម.ស.ម.ក), ទំព័រ ២០-២១។

- មាត្រា ៥ (១១) រឹតត្បិតសិទ្ធិទទួលព័ត៌មាន ដោយផ្តល់អំណាចដល់រដ្ឋាភិបាលក្នុងការ «ហាមឃាត់ ឬរឹតត្បិតការចែករំលែកព័ត៌មាន ឬប្រព័ន្ធផ្សព្វផ្សាយ» ដែលអាចរារាំងការរាយការណ៍ប្រកបដោយតម្លាភាព។ ច្បាប់នេះក៏បានផ្តល់អំណាចបន្ថែមដល់អាជ្ញាធរ ក្នុងការហាមឃាត់ការមានមតិ ឬសម្តែងមតិដែលអាច «ធ្វើឱ្យប្រជាពលរដ្ឋមានការភិតភ័យ ឬចលាចល ឬនាំឱ្យខូចខាតដល់សន្តិសុខជាតិ» ឬអាច «បណ្តាលឱ្យមានការភាន់ច្រឡំ» ក្នុងចំណោមសាធារណជន ដោយសារការរឹតត្បិតនេះគឺមានលក្ខណៈទូលំទូលាយពេក និងផ្ទុយនឹងមាត្រា ៤ នៃ ក.អ.ស.ព.ន។

អនុក្រឹត្យស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ («អនុក្រឹត្យស្តីពីច្រកទ្វារអ៊ីនធឺណិតជាតិ») ឆ្នាំ២០២១[30]

- អនុក្រឹត្យច្រកទ្វារអ៊ីនធឺណិតជាតិ ដែលគ្រោងនឹងដាក់ឱ្យអនុវត្តក្នុងពេលខាងមុខ នឹងតម្រូវឱ្យបណ្តាញទំនាក់ទំនង និងទិន្នន័យអ៊ីនធឺណិតណាមួយ ឬទាំងអស់ ទាំងក្នុងស្រុកនិងក្រៅស្រុក ដែលត្រូវឆ្លងកាត់ច្រកទ្វារអ៊ីនធឺណិតជាតិជាមុនសិន មុននឹងបញ្ជូនទៅកាន់អ្នកប្រើប្រាស់ចុងក្រោយ។ អនុក្រឹត្យច្រកទ្វារអ៊ីនធឺណិតជាតិ ជាពិសេសមាត្រា ៦ នៃអនុក្រឹត្យនេះគឺមិនស្របតាមលក្ខខណ្ឌទាំងបីរបស់មាត្រា ១៩ (៣) នៃ ក.អ.ស.ព.ន ហើយធ្វើឱ្យមានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះសេរីភាពខាងការបញ្ចេញមតិ និងសិទ្ធិផ្សេងទៀតនៅក្នុងប្រទេសកម្ពុជា។[31]

ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតឆ្នាំ២០២៣ («ច្បាប់បោះឆ្នោត»)

- ការធ្វើវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតឆ្នាំ២០២៣ ទៅលើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដាក់ទោសចំពោះការញុះញង់អ្នកដែលមានសិទ្ធិបោះឆ្នោតមិនឱ្យទៅបោះឆ្នោត និងណែនាំ ឬញុះញង់ឱ្យអ្នកបោះឆ្នោតបំផ្លាញ ឬធ្វើឱ្យខូចសន្លឹកឆ្នោត។ ការរឹតត្បិតទាំងនេះសំដៅដល់ការរឹតត្បិតដែលមិនអាចអនុញ្ញាតបានចំពោះសិទ្ធិមានសេរីភាពខាងការបញ្ចេញមតិតាមមាត្រា ១៩(៣) នៃ ក.អ.ស.ព.ន។

[30] អនុក្រឹត្យស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ។

[31] សម្រាប់ព័ត៌មានលម្អិត សូមមើល "របាយការណ៍ប្រចាំឆ្នាំទីប្រាំពីខែមេសា ដល់ខែធ្នូ២០២០ ស្តីពីការឃ្លាំមើលសេរីភាពមូលដ្ឋាននៅកម្ពុជា" របស់ ម.ស.ម.ក (ម.ស.ម.ក), ទំព័រ ២០–២១។ សូមមើលផងដែរនូវរបាយការណ៍ស្តីពីសេរីភាពខាងការបញ្ចេញមតិប្រចាំឆ្នាំ ២០២០-២០២១ របស់ ម.ស.ម.ក ទំព័រ ២១-២៣។

## III. ការវិភាគផ្នែកច្បាប់នៅលើការវិវត្តនីតិបញ្ញត្តិចុងក្រោយ

*បច្ចុប្បន្នភាពនៃអនុក្រឹត្យស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ*




អនុក្រឹត្យស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ ត្រូវបានអនុម័តនៅថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ២០២១។[32] អនុក្រឹត្យនេះបង្កើតនូវច្រកទ្វារអ៊ីនធឺណិតជាតិ ដែលតម្រូវឱ្យរាល់ការទំនាក់ទំនង និងទិន្នន័យអ៊ីនធឺណិតទាំងក្នុងស្រុក និងក្រៅស្រុក ត្រូវឆ្លងកាត់តាមច្រកទ្វារអ៊ីនធឺណិតជាតិជាមុនសិន មុនពេលត្រូវបានបញ្ជូនទៅអ្នកប្រើប្រាស់ចុងក្រោយ។ អង្គការសង្គមស៊ីវិលបានជំទាស់នឹងសេចក្តីស្នើអនុក្រឹត្យនេះ ព្រោះជាការគំរាមកំហែងដល់ការអនុវត្តសេរីភាពមូលដ្ឋានតាមអ៊ីនធឺណិត រួមទាំងសេរីភាពខាងការបញ្ចេញមតិផងដែរ។[33] អនុក្រឹត្យដែលគ្រោងដាក់ឱ្យអនុវត្តចាប់ពីខែកុម្ភៈ ឆ្នាំ២០២២ ត្រូវបានពន្យារពេលដោយសារ «បញ្ហាបច្ចេកទេស» នេះបើយោងតាម ក.ប.ទ។[34] គិតត្រឹមដើមខែតុលា ឆ្នាំ២០២៣ អនុក្រឹត្យនេះនៅមិនទាន់ដាក់ឱ្យអនុវត្តនៅឡើយទេ។

*អនុក្រឹត្យស្តីពីការចុះបញ្ជីអត្តសញ្ញាណឧបករណ៍ទូរគមនាគមន៍ប្រើស៊ីម គំរាមកំហែងដល់សេរីភាពមូលដ្ឋាន*

អនុក្រឹត្យស្តីពីការចុះបញ្ជីអត្តសញ្ញាណឧបរណ៍ទូរគមនាគមន៍ប្រើស៊ីម («អនុក្រឹត្យលេខ ៤១») ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២៣ មានគោលបំណងទប់ស្កាត់ និងកាត់បន្ថយការប្រើប្រាស់ឧបករណ៍ទូរគមនាគមន៍ប្រើស៊ីមក្លែងក្លាយ ឧបករណ៍ដែលជាផលចោរកម្ម និងឧបករណ៍ដែលនាំចូលខុសច្បាប់ និងដើម្បីការពារសុខភាព សុវត្ថិភាព និងសិទ្ធិអ្នកប្រើប្រាស់ ធ្វើឱ្យប្រសើរឡើងគុណភាពសេវាទូរគមនាគមន៍ ក្នុងចំណោមគោលបំណងផ្សេងៗទៀត។ យោងតាមអនុក្រឹត្យនេះ ការចុះបញ្ជីអត្តសញ្ញាណឧបករណ៍ទូរគមនាគមន៍ប្រើស៊ីមកាត ត្រូវតែធ្វើដាច់ខាត លើកលែងតែឧបករណ៍ទូរគមនាគមន៍ប្រើស៊ីមរបស់អ្នកទេសចរណ៍ ឬអ្នកដំណើរបរទេសដែលស្នាក់នៅក្នុងប្រទេសមិនលើសពីរយៈពេល៦០ថ្ងៃ។

---

[32] សម្រាប់ការវិភាគពេញលេញលើផលប៉ះពាល់នៃអនុក្រឹត្យលើសេរីភាពមូលដ្ឋាន រួមទាំងសេរីភាពខាងការបញ្ចេញមតិ សូមមើលរបាយការណ៍ប្រចាំឆ្នាំលើកទីប្រាំមួយស្តីពីការឃ្លាំមើលសេរីភាពមូលដ្ឋាននៅកម្ពុជារបស់ ម.ស.ម.ក មជ្ឈមណ្ឌលសាមគ្គីភាព និងសមាគមអាដហុក ម.ស.ម.ក, (មេសា ២០២២) ទំព័រ ១៣-១៦។

[33] ម.ស.ម.ក និងស្ថាប័នផ្សេងទៀត, "សេចក្តីថ្លែងការណ៍រួម៖ ប្រានចោលអនុក្រឹត្យស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ ដែលប៉ះពាល់ដល់សិទ្ធិមនុស្សតាមប្រព័ន្ធអ៊ីនធឺណិតនៅកម្ពុជា"។ (១៨ កុម្ភៈ ២០២១)។

[34] សេង ថៃ, "រដ្ឋាភិបាលព្យួរច្រកទ្វារអ៊ីនធឺណិតដែលមានភាពចម្រូងចម្រាសជាបណ្តោះអាសន្ន"។ (វីអូឌី, ១៥ កុម្ភៈ ២០២២)។

ជាលទ្ធផល រាល់ទូរស័ព្ទ រួមទាំងប្រភេទដែលមានលក្ខណៈស្រដៀងកុំព្យូទ័រមួយចំនួន សៀវភៅអេឡិចត្រូនិក និងឧបករណ៍អេឡិចត្រូនិកផ្សេងទៀតដែលប្រើប្រាស់ស៊ីមកាតត្រូវតែចុះបញ្ជីសម្គាល់អត្តសញ្ញាណជាអន្តរជាតិសម្រាប់ឧបករណ៍ចល័ត («លេខអាយមី») ក្នុងប្រព័ន្ធផ្ទុកទិន្នន័យរបស់រដ្ឋាភិបាល។ ក្នុងអនុក្រឹត្យក៏ចែងពីការដាក់ពិន័យរដ្ឋបាល និងពិន័យអន្តរការណ៍ដល់បុគ្គលណាដែលមិនអនុលោមតាមការកំណត់នេះ។ ទោះជាយ៉ាងណាក៏ដោយ ការចែងនេះមានភាពស្រពិចស្រពិលក្នុងការកំណត់ថាតើដំណើរការចុះបញ្ជីជាមួយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍នឹងប្រព្រឹត្តទៅបែបណា ប្រភេទទិន្នន័យដែលនឹងត្រូវបានប្រមូល រក្សាទុក និងប្រើប្រាស់ ឬរបៀបដែលរដ្ឋាភិបាលនឹងការពារឯកជនភាពរបស់អ្នកប្រើប្រាស់។

បន្ថែមលើសពីនេះ អនុក្រឹត្យនេះមិនបានបញ្ជាក់ពីរបៀបនៃដំណើរការចុះបញ្ជី ដែលនឹងនាំឱ្យសម្រេចបាននូវគោលបំណងមិនច្បាស់លាស់ដូចបានរៀបរាប់ខាងលើ។ អនុក្រឹត្យនេះក៏នាំឱ្យមានការព្រួយបារម្ភផងដែរថាអាចនឹងអនុវត្តខុសដើម្បីអនុញ្ញាតឱ្យរដ្ឋាភិបាលងាយស្រួលតាមដាន និងឃ្លាំមើលប្រជាពលរដ្ឋ ជាពិសេសអ្នកការពារសិទ្ធិមនុស្ស អ្នកសារព័ត៌មាន សកម្មជនបរិស្ថាន និងសំឡេងរិះគន់ ដោយសារតែអនុក្រឹត្យមិនបានបញ្ជាក់ពីរបៀបទុកដាក់ព័ត៌មានដែលទទួលបានពីដំណើរការចុះបញ្ជីថាជាការសម្ងាត់នោះទេ។ ដោយសារតែមិនមានក្របខ័ណ្ឌការពារទិន្នន័យ ព័ត៌មានដែលមាននៅក្នុងស៊ីមកាតអាចត្រូវបានចូលទៅប្រើប្រាស់ និងចែករំលែកទៅប្រព័ន្ធផ្ទុកទិន្នន័យ និងភាគីទីបីផ្សេងទៀតបានយ៉ាងងាយស្រួល។ នេះអាចជាការរំលោភទៅលើសិទ្ធិឯកជនភាព ដោយសារអនុក្រឹត្យនេះអាចបង្កើនសមត្ថភាពរបស់រដ្ឋាភិបាលក្នុងការបិទឧបករណ៍ តាមដាន និងឃ្លាំមើលប្រជាពលរដ្ឋ។ ជាងនេះទៅទៀត អនុក្រឹត្យនេះរំលោភទៅលើការការពារអនាមិកភាពក្នុងទូរគមនាគមន៍ធ្វើឱ្យចុះខ្សោយនូវសិទ្ធិរបស់ពលរដ្ឋកម្ពុជាក្នុងការទទួលបានប្រព័ន្ធទំនាក់ទំនងប្រកបដោយសុវត្ថិភាព ដូច្នេះនឹងនាំគ្រោះថ្នាក់ដល់សិទ្ធិសេរីភាពខាងការបញ្ចេញមតិ និងសមាគម។

### *ការធ្វើវិសោធនកម្មច្បាប់បោះឆ្នោតបន្ថែមការរឹតត្បិតដល់សិទ្ធិសេរីភាពខាងការបញ្ចេញមតិ*

នៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២៣ មួយខែមុនការបោះឆ្នោតជាតិឆ្នាំ២០២៣ រដ្ឋសភាបានអនុម័តជាឯកច្ឆ័នទៅលើការធ្វើវិសោធនកម្មទៅលើ (សំដៅដល់វិសោធនកម្មច្បាប់បោះឆ្នោត) ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ («ច្បាប់ជ្រើសតាំងតំណាងរាស្ត្រ») ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ («ច្បាប់បោះឆ្នោតឃុំ សង្កាត់») ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខ័ណ្ឌ។ ព្រឹទ្ធសភាអនុម័តនៅថ្ងៃទី២៩ ខែមិថុនា បន្ទាប់មកក្រុមប្រឹក្សាធម្មនុញ្ញបានសម្រេចនៅថ្ងៃទី០៣ ខែកក្កដា ថាច្បាប់នេះមានធម្មនុញ្ញភាព។ ច្បាប់នេះត្រូវបានព្រះមហាក្សត្រប្រកាសដាក់ឱ្យប្រើប្រាស់នៅថ្ងៃទី០៤ ខែកក្កដា។ វិសោធនកម្មទាំងនេះបានបន្ថែមបទល្មើសថ្មីចំនួនពីរនៅក្នុងច្បាប់ជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់បោះឆ្នោតឃុំ សង្កាត់ រួមមានបទញុះញង់ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតមិនឱ្យទៅបោះឆ្នោត និងណែនាំ ឬញុះញង់ឱ្យអ្នកបោះឆ្នោតបំផ្លាញ ឬធ្វើឱ្យខូចសន្លឹកឆ្នោត។ បទល្មើសថ្មីទាំងពីរនេះអាចផាកពិន័យជាប្រាក់ និងព្យួរសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតជាបណ្តោះអាសន្ន ឬអាចជាអចិន្ត្រៃយ៍ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

ការវិភាគផ្នែកច្បាប់របស់ ម.ស.ម.ក អំឡុងពេលបាយការណ៍នេះបានបង្ហាញថាវិសោធនកម្មច្បាប់នេះបាន **កម្រិតសេរីភាពខាងការបញ្ចេញមតិ** ដែលហាក់ដូចជាផ្ទុយនឹងច្បាប់ជាតិ។ ទោះបីជាមាត្រា៤១ នៃរដ្ឋធម្មនុញ្ញចែងថា ប្រជាពលរដ្ឋខ្មែរ មានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួនក៏ដោយ ក៏មាត្រានេះអនុញ្ញាតឱ្យមានការរឹតត្បិតស្របច្បាប់ទៅលើសិទ្ធិនេះដើម្បីការពារដល់ "សិទ្ធិអ្នកដទៃ" "ទំនៀមទំលាប់ល្អរបស់សង្គម" ឬ "ច្បាប់ និងសណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខជាតិ"។ នៅក្នុងការអនុវត្តជាក់ស្តែង ពាក្យពេចន៍ដែលមានលក្ខណៈទូលំទូលាយនៃបទប្បញ្ញត្តិទាំងនេះ បានអនុញ្ញាតឱ្យរដ្ឋាភិបាលអនុម័តបទប្បញ្ញត្តិច្បាប់ដែលរឹតត្បិតសិទ្ធិសេរីភាពខាងការបញ្ចេញមតិក្នុងរយៈពេលជាច្រើនឆ្នាំមកនេះ។ ទោះជាយ៉ាងនេះក្តី ក៏គួរឱ្យកត់សម្គាល់ថាក្រមព្រហ្មទណ្ឌគ្រាន់តែដាក់ទោសទណ្ឌចំពោះការញុះញង់ឱ្យមានអំពើខុសច្បាប់ ដូចជាការបោះបង់កូនចោល ការប្រព្រឹត្តបទឧក្រិដ្ឋ រារាំងមន្ត្រីរាជការសាធារណៈ ឬការរើសអើងជាដើម។ ដោយសារការធ្វើពហិការបោះឆ្នោត ឬការបង្ខូច/បំផ្លាញសន្លឹកឆ្នោតរបស់ខ្លួនឯងមិនមែនជាអំពើខុសច្បាប់ ច្បាប់ថ្មីដាក់ទោសយ៉ាងមានប្រសិទ្ធភាពដល់អំពើញុះញង់ដែលមិនអាចផ្តន្ទាទោសបាន ដែលជាវិធីសាស្ត្រហាក់ដូចជាមានវិសមភាពជាមួយនឹងហេតុផលនៅពីក្រោយការដាក់ទោសទណ្ឌចំពោះការញុះញង់។ ក្រៅពីនេះ បទប្បញ្ញត្តិថ្មីហាក់ដូចជាផ្ទុយនឹងលក្ខខណ្ឌបីដែលមាននៅក្នុងមាត្រា ១៩ (៣) នៃ ក.អ.ស.ព.ន ដើម្បីបង្ហាញពីភាពត្រឹមត្រូវនៃការរឹតត្បិតទៅលើសេរីភាពខាងការបញ្ចេញមតិ។

| លក្ខខណ្ឌបីនៃមាត្រា ១៩ នៃ ក.អ.ស.ព.ន | | |
|---|---|---|
| ដើម្បីឱ្យមានភាពស្របច្បាប់តាមបទដ្ឋានអន្តរជាតិ ការរឹតត្បិតលើសេរីភាពខាងការបញ្ចេញមតិត្រូវ៖ | | |
| **លក្ខខណ្ឌទី១.** ចែងដោយច្បាប់ (**តម្រូវការនីត្យានុកូល**) | **លក្ខខណ្ឌទី២.** អនុវត្តតាមគោលបំណងច្បាប់កំណត់ (**តម្រូវការនៃគោលបំណងស្របច្បាប់**) | **លក្ខខណ្ឌទី៣.** ចាំបាច់ក្នុងសង្គមប្រជាធិបតេយ្យ និងសមាមាត្រនឹងគោលបំណងច្បាប់ (**តម្រូវការភាពចាំបាច់ និងសមាមាត្រ**) |

**ផ្នែកទី១៖ តម្រូវការនីត្យានុកូល៖** យោងមាត្រា៨ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់បោះឆ្នោត ច្បាប់នេះបានចូលជាធរមានភ្លាមៗបន្ទាប់ពីព្រះមហាក្សត្រប្រកាសដាក់ឱ្យប្រើប្រាស់នៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២៣។ ដូច្នេះ ការរឹតត្បិតថ្មីបំពេញផ្នែកទីមួយនៃលក្ខខណ្ឌទាំងបី។

**ផ្នែកទី២៖ តម្រូវការនៃគោលបំណងស្របច្បាប់៖** មាត្រា១៩ នៃក.អ.ស.ព.ន បានចែងថាការរឹតត្បិតចំពោះសិទ្ធិសេរីភាពខាងការបញ្ចេញមតិត្រូវតែចាំបាច់ ១) គោរពសិទ្ធិ និងកិត្តិសព្ទរបស់អ្នកដទៃ និង២) ការពារសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ សុខភាព ឬសីលធម៌សាធារណៈ។ ដោយហេតុថា ច្បាប់កម្ពុជាមិនហាមឃាត់សាធារណជនទៅចូលរួមបោះឆ្នោត ឬបង្ខូច/បំផ្លាញសន្លឹកឆ្នោតរបស់ខ្លួន ការញុះញង់ឱ្យពលរដ្ឋឱ្យធ្វើបែបនោះមិនអាចចាត់ទុកថារំលោភទៅលើសិទ្ធិ ឬកិត្តិសព្ទរបស់អ្នកដទៃ ឬគំរាមកំហែងដល់សន្តិសុខជាតិ ឬសណ្តាប់ធ្នាប់សាធារណៈ សុខភាព ឬសីលធម៌សាធារណៈបានឡើយ។ បន្ថែមលើសពីនេះ នៅក្នុងសេចក្តី

ពន្យល់ទូទៅលេខ៣៤ អំពីសេរីភាពនៃគំនិត និងសម្តែងមតិ គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ បានបញ្ជាក់ថាការរឹតត្បិតលើសេរីភាពខាងការបញ្ចេញមតិ មិនត្រូវរារាំងការជជែកដេញដោលផ្នែកនយោបាយ រួមបញ្ចូលទាំង [...] ការអំពាវនាវឱ្យធ្វើពហិការមិនឱ្យទៅបោះឆ្នោតដោយបង្ខំ។ ចំណុចខាងលើបញ្ជាក់ថាការរឹតត្បិតថ្មីមិនបានបំពេញផ្នែកទី២ នៃលក្ខខណ្ឌទាំងបី។ អវត្តមាននៃគោលបំណងស្របច្បាប់នេះ ក៏មិនអាចបំពេញផ្នែកទីបីបានទេ។

បន្ថែមលើសពីនេះ បទល្មើសដែលមានចែងក្នុងច្បាប់ស្តីពីវិសោធនកម្មច្បាប់បោះឆ្នោត អាចត្រូវបានផ្តន្ទាទោសដោយការដាក់ពិន័យ ដូច្នេះចាត់ចូលក្នុងប្រភេទបទលហុតាមមាត្រា៤៨ នៃក្រមព្រហ្មទណ្ឌ។ ប៉ុន្តែច្បាប់នេះអាចអនុវត្តការព្យួរសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតរយៈពេលវែង ឬជាអចិន្ត្រៃយ៍បាន។ ដូច្នេះភាពធ្ងន់ធ្ងរនៃការផ្តន្ទាទោសគឺមិនសមាមាត្រទៅនឹងទំហំនៃការរំលោភបំពាននោះទេ។ នៅក្នុងបរិបទនេះ ការដែលច្បាប់ស្តីពីវិសោធនកម្មច្បាប់បោះឆ្នោត ផ្តល់សិទ្ធិអំណាចពេញលេញដល់ គ.ជ.ប ដែលស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាលក្នុងការដាក់ទណ្ឌកម្មទាំងនេះ និងសម្រេចអំពីរយៈពេល ដែលនាំឱ្យមានការព្រួយបារម្ភ ព្រោះច្បាប់នេះមិនកំណត់អំពីពេលវេលាដែលបុគ្គលណាមួយអាចត្រូវបានដកហូតសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតនោះទេ។ មិនត្រឹមតែបង្កើនការព្រួយបារម្ភអំពីដំណើរការប៉ុណ្ណោះទេ ហានិភ័យក៏កើនឡើងផងដែរថាបទប្បញ្ញត្តិថ្មីអាចនឹងត្រូវប្រើប្រាស់ជាអាវុធក្នុងការហាមឃាត់សមាជិកគណបក្សជំទាស់ពីការចូលរួមការបោះឆ្នោតជាច្រើនទសវត្សរ៍។

ទោះបីជាការធ្វើវិសោធនកម្មថ្មីស្របទៅតាមច្បាប់ជាតិក៏ដោយ ក៏ការធ្វើវិសោធនកម្មនោះមិនបានបំពេញកាតព្វកិច្ចរបស់កម្ពុជា ក្នុងការមិនរឹតត្បិតសិទ្ធិសេរីភាពខាងការបញ្ចេញមតិដោយឥតហេតុផលនោះឡើយ។ ការធ្វើវិសោធនកម្មនេះក៏នាំឱ្យមានការព្រួយបារម្ភផងដែរ ដែលត្រូវបានអនុម័តក្នុងលក្ខណៈប្រញាប់ប្រញាល់ និងហាក់ដូចជាប្រតិកម្មចំពោះការអំពាវនាវតាមអ៊ីនធឺណិតឱ្យធ្វើពហិការការបោះឆ្នោតជាតិ ឆ្នាំ២០២៣ និងគូសសន្លឹកឆ្នោតចោល បន្ទាប់ពីការដកសិទ្ធិគណបក្សភ្លើងទៀនដែលជាគណបក្សប្រឆាំងដ៏សំខាន់កាលពីខែឧសភា ឆ្នាំ២០២៣ និងដោយគ្មានការជជែកដេញដោលជាសាធារណៈណាមួយឡើយ។ នៅក្នុងសេចក្តីថ្លែងការណ៍រួមមួយចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៣ ក្រុមអង្គការសង្គមស៊ីវិល សមាគម និងសហជីពចំនួន២៤ បានលើកឡើងថាការអនុម័តយ៉ាងឆាប់រហ័សនេះគឺជា "ការចាកចេញពីមាគ៌ាប្រជាធិបតេយ្យដែលទាមទារឱ្យមានការចូលរួម" ពីភាគីពាក់ព័ន្ធ។ ពួកគេក៏បានអំពាវនាវឱ្យរដ្ឋាភិបាលពន្យារដំណើរការ និងដាក់សេចក្តីព្រាងវិសោធនកម្មនេះឱ្យមានកិច្ចពិភាក្សាទូលំទូលាយតាមការចូលរួមបែបប្រជាធិបតេយ្យ និងសិទ្ធិមនុស្សរហូតការបោះឆ្នោតជាតិចប់រួចរាល់។[35]

[35] គីម យុទ្ធថារ៉ូ, "ក្រសួងរិះគន់ចំពោះការអំពាវនាវឱ្យពន្យារពេលវិសោធនកម្មច្បាប់បោះឆ្នោត"។ (ភ្នំពេញប៉ុស្តិ៍, ២៨ មិថុនា ២០២៣)។

## IV. ស្ថានភាពនៃសេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាននៅកម្ពុជា

ចាប់ពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២២ ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៣ សិទ្ធិសេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាន នៅតែបន្តរងការវាយប្រហារនៅក្នុងប្រទេសកម្ពុជា ដោយអ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្ស តែងរងការបង្ក្រាប និងដៅមុខសញ្ញាដោយសារការអនុវត្តសិទ្ធិស្របច្បាប់ក្នុងការរាយការណ៍ និងការតស៊ូមតិសំខាន់ៗរបស់ខ្លួន។ តារាងខាងក្រោមនេះ សង្ខេបអំពីស្ថានភាពនៃសិទ្ធិទាំងបីក្នុងអំឡុងពេលនៃរបាយការណ៍នេះ៖




| ស្ថានភាពនៃសេរីភាពសារព័ត៌មាន | ស្ថានភាពនៃសេរីភាពខាងការបញ្ចេញមតិរបស់អ្នកការពារសិទ្ធិមនុស្ស | ស្ថានភាពនៃសិទ្ធិទទួលព័ត៌មាន |
|---|---|---|
| • អាជ្ញាបណ្ណផ្សព្វផ្សាយចំនួនប្រាំត្រូវបានដកហូត។<br>• អ្នកសារព័ត៌មាន១៦ នាក់ ប្រឈមមុខនឹងចំណាត់ការតាមផ្លូវច្បាប់៖<br>- កោះហៅ ៤ នាក់<br>- សួរចម្លើយ ៣ នាក់<br>- ឃុំខ្លួន ៧ នាក់<br>- បង្ខំឱ្យចុះកិច្ចសន្យា ១នាក់ | • អ្នកការពារសិទ្ធិមនុស្ស ចំនួន ១០០ នាក់ ប្រឈមនឹងចំណាត់ការផ្លូវច្បាប់៖<br>- កោះហៅ ២៦ នាក់<br>- សួរចម្លើយ ៥២ នាក់<br>- ឃាត់ខ្លួន ១៨ នាក់<br>- ឃុំខ្លួន ៣៤ នាក់<br>- ចោទប្រកាន់ ៣ នាក់<br>- ផ្តន្ទាទោស ២១ នាក់ | • អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា («អ.វ.ត.ក») បានរក្សាប័ណ្ណសាររបស់ខ្លួន និងលើកកម្ពស់សិទ្ធិសាធារណជនក្នុងការយល់ដឹងអំពីហេតុការណ៍កន្លងមកទាក់ទងនឹងការប្រព្រឹត្តបទឧក្រិដ្ឋកម្រិតធ្ងន់។<br>• រដ្ឋាភិបាលបានបិទខ្ទប់ការចូលទៅប្រើប្រាស់គេហទំព័រសារព័ត៌មានមួយចំនួនមុនការបោះឆ្នោតជាតិឆ្នាំ២០២៣ ។ |

| | | |
|---|---|---|
| - ចោទប្រកាន់ ៥ នាក់<br>- ចាប់ខ្លួន ៥ នាក់<br>- ផ្តន្ទាទោស ១ នាក់<br>- តម្កល់សាលក្រម ២ នាក់។ | - តុលាការជាន់ខ្ពស់តម្កល់សេចក្តីសម្រេចផ្តន្ទាទោស ៧ នាក់ ។ | • អ្នកសារព័ត៌មានមានភាពលំបាកក្នុងការទទួលព័ត៌មានពីមន្ត្រីសាធារណៈ។<br>• ការអនុម័តច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានបន្តប្រឈមនឹងការពន្យារពេល។ |

## ៤.១ ស្ថានភាពនៃសេរីភាពសារព័ត៌មាន[36]

អំឡុងពេលនៃរបាយការណ៍ រដ្ឋាភិបាលបានបញ្ជាក់ជាថ្មីនូវការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការលើកកម្ពស់សេរីភាពសារព័ត៌មាន។[37] ទោះជាយ៉ាងនេះក៏ដោយ ការវិវត្តផ្សេងទៀតបានបង្ហាញថាសេរីភាពសារព័ត៌មាននៅតែបន្តរងការប៉ះពាល់នៅទូទាំងប្រទេសកម្ពុជា។ របត់ខាងក្រោមនេះបង្ហាញពីការធ្លាក់ចុះនូវសិទ្ធិសេរីភាពនេះ ទន្ទឹមនឹងលទ្ធផលរបស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សក្នុងប្រទេសកម្ពុជារកឃើញថា ប្រព័ន្ធផ្សព្វផ្សាយរបស់ប្រទេសនេះស្ថិតក្នុងនៅឆ្នាំ ២០២២-២០២៣ មានសភាពយ៉ាប់យ៉ឺនជាងពេលមុន។[38]




នៅក្នុងឆ្នាំ **២០២៣** នៅកម្ពុជាមានៈ ប្រព័ន្ធផ្សព្វផ្សាយចំនួន **២១៥៤** ក្នុងនោះមានគេហទំព័រព័ត៌មាន និងទូរទស្សន៍អនឡាញចំនួន **៨៧៨** កាសែតចំនួន **៦៦១** ស្ថានីយ៍វិទ្យុចំនួន **២២១** ស្ថានីយទូរទស្សន៍ចំនួន **១៩** និងស្ថានីយទូរទស្សន៍ផ្សាយបន្តចំនួន **១៦៥**។ ភ្នាក់ងារសារព័ត៌មានការិយាល័យនៃវិទ្យុ និងទូរទស្សន៍បរទេសចំនួន **១៧** និងសមាគមប្រព័ន្ធផ្សព្វផ្សាយចំនួន**៥១**។

ការគំរាមកំហែងដែលអ្នកសារព័ត៌មានបានប្រឈមក្នុងពេលបំពេញការងារបែបស៊ើបអង្កេត និងអនុវត្តសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន ត្រូវបានកត់ត្រាទុក។ ការគំរាមកំហែងទាំងនេះរួមមានការដកហូតអាជ្ញាបណ្ណស្ថាប័នសារព័ត៌មាន ការឃាំឃីតាមប្រព័ន្ធតុលាការ ការរារាំងនៅពេលរាយការណ៍អំពីបញ្ហារសើប

[36] ព័ត៌មាននៅក្នុងប្រអប់អំពីចំនួនស្ថាប័នព័ត៌មានគឺបានមកពី ជា វណ្ណៈ "ការកើនឡើងនៃចំនួនស្ថាប័នសារព័ត៌មានបង្ហាញពីសេរីភាពខាងការបញ្ចេញមតិ និងសារព័ត៌មាននៅកម្ពុជា"។ (ខ្មែរថាមស៍, ៦ មេសា ២០២៣)។

[37] ហេង បញ្ញា, "លោករដ្ឋមន្ត្រីបញ្ជាក់ជាថ្មីពីការប្តេជ្ញាចិត្តលើកកម្ពស់សេរីភាពសារព័ត៌មាន"។ (ខ្មែរថាមស៍, ២៨ តុលា ២០២២); នីកា, "រដ្ឋាភិបាលបន្តប្តេជ្ញាចិត្តការពារសេរីភាពសារព័ត៌មាន"។ (ខ្មែរថាមស៍, ៤ ឧសភា ២០២៣)។

[38] ក្រុមប្រឹក្សាសិទ្ធិមនុស្ស, "របាយការណ៍អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅប្រទេសកម្ពុជា"។ វិទីត មុនថាប៊ន, (A/HRC/54/75 ២០ កក្កដា ២០២៣) ទំព័រទី៥។

ដែលនាំទៅដល់ការដាក់កំហិតខ្លួនឯង ការគំរាមកំហែងសន្តិសុខផ្លូវកាយ ក៏ដូចជាការរើសអើង និងការឃោឃៅមកលើអ្នកសារព័ត៌មានជាស្ត្រី ជាដើម។

អង្គការអ្នកសារព័ត៌មានគ្មានព្រំដែនបានដាក់ចំណាត់ថ្នាក់ប្រទេសកម្ពុជានៅលេខរៀងទី១៤៧ ក្នុងចំណោម ១៨០ ប្រទេសដែលបានវាយតម្លៃនៅក្នុងសន្ទស្សន៍សេរីភាពសារព័ត៌មានពិភពលោកឆ្នាំ២០២៣[39] បង្ហាញថាសេរីភាពសារព័ត៌មានដែលជាធាតុផ្សំដ៏សំខាន់មួយនៃលទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ កំពុងស្ថិតក្រោមការគំរាមកំហែងនៅក្នុងប្រទេស។

### *ការដកហូតអាជ្ញាបណ្ណផ្សព្វផ្សាយ*

រដ្ឋាភិបាលបានប្រកាសដកអាជ្ញាបណ្ណប្រព័ន្ធផ្សព្វផ្សាយចំនួនប្រាំក្នុងអំឡុងនៃរបាយការណ៍។ នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២ គេហទំព័រសារព័ត៌មាន Khmer Cover TV (KCTV) បានចេញផ្សាយអត្ថបទ និងវីដេអូឃ្លីបមួយបង្ហាញពីកម្មករនៅក្រុមហ៊ុនកាឡាក់ស៊ី ណាវ៉ាត់ត្រា ចាក់ខ្សាច់លុបបឹងនៅស្រុកល្វាឯម ខេត្តកណ្ដាល។ អត្ថបទព័ត៌មាននេះបានសរសេរថា ក្រុមហ៊ុនកំពុងសាងសង់ផ្លូវបេតុងមួយខ្សែដើម្បីភ្ជាប់ជាមួយគម្រោងអភិវឌ្ឍន៍ និងបានអះអាងថាការសាងសង់នេះបានបំផ្លាញស្ពានសាធារណៈនៅលើដីរបស់រដ្ឋ។ ក្រុមហ៊ុនបានឆ្លើយតបជាមួយនឹងលិខិតគំរាមប្ដឹងស្ថាប័នសារព័ត៌មានពីបទបរិហារកេរ្តិ៍ និងទាមទារឱ្យដកអត្ថបទ និងវីដេអូឃ្លីបនោះចេញ។ សារព័ត៌មាន KCTV បានបដិសេធដោយលើកឡើងថាព័ត៌មាននោះផ្អែកលើការពិត ហើយថាខ្លួនមានសិទ្ធិក្នុងការផ្សព្វផ្សាយ។[40] នៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៣ ក្រសួងព័ត៌មានបានដកហូតអាជ្ញាបណ្ណសារព័ត៌មានរបស់ KCTV ដោយចោទប្រកាន់ថាស្ថាប័ននេះមិនបានអនុវត្តតាមការណែនាំរបស់ក្រសួងចំនួនពីរលើក និង "បានរំលោភលើវិជ្ជាជីវៈធ្ងន់ធ្ងរ" ប៉ុន្តែក្រសួងមិនបានបញ្ជាក់បន្ថែមចំពោះការរំលោភបំពានទាំងនេះទេ។[41]

[39] អ្នកសារព័ត៌មានគ្មានព្រំដែន, សន្ទស្សន៍សេរីភាពសារព័ត៌មានពិភពលោកឆ្នាំ២០២៣។

[40] ឃួន ណារីម, "អ្នកសារព័ត៌មានប្រឈមនឹងការចោទប្រកាន់ពីបទជំរិតទារប្រាក់ និងរងការគំរាមពីឧកញ៉ា ដោយសារអត្ថបទរសើប"។ (ខេមបូចា, ២៧ ធ្នូ ២០២២)។

[41] ខ្មែរថាមស៍, "អាជ្ញាបណ្ណគេហទំព័រត្រូវបានដកហូតបន្ទាប់ពីរំលោភវិជ្ជាជីវៈធ្ងន់ធ្ងរ"។ (ខ្មែរថាមស៍, ២០ មករា ២០២៣)។




នៅថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២៣ វិទ្យុសំឡេងប្រជាធិបតេយ្យ (វីអូឌី) ដែលជាស្ថាប័នសារព័ត៌មានឯករាជ្យចុងក្រោយនៅកម្ពុជា បានចុះផ្សាយអត្ថបទមួយដកស្រង់សម្ដីអ្នកនាំពាក្យរដ្ឋាភិបាល លោក ផៃ ស៊ីផាន ដែលថាលោក ហ៊ុន ម៉ាណែត ដែលពេលនោះជាអគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ បានចុះហត្ថលេខាលើកញ្ចប់ថវិកាសង្គ្រោះចំនួន១០ម៉ឺនដុល្លារអាមេរិក ជួយដល់ប្រទេសទួកគី ជំនួសឪពុករបស់លោក ដែលពេលនោះជាលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន។ លោក ហ៊ុន ម៉ាណែត បានច្រានចោលចំពោះការលើកឡើងនេះ ហើយបានទាមទារឱ្យវីអូឌីផ្ដល់នូវភស្ដុតាងនៃការចុះហត្ថលេខាលើឯកសារនេះ។ នៅថ្ងៃទី១១ ខែកុម្ភៈ តាមរយៈបណ្ដាញសង្គម លោក ហ៊ុន សែន បានទាមទារឱ្យវីអូឌីសុំទោសជាសាធារណៈក្នុងរយៈពេល៧២ម៉ោង មុននឹងបន្ថយរយៈពេលមកត្រឹមម៉ោង១០ព្រឹក ថ្ងៃទី១៣ ខែកុម្ភៈ វិញ។ ថ្ងៃទី១២ ខែកុម្ភៈ មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យដែលជាស្ថាប័នគ្រប់គ្រងវិទ្យុវីអូឌី បានចេញលិខិតមួយច្បាប់សម្ដែងការសោកស្ដាយចំពោះការភាន់ច្រឡំណាមួយដែលអត្ថបទព័ត៌មានបង្កឡើង និងសុំការអធ្យាស្រ័យពីនាយករដ្ឋមន្ត្រី។ នៅថ្ងៃដដែលនោះ លោក ហ៊ុន សែន បានហៅការឆ្លើយតបនោះថា "មិនអាចទទួលយកបាន" និងបញ្ជាឱ្យក្រសួងព័ត៌មានដកហូតអាជ្ញាបណ្ណផ្សព្វផ្សាយរបស់វិទ្យុវីអូឌីនៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៣។[42]

នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៣ ប្រធានផ្នែកសិទ្ធិមនុស្សនៃ អ.ស.ប លោក Volker Türk បានអំពាវនាវឱ្យរដ្ឋាភិបាលលុបចោល "ការសម្រេចចិត្តដ៏គួរឱ្យព្រួយបារម្ភ" នេះវិញ។ លោកបានកត់សម្គាល់ថាការដកហូតអាជ្ញាបណ្ណរបស់វីអូឌីនេះ មិនបានធ្វើឡើងដោយហ្មត់ចត់ និងតម្លាភាពដូចដែលច្បាប់កម្ពុជាស្ដីពីរបបសារព័ត៌មានបានកំណត់នោះទេ ហើយក៏មិនបានបំពេញតាមលក្ខខណ្ឌតម្រូវរបស់ច្បាប់អន្តរជាតិ ចំពោះនីត្យានុកូលភាព ភាពចាំបាច់ និងសមាមាត្រនោះដែរ។[43] លោក Phil Robertson នាយករងនៃអង្គការឃ្លាំមើលសិទ្ធិមនុស្សប្រចាំ

---

[42] ភ្លៃរ បិលរីន, "នាយករដ្ឋមន្ត្រីកម្ពុជាបញ្ជាឱ្យបិទស្ថាប័នព័ត៌មានឯករាជ្យក្នុងស្រុក"។ (រ៉យទ័រ, ១៣ កុម្ភៈ ២០២៣); ឡាយ សាមាន, "លោក ហ៊ុន សែន បិទស្ថាប័នសារព័ត៌មានឯករាជ្យវីអូឌី"។ (ភ្នំពេញប៉ុស្តិ៍, ១២ កុម្ភៈ ២០២៣); ខេលី នីង, "លោក ហ៊ុន សែន បិទស្ថាប័នសារព័ត៌មានឯករាជ្យវីអូឌី"។ (ប៊ីប៊ីស៊ី, ១៣ កុម្ភៈ ២០២៣); តន វិបុល, "ក្រសួង៖ អាជ្ញាបណ្ណវីអូឌីត្រូវបានដកហូតដោយសារតែការរំលោភបំពានធ្ងន់ធ្ងរ"។ (ខ្មែរថាមស៍, ១៤ កុម្ភៈ ២០២៣)។

[43] ការិយាល័យឧត្ដមស្នងការ, "ការលើកឡើងដោយលោក Volker Türk ប្រធានផ្នែកសិទ្ធិមនុស្សនៃ អ.ប.ស បន្ទាប់ពីការបិទស្ថាប័នប្រព័ន្ធផ្សព្វផ្សាយឯករាជ្យនៅកម្ពុជា"។ (១៣ កុម្ភៈ ២០២៣)។

តំបន់អាស៊ី បានលើកឡើងថាចំណាត់ការនេះគឺជា "ការបំផ្លិចបំផ្លាញយ៉ាងធ្ងន់ធ្ងរដល់សេរីភាពប្រព័ន្ធផ្សព្វផ្សាយ" ដែលអាច "បញ្ចប់ប្រព័ន្ធផ្សព្វផ្សាយ ដែលមានភាពចាំបាច់សម្រាប់បរិយាកាសបោះឆ្នោតដែលអាចជឿទុកចិត្តបាន"។[44] ស្រដៀងគ្នានេះដែរ អង្គការលើកលែងទោសអន្តរជាតិបានលើកឡើងថា "ជាការប៉ុនប៉ងដោយមិនខ្មាសអៀនដើម្បីបិទច្រកដែលនៅសេសសល់សម្រាប់ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យនៅក្នុងប្រទេស "ដោយព្រមានថានឹង "មានផលប៉ះពាល់ភ្លាមៗចំពោះអ្នកដែលហ៊ានចោទសួរពីចំណាត់ការរបស់រដ្ឋាភិបាលកម្ពុជា"។[45] អង្គការអ្នកសារព័ត៌មានគ្មានព្រំដែនក៏បានចូលរួមជាមួយនឹងអង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិចំនួន៩២ស្ថាប័នក្នុងការអំពាវនាវឱ្យរដ្ឋាភិបាល "ដោះស្រាយបញ្ហានេះ ប្រកបដោយការអត់ធ្មត់ វិជ្ជាជីវៈ និងការគោរព ដែលស្របទៅនឹងច្បាប់កម្ពុជា និងមិនប៉ះពាល់ដល់លំហសារព័ត៌មាននៅកម្ពុជា"។[46]




នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៣ ក្រសួងព័ត៌មានបានលុបអាជ្ញាបណ្ណបណ្ដាញផ្សព្វផ្សាយជាភាសាខ្មែរតាមអនឡាញដែលរួមមាន **សហព័ន្ធអ្នកសារព័ត៌មានកម្ពុជា-អាស៊ាន សារព័ត៌មានរស្មីកំពង់ចាម** និង**សារព័ត៌មានដំណឹងក្នុងស្រុក** ដោយចោទថាបាន "រំលោភលើក្រមសីលធម៌អ្នកសារព័ត៌មានយ៉ាងធ្ងន់ធ្ងរ"។ ស្ថាប័នទាំងបីនេះធ្លាប់បានរាយការណ៍ពាក់ព័ន្ធនឹងការចោទប្រកាន់ទៅលើព្រះរាជអាជ្ញារងខេត្តតាកែវក្នុងករណីជំរិតទារប្រាក់មួយ។ ពួកគេក៏បានចុះផ្សាយអត្ថបទមួយដែលលាតត្រដាងថាលោក ស ចំរ៉ុង សមាជិកជាន់ខ្ពស់របស់គណបក្សប្រជាជនកម្ពុជានៅក្នុងរដ្ឋសភាជាតិ បានក្លែងបន្លំឯកសារដើម្បីទទួលបានដីមួយកន្លែងនៅខេត្តបន្ទាយមានជ័យ។ លោក ជា សារ៉ែន ចាងហ្វាងសារព័ត៌មានដំណឹងក្នុងស្រុកបានថ្លែងថា ក្រសួងបានសុំឱ្យលោកដកអត្ថបទទាំងពីរនេះចេញ ប៉ុន្តែលោកបានបដិសេធ។ លោក មាស សោភ័ណ្ឌ អ្នកនាំពាក្យក្រសួងបានច្រានចោលការចោទប្រកាន់នេះ ហើយថាអាជ្ញាបណ្ណត្រូវបានដកហូតដោយសារហេតុផលផ្សេងទៀត ក្នុងនោះមាន ពួកគេ "មិនព្រមកែតម្រូវព័ត៌មានដែលនាំឱ្យមានការយល់ច្រឡំដែលពួកគេបានចុះផ្សាយ"។[47] នៅថ្ងៃទី២០ ខែមីនា ក្រសួងបានគំរាមចាត់វិធានការផ្លូវច្បាប់លើសារព័ត៌មានខេមបូចា ប្រសិនបើសារព័ត៌មាននេះមិនព្រមកែ

44 អង្គការឃ្លាំមើលសិទ្ធិមនុស្ស, "កម្ពុជា៖ លោក ហ៊ុន សែន លប់បំបាត់សេរីភាពប្រព័ន្ធផ្សព្វផ្សាយ"។ (១៤ កុម្ភៈ ២០២៣)។

45 អង្គការលើកលែងទោសអន្តរជាតិ, "ប្រទេសកម្ពុជា៖ ការបិទស្ថាប័នវីអូឌីគឺជាការប៉ុនប៉ងបិទច្រកសម្រាប់ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ"។ (១៣ កុម្ភៈ ២០២៣)។

46 អ្នកសារព័ត៌មានគ្មានព្រំដែន, "អង្គការអ្នកសារព័ត៌មានគ្មានព្រំដែនចូលរួមជាមួយអង្គការសេរីភាពសារព័ត៌មាន និងសង្គមស៊ីវិល ក្នុងការថ្កោលទោសការសម្រេចរបស់រដ្ឋាភិបាលកម្ពុជាក្នុងការដកហូតអាជ្ញាបណ្ណប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ វីអូឌី"។ (១៣ កុម្ភៈ ២០២៣)។

47 ឃួន ណារីម, "ក្រសួងព័ត៌មានបានលុបអាជ្ញាបណ្ណផ្សព្វផ្សាយសារព័ត៌មានចំនួនបីដោយសារបានចុះផ្សាយព័ត៌មានពាក់ព័ន្ធនឹងការបោកប្រាស់យកដីធ្លីពីសំណាក់មន្ត្រីជាន់ខ្ពស់ព្រឹទ្ធសភា"។ (ខេមបូចា, ១៨ មីនា ២០២៣)។

តម្រូវលើអត្ថបទរបស់ខ្លួន ដែលបានសរសេរដោយមិនបានដាក់បញ្ចូលចំណុចសំខាន់ៗដែលលោក មាស សោភ័ណ្ឌ បាននិយាយពាក់ព័ន្ធនឹងការដេកហូតអាជ្ញាបណ្ណទាំងនោះ។[48]

### *ការយាយីតាមប្រព័ន្ធតុលាការលើអ្នកសារព័ត៌មាន*

នៅប៉ុន្មានឆ្នាំចុងក្រោយនេះ អាជ្ញាធរបានបង្រ្កាបទៅលើប្រព័ន្ធផ្សព្វផ្សាយក្នុងគោលបំណងទប់ស្កាត់ ឬដាក់ទណ្ឌកម្មទៅលើសារព័ត៌មានដែលមិនស្របនឹងខ្លួន។ ជាពិសេស ចំណាត់ការផ្លូវច្បាប់បាននឹងកំពុងបន្តដាក់ចេញពីអាជ្ញាធរ និងភាគីទីបីដើម្បីបំភិតបំភ័យអ្នកសារព័ត៌មាន និងរឹតត្បិតសិទ្ធិ សេរីភាពក្នុងការរាយការណ៍របស់ពួកគេ។

អ្នកសារព័ត៌មានពីនាក់ដែលត្រូវបានសម្ភាសន៍សម្រាប់របាយការណ៍នេះ បានលើកឡើងពីការគំរាមកំហែងចាត់វិធានការផ្លូវច្បាប់យ៉ាងជាក់លាក់ក្រោមបទញុះញង់ ឬបរិហារកេរ្តិ៍ ថាជាការគំរាមកំហែងដល់សេរីភាពសារព័ត៌មាននៅកម្ពុជា។ អ្នកសារព័ត៌មានម្នាក់ដែលផ្តល់បទសម្ភាសន៍អំឡុងខែវិច្ឆិកា ឆ្នាំ២០២២ ដល់ខែមីនា ឆ្នាំ២០២៣ ក៏បានលើកឡើងដែរថាគាត់បានប្រឈមនឹងបណ្តឹងព្រហ្មទណ្ឌជាង១០បណ្តឹង ពាក់ព័ន្ធនឹងការរាយការណ៍របស់គាត់។ គិតត្រឹមដើមឆ្នាំ២០២៣ គាត់នៅតែប្រឈមនឹងការចោទប្រកាន់ពីបទបរិហារកេរ្តិ៍ចំនួនពីរករណី។ ទោះជាយ៉ាងណាក៏ដោយ ការយាយីតាមប្រព័ន្ធតុលាការនេះមិនបានរារាំងគាត់ពីការបន្តការងាររបស់គាត់នោះទេ *"បើខ្ញុំគិតថានេះជាព័ត៌មានប្រឈម ហើយខ្ញុំមិនហ៊ានផ្សព្វផ្សាយ ខ្ញុំឈប់ធ្វើជាអ្នកសារព័ត៌មានល្អជាង"។*

នៅចន្លោះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២២ ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៣ រដ្ឋាភិបាល ឬភាគីទីបីបាន **ចាត់វិធានការផ្លូវច្បាប់មកលើអ្នកសារព័ត៌មានយ៉ាងហោចណាស់ ១៦នាក់** ដែលមានការថយចុះចំនួន ២០ភាគរយធៀបនឹងចំនួនអ្នកសារព័ត៌មាន (២០នាក់) ដែលប្រឈមមុខនឹងវិធានការផ្លូវច្បាប់ក្នុងរយៈពេលដូចគ្នានៃរបាយការណ៍មុន។ ក្នុងចំណោមអ្នកសារព័ត៌មានទាំងនេះ៖




- កោះហៅចំនួន ៤ នាក់

[48] នាង សុគន្ធា, "ក្រសួងទាមទារឱ្យកែតម្រូវចំពោះសម្រង់សម្តីសង្ខេបដែលដកស្រង់ខុស"។ (ភ្នំពេញប៉ុស្តិ៍, ២០ មីនា ២០២៣)។

- ស្ដារចម្លើយចំនួន ៣ នាក់
- ឃុំខ្លួនចំនួន ៧ នាក់
- បង្ខំឱ្យចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្យាថាខ្លួននឹង «បញ្ឈប់» ធ្វើសកម្មភាពជាលាក់ណាមួយ ចំនួន ១ នាក់
- រងការចោទប្រកាន់ចំនួន ៥ នាក់
- ចាប់ខ្លួនចំនួន ៥ នាក់
- កាត់ទោសចំនួន ១ នាក់
- ការកាត់ទោសត្រូវបានតម្កល់ចំនួន ២ នាក់ ។

***អ្នកសារព័ត៌មានបីនាក់ត្រូវបានផ្ដន្ទាទោស ឬបានផ្ដន្ទាទោសពីមុនដោយសាលាឧទ្ធរណ៍ រវាងថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២២ និងថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៣***

ករណីលោក **សែម ឌីយ៉ា៖** នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២ តុលាការខេត្តបាត់ដំបងបានផ្ដន្ទាទោសលោក សែម ឌីយ៉ា ចាងហ្វាងនៃសារព័ត៌មានបាត់ដំបងប៉ុស្ដិ៍ និងអ្នកលក់ពោតពីរនាក់ផ្សេងទៀតឱ្យជាប់ពន្ធនាគាររយៈពេលមួយឆ្នាំពីបទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ តាមមាត្រា ៤៩៥ នៃក្រមព្រហ្មទណ្ឌ ប៉ុន្តែទោសដែលនៅសល់ត្រូវបានព្យួរ។ អ្នកទាំងបីធ្លាប់បានផ្សាយផ្ទាល់ការប្រមូលផ្ដុំគ្នាមួយដែលមនុស្សរាប់រយនាក់តវ៉ា ពាក់ព័ន្ធនឹងការឃាត់រថយន្តដឹកពោតរបស់ឈ្មួញថៃ ដោយអាជ្ញាធរមូលដ្ឋានកាលពីថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២២។ ក្រោយមកពួកគេត្រូវបានចោទប្រកាន់ពីបទញុះញង់ឱ្យអ្នកបើកបរយករថយន្តដឹកទំនិញពីប៉ូលិសមកវិញដោយបង្ខំ[49] មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ បាននិយាយថាលោក ឌីយ៉ា គ្រាន់តែផ្សព្វផ្សាយហេតុការណ៍នេះក្នុងនាមជាអ្នកសារព័ត៌មានប៉ុណ្ណោះ។[50]

ករណីលោក **ប៉ែន នួន៖** នៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៣ តុលាការកំពូលបានតម្កល់សេចក្ដីសម្រេចរបស់សាលាដំបូងខេត្តឧត្តរមានជ័យកាលពីខែវិច្ឆិកា ឆ្នាំ២០២០ ដែលសម្រេចផ្ដន្ទាទោសលោក ប៉ែន នួន ដែលជាអ្នកសារព័ត៌មានអនឡាញឈ្មោះ "ស្រទាប់យុវវ័យ" និងពិន័យជាប្រាក់ចំនួន ៥ លានរៀល ពីបទបរិហារកេរ្តិ៍ ជាសាធារណៈតាមមាត្រា ៣០៥ នៃក្រមព្រហ្មទណ្ឌ ។ លោក ក៏ត្រូវបានបង្គាប់ឱ្យបង់សំណងចំនួន ៨០ លានរៀល ដល់មន្ត្រីយោធាពីរនាក់ (ក្នុងម្នាក់ ៤០ លានរៀល) ដែលលោកបានផ្សាយថាបានរំលោភយកដីរបស់ប្រជាពលរដ្ឋជាច្រើនគ្រួសារដែលរស់នៅក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ តាមរយៈការបង្ហោះតាមហ្វេសប៊ុកជាបន្តបន្ទាប់កាលពីឆ្នាំ២០១៩។[51]

---

[49] សុខ សារី, "តុលាការខេត្តបាត់ដំបងបានផ្ដន្ទាទោសចាងហ្វាងកាសែតម្នាក់ និងពលរដ្ឋពីរនាក់ដាក់ពន្ធនាគារម្នាក់ៗមួយឆ្នាំ"។ (ខេមបូចា, ២៣ ធ្នូ ២០២២); ប៊ុត រស្មីគង្គា, "ឃាត់ខ្លួនមនុស្ស៣នាក់ពីបទញុះញង់ឱ្យមានការតវ៉ា"។ (ខ្មែរថាមស៍, ១៨ កក្កដា ២០២២)។

[50] គណៈកម្មាធិការការពារអ្នកសារព័ត៌មាន, "សែម ឌីយ៉ា, បាត់ដំបងប៉ុស្ដិ៍ | ជាប់ពន្ធនាគារនៅកម្ពុជា | ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ ២០២២"។ (មិនមានថ្ងៃខែ)។

[51] ប៊ុត រស្មីគង្គា, "តុលាការកំពូលតម្កល់ការកាត់ទោសការបរិហារកេរ្តិ៍របស់អ្នកសារព័ត៌មាន"។ (ខ្មែរថាមស៍, ២៤ មករា ២០២៣)។

ករណីលោក **កៅ ពិសិដ្ឋ៖** អ្នកសារព័ត៌មាននៃគេហទំព័រសៀមរាបទាន់ហេតុការណ៍ (Siem Reap Breaking News) ត្រូវបានចាប់ខ្លួនកាលពីខែកក្កដា ឆ្នាំ២០២១ នៅខេត្តបាត់ដំបង បន្ទាប់ពីបានរិះគន់រដ្ឋាភិបាលកម្ពុជា និងអំពីប្រសិទ្ធភាពនៃវ៉ាក់សាំងកូវីដ១៩ ដែលផលិតដោយប្រទេសចិន នៅលើបណ្ដាញសង្គម។ កាលពីខែធ្នូ ឆ្នាំ២០២១ លោកត្រូវបានតុលាការផ្ដន្ទាទោសឱ្យជាប់ពន្ធនាគាររយៈពេល ២ឆ្នាំ ពីបទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ និងរារាំងការអនុវត្តវិធានការទប់ស្កាត់ជំងឺកូវីដ១៩ តាមមាត្រា១១ នៃច្បាប់ស្ដីពី *វិធានការទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ១៩ និងជំងឺគ្រោះថ្នាក់ និងជំងឺឆ្លងផ្សេងៗ*។ សាលាឧទ្ធរណ៍បាត់ដំបង បានសម្រេចតម្កល់ការផ្ដន្ទាទោសរបស់លោក នៅថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២២[52] ខណៈតុលាការកំពូលក៏បន្តតម្កល់ការផ្ដន្ទាទោសលើរូបលោកដូចគ្នានៅថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២៣។[53] លោកត្រូវបានតុលាការដោះលែងវិញបន្ទាប់ពីបានអនុវត្តទោសរួចរាល់កាលពីថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២៣។[54]

ករណីទាំងនេះបង្ហាញពីបញ្ហាប្រឈម ដែលអ្នកសារព័ត៌មានបានប្រឈមមុខនៅពេលអនុវត្តការងាររបស់ខ្លួន។ អ្នកសារព័ត៌មានជាច្រើនប្រឈមនឹងការឃុំខ្លួន និងសាកសួរតាមអំពើចិត្តនៅពេលដែលពួកគេកំពុងបំពេញការងារ ប៉ុន្តែក៏មានការចោទប្រកាន់ និងការកាត់ទោសព្រហ្មទណ្ឌផងដែរ ដោយសារតែអាជ្ញាធរ និងភាគីទីបីហាក់ដូចជាមានការតាំងចិត្តប្រើច្បាប់ព្រហ្មទណ្ឌដើម្បីបំបិទការរាយការណ៍របស់ពួកគេ។ ការឃុំខ្លួន និងការចោទប្រកាន់តាមអំពើចិត្តត្រូវបានប្រើជាឧបករណ៍ និងយុទ្ធសាស្ត្រប្រឆាំងនឹងការចូលរួមរបស់សាធារណជន ដើម្បីបំភិតបំភ័យអ្នកសារព័ត៌មាន និងមិនលើកទឹកចិត្តឱ្យពួកគេរាយការណ៍ អំពីបញ្ហាដែលត្រូវបានគេចាត់ទុកថាជារឿងរ៉ាវ ឬពាក់ព័ន្ធនឹងមន្ត្រីមានអំណាច ឬតួអង្គផ្នែកសេដ្ឋកិច្ច។

***បញ្ហាប្រឈមនៅក្នុងការរាយការណ៍អំពីបញ្ហាដែលចាត់ទុកថាមានលក្ខណៈរសើប នាំឱ្យមានការចាត់ពិរុទ្ធខ្លួនឯង***

អំឡុងពេលនៃរបាយការណ៍ ម.ស.ម.ក បានកត់ត្រាហេតុការណ៍ជាច្រើនដែលអាជ្ញាធរ ឬភាគីទីបី បានរឹតត្បិត ឬដាក់សម្ពាធអ្នកសារព័ត៌មានមិនឱ្យរាយការណ៍លើប្រធានបទជាក់លាក់មួយចំនួន។

*បញ្ហាដីធ្លី និងបរិស្ថាន៖* ជម្លោះដីធ្លី ការបំផ្លាញបរិស្ថាន និងការកាប់ឈើខុសច្បាប់ ជាបញ្ហាចម្រូងចម្រាសនៅកម្ពុជាជាយូរមកហើយ។ ទិន្នន័យដែលបានប្រមូលក្នុងអំឡុងពេលនៃរបាយការណ៍ បានបង្ហាញថាការរាយការណ៍អំពីបញ្ហាទាំងនេះនៅតែជាបញ្ហាប្រឈម។ ក្នុងហេតុការណ៍ទាំង ១០ ដែលបានរៀបរាប់ខាងក្រោមនេះ អ្នកសារព័ត៌មាន បានប្រឈមនឹងការជ្រៀតជ្រែកក្នុងការប្រមូលព័ត៌មាន ឬការសរសេរអំពីបញ្ហាពាក់ព័ន្ធនឹងដីធ្លី ឬការបំផ្លាញធនធានធម្មជាតិ។

---

[52] ងាយ ណៃ,"សាលាឧទ្ធរណ៍រក្សាការកាត់ទោសប្រឆាំងនឹងអ្នកកាសែតដែលបានរិះគន់វ៉ាក់សាំង"។ (ខេមបូចា, ៥ កក្កដា ២០២២)។

[53] ម៉េង គ្រុយពន្លក, "តុលាការកំពូលសម្រេចឱ្យអ្នកសារព័ត៌មានជាប់ពន្ធនាគារពីរឆ្នាំ ករណីបង្ហោះសារលើហ្វេសប៊ុករិះគន់រដ្ឋាភិបាល"។ (វីអូឌី, ១ កុម្ភៈ ២០២៣)។

[54] ខេមបូចា, "ស្ថានភាពសារព័ត៌មាននៅកម្ពុជា៖ របាយការណ៍ត្រួតពិនិត្យប្រចាំត្រីមាស ពីខែកក្កដា ដល់ ខែកញ្ញា ឆ្នាំ២០២៣"។ លេខផ្សាយ០៩, ទំព័រ២៤។

***អ្នកសារព័ត៌មានដែលរាយការណ៍អំពីបញ្ហាដីធ្លី និងបរិស្ថាន បានប្រឈមនឹងការរឹតត្បិតជាច្រើនពីថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ២០២២ ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៣***

**<u>ការឃាំឃី ការគំរាមកំហែង និងការបំភិតបំភ័យ៖</u>** នៅថ្ងៃទី២១ ខែមេសា ឆ្នាំ២០២៣ មន្ត្រីឧទ្យាននុរក្ស នៃក្រសួងបរិស្ថាន បានបង្ខំអ្នកសារព័ត៌មាននៃគេហទំព័រម៉ុងហ្គាបាយ (**MONGABAY**) ឈ្មោះ ជ័រវដ ហ្វ្លីន (GERALD FLYNN) និងអ្នកសារព័ត៌មានសេរីពីរនាក់ទៀតឈ្មោះ អ៊េតឌី បិល (ANDY BALL) និងលោក ម៉េង គ្រុយពន្លក ឱ្យចាកចេញពីព្រៃសហគមន៍ព្រះរកាក្នុងខេត្តព្រះវិហារ ខណៈដែលពួកគេកំពុងរាយការណ៍ អំពីការកាប់បំផ្លាញព្រៃឈើ។ ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស ប្រចាំប្រទេសកម្ពុជា បាន រាយការណ៍ថាខ្លួនបានប្ដឹងសំណុំរឿងរបស់ពួកគេទៅកាន់អាជ្ញាធរខេត្ត ហើយក្រោយមកអាជ្ញាធរខេត្តនេះបាន ព្រមព្រៀងមិនឃុំខ្លួនពួកគេវិញ។[55]

នៅថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២៣ អាជ្ញាធរមូលដ្ឋាននៅស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល បានថតរូប អ្នកសារព័ត៌មានខេមបូចា ដែលកំពុងយកព័ត៌មានពីការតវ៉ារបស់ប្រជាពលរដ្ឋប្រឆាំងនឹងការចាក់បំពេញដី ដែលជាផ្នែកមួយនៃគម្រោងព្រលានយន្តហោះអន្តរជាតិតេជោក្រុងតាខ្មៅ។ បុគ្គលម្នាក់ដែលស្លៀកពាក់ក្នុង ឯកសណ្ឋានស៊ីវិល បានថតរូបកាតរបស់អ្នកសារព័ត៌មានខេមបូចា ហើយបាននិយាយថា "ថៅហ្វាយ" របស់ គាត់ចង់និយាយជាមួយអ្នកសារព័ត៌មាន។ បន្ទាប់មកបុគ្គលិកសារព័ត៌មានខេមបូចារូបនោះ បានធ្វើតាមការ ណែនាំរបស់អ្នកភូមិ ដែលឱ្យចាកចេញពីតំបន់នោះដើម្បីបញ្ចៀសការចាប់ខ្លួន។ អ្នកសារព័ត៌មាន ខេមបូចាពីរ នាក់ទៀត មិនអាចទៅដល់ កន្លែងធ្វើការតវ៉ាបានទេនៅថ្ងៃដដែលនោះ។[56]

កាលពីខែសីហា ឆ្នាំ២០២៣ អាជ្ញាធរខេត្តបាត់ដំបង បានគំរាមដាក់ពាក្យបណ្ដឹងពីបទញុះញង់ ប្រឆាំងនឹងអ្នកកាសែតកោះសន្តិភាពម្នាក់លោក ឆោម ភីសាម៉ៃ ពាក់ព័ន្ធនឹងការរាយការណ៍របស់លោក។ កន្លងមក លោកធ្លាប់បានធ្វើការរាយការណ៍ជាបន្តបន្ទាប់ ដោយរិះគន់អាជ្ញាធរមូលដ្ឋាន ដែលខកខានចាត់ វិធានការលើរោងចក្ររបស់ប្រទេសចិន ដែលបង្កឱ្យមានការបំពុលទឹកនៅក្នុងស្រុករតនមណ្ឌល។[57]

**<u>ការចាត់វិធានការតាមផ្លូវច្បាប់៖</u>** នៅថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២២ តុលាការខេត្តបាត់ដំបង បានកោះហៅ អ្នកសារព័ត៌មាននៃគេហទំព័រ SBP Post News **លោក សេន វីរៈ** ឱ្យចូលខ្លួនទៅតុលាការដើម្បីសាកសួរ។ ការ កោះហៅនេះបានធ្វើឡើងប្រហែលបីសប្ដាហ៍បន្ទាប់ពីលោក បានផ្សព្វផ្សាយ និងរាយការណ៍អំពីការតវ៉ារបស់ អ្នកភូមិប្រមាណជា ៦០-៧០ នាក់ ប្រឆាំងនឹងការឈូសឆាយដីរបស់ពួកគេពីសំណាក់អាជ្ញាធរ ដែលមានទី តាំងនៅក្នុងតំបន់ដីសម្បទានរបស់រដ្ឋ នៅតំបន់អាងភាស ស្ថិតនៅឃុំពាមឯក ស្រុកឯកភ្នំ ខេត្តបាត់ដំបង។

---

[55] ខេមបូចា, "ស្ថានភាពសារព័ត៌មាននៅកម្ពុជា៖ របាយការណ៍ត្រួតពិនិត្យប្រចាំត្រីមាស ពីខែមេសា ដល់ ខែមិថុនា ឆ្នាំ២០២៣"។ <u>លេខផ្សាយ០៨</u>, ទំព័រ១៣។

[56] រុន ស្រីដេត និងឃួន ណារីម, "ប្រជាពលរដ្ឋខេត្តកណ្ដាលតវ៉ាប្រឆាំងនឹងការចាក់បំពេញដីនៅជិតតំបន់អភិវឌ្ឍន៍ព្រលានយន្តហោះថ្មី"។ (<u>ខេមបូចា</u>, ៨ មិថុនា ២០២៣); ខេមបូចា, "ស្ថានភាពសារព័ត៌មាននៅកម្ពុជា៖ របាយការណ៍ត្រួតពិនិត្យប្រចាំត្រីមាស ពីខែមេសា ដល់ ខែមិថុនា ឆ្នាំ២០២៣"។ <u>លេខផ្សាយ០៨</u>, ទំព័រ៨។

[57] ខេមបូចា, "ស្ថានភាពសារព័ត៌មាននៅកម្ពុជា៖ របាយការណ៍ត្រួតពិនិត្យប្រចាំត្រីមាស ពីខែកក្កដា ដល់ ខែកញ្ញា ឆ្នាំ២០២៣"។ <u>លេខផ្សាយ០៩</u>, ទំព័រ១៧។

កាលនោះ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ធ្លាប់បានផ្ដាំទៅអាជ្ញាធរមូលដ្ឋានឱ្យដោះស្រាយវិវាទ និងចាត់វិធានការផ្លូវច្បាប់ទៅលើអ្នកសារព័ត៌មានណាដែលបានប្រព្រឹត្តបទល្មើសញុះញង់ ពាក់ព័ន្ធនឹងករណីដីធ្លីខាងលើ។[58]

កាលពីខែតុលា ឆ្នាំ២០២២ តុលាការខេត្តព្រះវិហារ បានចេញដីកាបង្គាប់ឱ្យចាប់ខ្លួនអ្នកសារព័ត៌មានសេរីម្នាក់ឈ្មោះ ទ្រី សុផល ដោយចោទប្រកាន់ពីបទជំរិតទារប្រាក់ បន្ទាប់ពីលោកត្រូវបានគេរាយការណ៍ថាខកខានក្នុងការបង្ហាញខ្លួនសម្រាប់ការត្រួតពិនិត្យប្រចាំខែនៅប៉ុស្តិ៍ប៉ូលីសតាមការកំណត់របស់របស់តុលាការ។ នៅខែធ្នូ ឆ្នាំ២០២១ លោកបានរាយការណ៍អំពីការកាប់ឆ្ការព្រៃរបស់រដ្ឋដែលស្ថិតក្នុងស្រុកគូលែន នៃខេត្តព្រះវិហារ ក្រោយមកលោកត្រូវបានប្ដឹងពីបទ "ជំរិតទារប្រាក់" ដោយម្ចាស់អេស្កាវ៉ាទ័រម្នាក់។ លោកបានទទួលការធានាឱ្យស្ថិតនៅក្រៅឃុំ ដោយដាប់បំរាមត្រួតពិនិត្យរបស់តុលាការទាក់ទងនឹងសំណុំរឿងនេះ កាលពីខែសីហា ឆ្នាំ២០២២។ លោកបានបដិសេធថាមិនបានប្រព្រឹត្តខុសអ្វីទេ ដោយលើកឡើងថា លោកបានអនុវត្តន៍តាមនីតិវិធីរបស់តុលាការទាំងអស់។ *"វាហាក់ដូចជាការបង្ក្រាប ដោយសារពួកគេមិនចង់ឱ្យខ្ញុំធ្វើការរាយការណ៍នៅក្នុងខេត្តនេះទេ"*។[59]

នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២២ អាជ្ញាធរមូលដ្ឋានក្នុងខេត្តព្រះវិហារ បានចាប់ខ្លួនអ្នកសារព័ត៌មានបីរូប រួមមាន លោក មុំ វិបុល លោក ទីន ទ្រី និងលោក ទីន ស៊ីថា ហើយចោទប្រកាន់ពួកគេពីបទជំរិតទារប្រាក់ដែលប្ដឹងដោយក្រុមហ៊ុនកាប់ឈើវៀតណាម PNT។ អ្នកទាំងបី ត្រូវបានចោទប្រកាន់ពីបទទាមទារប្រាក់សំណូកជាថ្នូរនឹងការបិទបាំងព័ត៌មាន អំពីការទិញឈើខុសច្បាប់របស់ក្រុមហ៊ុនខាងលើ។ បងប្អូនសាច់ថ្លៃរបស់អ្នកសារព័ត៌មានទាំងពីររូប បានច្រានចោលការចោទប្រកាន់ទាំងនេះ ខណៈពួកគេបានហៅការចាប់ខ្លួននេះថាជាការប៉ុនប៉ងរារាំង អ្នកសារព័ត៌មានមិនឱ្យពិនិត្យមើលការជួញដូរឈើខុសច្បាប់នេះ។ មិនមានចំណាត់ការណាមួយត្រូវបានធ្វើឡើងប្រឆាំងនឹងក្រុមហ៊ុននេះទេ បើទោះជាមានការចោទប្រកាន់ថា ក្រុមហ៊ុននេះបានពាក់ព័ន្ធក្នុងសកម្មភាពខុសច្បាប់ក៏ដោយ។[60]

នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៣ ប៉ូលិសខេត្តបានចាប់ខ្លួនអ្នកសារព័ត៌មានពលរដ្ឋ និងសកម្មជនដីធ្លីលោក **សួន ញឿន** បន្ទាប់ពីរូបលោកបានថតរូបការជួបប្រជុំដោយសន្តិវិធីរបស់សមាជិកសហគមន៍ឡពាងជាង ៥០នាក់ នៅមុខតុលាការខេត្តកំពង់ឆ្នាំង ។ ពួកគេបានទៅគាំទ្រតំណាងសហគមន៍ពីររូប ដែលបានចូលបំភ្លឺនៅក្នុងតុលាការ ពាក់ព័ន្ធនឹងជម្លោះដីធ្លីជាមួយក្រុមហ៊ុន ខេ.ឌី.ស៊ី (KDC)។ ប៉ូលីសបានរឹបអូសទូរស័ព្ទរបស់លោក និងបានបញ្ជាឱ្យលោកលុបរូបថត និងសួរចម្លើយគាត់អស់រយៈពេលជាងពីរម៉ោង។

---

[58] សុខ សាវី, "អ្នកកាសែតម្នាក់ត្រូវបានតុលាការខេត្តបាត់ដំបងចេញដីកាបញ្ជាឱ្យចូលខ្លួន បន្ទាប់ពីឡាយព័ត៌មានផ្ទាល់ទាក់ទងវិវាទដីធ្លី"។ (ខេមបូចា, ៨ កញ្ញា ២០២២)។

[59] ឃួន ណារីម, "អ្នកសារព័ត៌មានប្រឈមនឹងការចោទប្រកាន់ពីបទជំរិតទារប្រាក់ឧកញ៉ាការគំរាមកំហែងចំពោះព័ត៌មានសេរី"។ (ខេមបូចា, ២៧ ធ្នូ ២០២២)។

[60] អាស៊ីសេរី, "អ្នកកាសែតនៅកម្ពុជាដែលរាយការណ៍ពីការកាប់ឈើខុសច្បាប់ត្រូវចោទប្រកាន់ពីបទជំរិតទារប្រាក់"។ (អាស៊ីសេរី, ១២ ធ្នូ ២០២២)។

លោកត្រូវបានដោះលែងបន្ទាប់ពីបានចុះហត្ថលេខាលើកិច្ចសន្យាមួយ ដែលទំនងជាឱ្យលោកបញ្ឈប់ការផ្សព្វផ្សាយពីការជួបប្រជុំនេះ។[61]

នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៣ **ប៉ូលីសខេត្តកំពង់ធំបានចាប់ខ្លួនអ្នកសារព័ត៌មាន** TNM ឈ្មោះ **សឿន សុជា** ដោយចោទប្រកាន់ពីបទជំរិតទារប្រាក់ទាក់ទងនឹងការរាយការណ៍ជាបន្តបន្ទាប់អំពីការកាប់ឈើខុសច្បាប់ ដែលលោកបានសរសេរ ក្នុងឆ្នាំ២០២០ មុនពេលដែលគាត់ចាប់ផ្តើមធ្វើការឱ្យ TNM។ បើតាម លោក សែម បូរ៉ា ចាងហ្វាងផ្សព្វផ្សាយរបស់ TNM បានឱ្យដឹងថា លោក សឿន សុជា ត្រូវបានឈ្មួញឈើ ៣នាក់ និងមន្ត្រីបរិស្ថានម្នាក់ ប្តឹងពីបទផ្សាយព័ត៌មានមិនពិត ញុះញង់ និងជំរិតទារប្រាក់។ លោក សែម បូរ៉ា បន្ថែមថា កន្លងមកអាជ្ញាធរខេត្តកំពង់ធំ បានព្រមានលោក សឿន សុជា និងប្រព័ន្ធផ្សព្វផ្សាយរបស់លោកកុំឱ្យរាយការណ៍ពីការកាប់ឈើខុសច្បាប់ និងបញ្ហាបរិស្ថាន។ លោក សឿន សុជា ត្រូវបានដោះលែងឱ្យនៅក្រៅឃុំបណ្តោះអាសន្នកាលពីថ្ងៃទី១ ខែមិថុនា បន្ទាប់ពីលោកបានសុំទោស និងទទួលស្គាល់ថាលោកមិនបានផ្ទៀងផ្ទាត់ព័ត៌មានរបស់លោកឱ្យបានត្រឹមត្រូវ។[62]

កាលពីថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៣ អ្នកគ្រប់គ្រងសារព័ត៌មានរាជសីហ៍ឥសាន លោក សុង គឹមហេង និងអ្នកគ្រប់គ្រងសារព័ត៌មានណែតហ្វឹក (Newsnetwork) លោក ជី មួរ ត្រូវបានកោះហៅឱ្យចូលខ្លួននៅសាលាដំបូងខេត្តក្រចេះ ក្រោមបទចោទប្រកាន់ពីបទញុះញង់ និងបរិហារកេរ្តិ៍។ សារព័ត៌មានទាំងពីរនេះធ្លាប់រាយការណ៍ថាមន្ត្រីយោធាស្រុកស្នួល បានបំពុលទឹកបឹងសាធារណៈដែលប្រើប្រាស់ដោយជនជាតិដើមភាគតិចនៅទីនោះ ដោយបានចាក់ដីបំពេញដើម្បីអភិវឌ្ឍរីសត និងខារ៉ាអូខេ។ មន្ត្រីម្នាក់បានស្នើឱ្យអ្នកសារព័ត៌មានទាំងពីរដកអត្ថបទនេះចេញ ឬក៏ប្រឈមមុខនឹងផ្លូវច្បាប់។ នៅទីបំផុត មន្ត្រីរូបនោះបានសម្រេចដកពាក្យបណ្តឹងវិញបន្ទាប់ពីអ្នកសារព័ត៌មានទាំងពីរបានយល់ព្រមតាមសំណើរបស់លោក។[63]

**<u>អំពើហិង្សាលើរាងកាយ</u>**៖ នៅថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២៣ គេហទំព័រម៉ុងហ្គាបាយ (**MONGABAY)**

បានរាយការណ៍ថា អ្នកសារព័ត៌មានរបស់ខ្លួនម្នាក់ត្រូវបានឃុំខ្លួន ហើយត្រូវបានគេគ្រៀកអូសកាត់តាមផ្លូវមួយខណៈពេលដែលព្យាយាមសម្ភាសន៍ជាមួយទាហាននៅខាងក្នុងទីស្នាក់ការកណ្តាលយោធាតំបន់ទី៣ នៃខេត្តកំពង់ស្ពឺ ខណៈអ្នកសារព័ត៌មានម្នាក់នោះកំពុងធ្វើការស៊ើបអង្កេតពីវត្តមានរោងកែច្នៃ និងដេប៉ូឈើក្នុង

[61] យាង សុខមាន, "អង្គការសង្គមស៊ីវិលរិះគន់ការចាប់ខ្លួនលោក សួន ញឿន នៅចំពោះមុខតុលាការខេត្តកំពង់ឆ្នាំង ថាជារឿងអយុត្តិធម៌"។ (<u>សារព័ត៌មានពលរដ្ឋ</u>, ២៣ មករា ២០២៣)។

[62] ខេមបូចា, "ស្ថានភាពសារព័ត៌មាននៅកម្ពុជា៖ របាយការណ៍ត្រួតពិនិត្យប្រចាំត្រីមាស ពីខែមេសា ដល់ ខែមិថុនា ឆ្នាំ២០២៣"។ <u>លេខផ្សាយ០៨</u>, ទំព័រ១១; ជាតិ ចំណាន, "សហគមន៍ព្រៃឡង់ និងមន្ត្រីសង្គមស៊ីវិលទាមទារឱ្យតុលាការខេត្តកំពង់ធំដោះលែងអ្នកកាសែតអនឡាញម្នាក់"។ (<u>អាស៊ីសេរី</u>, ១២ ឧសភា ២០២៣)។

[63] ខេមបូចា, "ស្ថានភាពសារព័ត៌មាននៅកម្ពុជា៖ របាយការណ៍ត្រួតពិនិត្យប្រចាំត្រីមាស ពីខែកក្កដា ដល់ ខែកញ្ញា ឆ្នាំ២០២៣"។ <u>លេខផ្សាយ០៩</u>, ទំព័រ១៦។

បរិវេណទីស្នាក់ការខាងលើ។ ស្ថានការណ៍នេះបានបន្ធូរបន្ថយក្រោយការអន្តរាគមន៍របស់មន្ត្រីជាន់ខ្ពស់ម្នាក់។[64]

នៅពេលសួរថា តើមានប្រធានបទជាក់លាក់ណាមួយដែលអ្នកមិនហ៊ានរាយការណ៍នោះ អ្នកសារព័ត៌មានម្នាក់ដែលត្រូវបានសម្ភាសន៍សម្រាប់របាយការណ៍នេះបានលើកឡើងពីការចោទប្រកាន់ពាក់ព័ន្ធករណីអាជ្ញាធរព្រំដែនកម្ពុជាបានជួលដីឱ្យទៅក្រុមហ៊ុនវៀតណាម។ លោកបាននិយាយថា អាជ្ញាធរបានច្រានចោលការលើកឡើងទាំងនេះ ហើយបានប្រាប់លោកកុំឱ្យជឿលើពលរដ្ឋដែលបានប្រឌិតរឿងនេះ។ អ្នកសារព័ត៌មានម្នាក់ទៀតបញ្ជាក់ថា អ្នកសារព័ត៌មានដែលហ៊ានទម្លាយរឿងដីធ្លីតែងតែរងការរឹតត្បិត។ ដោយពិនិត្យឃើញថា ប្រធានបទនៃបញ្ហាដីធ្លី និងការកាប់បំផ្លាញព្រៃឈើនៅកម្ពុជាមានភាពរសើប ករណីទាំងអស់នេះហាក់ដូចជាបង្ហាញពីការប៉ុនប៉ងរបស់អាជ្ញាធរ ក្នុងការទប់ស្កាត់មិនចង់ឱ្យមានការយកចិត្តទុកដាក់ចំពោះបញ្ហាដីធ្លី និងការកាប់ឈើខុសច្បាប់ ព្រមទាំងមិនលើកទឹកចិត្តចំពោះការរាយការណ៍លើសាច់រឿងទាំងឡាយណាដែលអាជ្ញាធរមិនពេញចិត្ត ពីសំណាក់អ្នកសារព័ត៌មាន។

លើសពីនេះ អ្នកសារព័ត៌មានម្នាក់ដែលត្រូវបានសម្ភាសន៍បាននិយាយថា អាជ្ញាធរខណ្ឌមានជ័យបានរឹបអូសទូរស័ព្ទរបស់លោក ហើយបង្ខំឱ្យលុបរូបថតនៃជម្លោះដីធ្លីនៅសង្កាត់បឹងទំពុន។ បន្ទាប់មកពួកគេបានបញ្ជាឱ្យអ្នកសារព័ត៌មានដែលមានវត្តមានទាំងអស់នៅទីនោះឱ្យចាកចេញពីកន្លែងកើតហេតុ ហើយបានគំរាមចាត់វិធានការផ្លូវច្បាប់ទៅលើអ្នកដែលមិនធ្វើតាម។ លោកបានហៅហេតុការណ៍នេះថាជា "ការគំរាមកំហែងប្រឆាំងចំពោះអ្នកសារព័ត៌មាន"។ អ្នកសារព័ត៌មានម្នាក់ទៀតនិយាយថា លោកសង្ស័យថាលោកត្រូវបានទម្លាក់ចេញពីតួនាទីជាអនុប្រធានភូមិកាលពីឆ្នាំ២០១៨ ដោយសារតែការងាររបស់លោកពាក់ព័ន្ធករណីបញ្ហាដីធ្លី ក្នុងនាមជាអ្នកសារព័ត៌មានពលរដ្ឋ។

*<u>អំពើពុករលួយ៖</u>* ម្នាក់ក្នុងចំណោមអ្នកសារព័ត៌មានដែលត្រូវបានសម្ភាសន៍សម្រាប់របាយការណ៍នេះបាននិយាយថា អ្នកសារព័ត៌មានដែលហ៊ានផ្សព្វផ្សាយទាក់ទងបញ្ហាពុករលួយតែងតែទទួលរងការរឹតត្បិត។ អំឡុងពេលនៃរបាយការណ៍នេះ អ្នកសារព័ត៌មានម្នាក់ត្រូវបានរំខានសម្រាប់ការរាយការណ៍អំពីអំពើពុករលួយ។ ហេតុការណ៍ដែលបានពិពណ៌នាខាងក្រោមនេះ ហាក់ដូចជាបង្ហាញពីការប៉ុនប៉ងរបស់អាជ្ញាធរក្នុងការរារាំងអ្នកសារព័ត៌មានពីការសរសេរព័ត៌មានដែលអាចប៉ះពាល់ជាអវិជ្ជមានដល់ពួកគេ។

ករណីលោក **អ៊ុង ថាប់រាំង៖** នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៣ សមត្ថកិច្ចខេត្តបន្ទាយមានជ័យ បានចាប់ខ្លួនចាងហ្វាងផ្សព្វផ្សាយព័ត៌មាននៃគេហទំព័រខ្មែរជាយដែន (Khmer Cheay Den News) តាមពាក្យបណ្ដឹងរបស់មន្ត្រីមូលដ្ឋាន។ បន្ទាប់មកគាត់ត្រូវបានចោទប្រកាន់ពីបទបរិហារកេរ្តិ៍ និងញុះញង់ទាក់ទងនឹងអត្ថបទដែលបានផ្សព្វផ្សាយជាបន្តបន្ទាប់អំពីអំពើពុករលួយនៅក្នុងមន្ទីរសុខាភិបាល និងការិយាល័យពន្ធដារក្រុងប៉ោយប៉ែត ដែលលោកបានផ្សព្វផ្សាយក្នុងឆ្នាំ២០២១ និង២០២២។ លោកក៏ត្រូវបានចោទប្រកាន់ពីបទ

[64] ជ័ររេដ ហ្វ្លីន- Gerald Flynn, "អាជ្ញាបណ្ណកាប់ឈើ៖ យោធាកម្ពុជាជួយសម្រួលដល់ការកាប់ឈើនៅខេត្តកោះកុងក្រៅ និងតាមជួរភ្នំក្រវាញ"។ (Mongabay, ៦ មិថុនា ២០២៣)

ឆបោក ក្នុងសំណុំរឿងមួយផ្សេងទៀត ហើយត្រូវបានបញ្ជូនទៅឃុំខ្លួនមុនពេលសវនាការ។ លោកត្រូវបានដោះលែងនៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៣ ហើយត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ។[65]

*សកម្មភាពរបស់កងកម្លាំងសន្តិសុខ៖* អ្នកសារព័ត៌មានជាស្ត្រីម្នាក់ដែលបានសម្ភាសន៍បាននិយាយថាបានទទួលរងការយាយីជាច្រើនទម្រង់ដោយសារការផ្សព្វផ្សាយព័ត៌មាន នេះបង្ហាញថាកងកម្លាំងសន្តិសុខមិនបានយល់ច្បាស់អំពីគោលគំនិតនៃសេរីភាពសារព័ត៌មាននោះទេ៖ "*ពេលខ្លះពួកគេស្រែកដាក់យើង ទោះបីជាយើងមិនបានធ្វើអ្វីហួសពីតួនាទីរបស់យើងក៏ដោយ គឺយើងគ្រាន់តែធ្វើការងាររបស់យើងប៉ុណ្ណោះ*"។ ក្នុងអំឡុងពេលនៃរបាយការណ៍នេះ សមាជិកនៃកងកម្លាំងសន្តិសុខបានជ្រៀតជ្រែកមិនត្រឹមត្រូវទៅលើអ្នកសារព័ត៌មានដែលកំពុងធ្វើការងារស្របច្បាប់របស់ពួកគេជាច្រើនលើក ដែលនេះទំនងជាដើម្បីបញ្ចៀសការរាយការណ៍មិនល្អអំពីរបៀបដែលពួកគេចាត់ការលើស្ថានភាពជាក់លាក់ណាមួយ។ ករណីទាំង២ខាងក្រោមនេះត្រូវបានបង្ហាញជាឧទាហរណ៍។

ករណី **ព្រហ្ម ចាន់ថា៖** កាលពីថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២២ អធិការនគរបាលក្រុងបាវិត បានបញ្ជាឱ្យអ្នកសារព័ត៌មានជាច្រើននាក់ ដែលកំពុងផ្សាយផ្ទាល់នូវហេតុការណ៍គ្រោះថ្នាក់ចរាចរណ៍បញ្ឈប់ និងលុបវីដេអូឃ្លីបចោល។ នៅពេលដែលអ្នកសារព័ត៌មាននៃគេហទំព័រសារព័ត៌មានលួសសេង (Luos Seng News) លោក ព្រហ្ម ចាន់ថា បដិសេធ អាជ្ញាធរបានចាប់ទូរស័ព្ទរបស់លោក ដើម្បីលុបវីដេអូនោះដោយខ្លួនឯង ខណៈគំរាមថានឹងដាក់ខ្នោះដៃលោក។ ក្រោយមកចាងហ្វាងបោះពុម្ពផ្សព្វផ្សាយនៃសារព័ត៌មានលួសសេង បានដាក់ពាក្យបណ្តឹងពីបទគំរាមកំហែងអ្នកសារព័ត៌មានទៅកាន់តុលាការខេត្តស្វាយរៀង នៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២២។ លោកបានអះអាង ថាព្រះរាជអាជ្ញាបានព្យាយាមមិនឱ្យលោកធ្វើដូច្នេះ ហើយបានស្នើឱ្យលោក "សម្រុះសម្រួល" ជំនួសវិញ។[66]

ករណី ញឹម សនស៊ីដា៖ កាលពីថ្ងៃទី២៨ ខែមករា ឆ្នាំ២០២៣ មន្ត្រីអន្តោប្រវេសន៍នៅស្រុកលើកដែក ខេត្តកណ្តាល បានឃុំខ្លួនសមាជិកសមាគមសម្ព័ន្ធយុវជនសារព័ត៌មានដើម្បីសន្តិភាពអស់រយៈពេលជាច្រើនម៉ោង បន្ទាប់ពីលោកបានថតរូបបុគ្គលម្នាក់ដែលរត់ពន្ធបារី ហើយរាយការណ៍អំពីហេតុការណ៍នោះទៅអាជ្ញាធរ។ ទូរស័ព្ទរបស់លោកត្រូវបានរឹបអូស ហើយគាត់ត្រូវបាននាំខ្លួនទៅកាន់ប៉ុស្តិ៍ប៉ូលីសដើម្បីសាកសួរដោយសារតែលោកមិនមានលិខិតបេសកកម្ម និងមិនជូនដំណឹងដល់អាជ្ញាធរអំពីការថតរូបភាពទាំងនោះ។

---

[65] ខ្មែរថាមស៍, "ការចោទប្រកាន់ពីបទក្លែងបន្លំត្រូវបានបញ្ជាក់ចំពោះអ្នកសារព័ត៌មាន"។ (ខ្មែរថាមស៍, ១៥ កុម្ភៈ ២០២៣); នៅ វណ្ណារិន, "អ្នកបោះពុម្ពផ្សាយកាសែតប៉ូលីសខេត្តបន្ទាយមានជ័យ"។ (អាស៊ីសេរី, ១៣ កុម្ភៈ ២០២៣); ខេមបូចា, "ស្ថានភាពសារព័ត៌មាននៅកម្ពុជា៖ របាយការណ៍ត្រួតពិនិត្យប្រចាំត្រីមាស ពីខែមេសា ដល់ ខែមិថុនា ឆ្នាំ២០២៣"។ លេខផ្សាយ០៨, ទំព័រ១៨។
[66] ប៉ា សុខេង, "អ្នកសារព័ត៌មានក្នុងស្រុកដាក់ពាក្យបណ្តឹងប្រឆាំងអធិការក្រុងបាវិត"។ (វីអូឌី, ២៣ វិច្ឆិកា ២០២៣)។

លោកត្រូវបានដោះលែងឱ្យមានសេរីភាពវិញ បន្ទាប់ពីត្រូវបង្ខំចិត្តផ្តិតមេដៃសន្យាថានឹងមិនលេចធ្លាយរូបភាពទាំងនោះទៅកាន់ប្រព័ន្ធផ្សព្វផ្សាយឡើយ។[67]

*នយោបាយ និងការបោះឆ្នោតខែកក្កដា ឆ្នាំ២០២៣៖* នយោបាយគឺជាប្រធានបទដ៏រសើបមួយដែលត្រូវរាយការណ៍សម្រាប់អ្នកសារព័ត៌មាននៅកម្ពុជាចាប់តាំងពីរាជរដ្ឋាភិបាលបានចាប់ផ្តើមការបង្ក្រាបទាំងស្រុងលើប្រព័ន្ធផ្សព្វផ្សាយឯករាជ្យក្នុងឆ្នាំ២០១៧។ នេះជាការពិតមួយ ជាពិសេសនៅពេលក្នុងឆ្នាំបោះឆ្នោតដែលជាធម្មតាគេកត់សំគាល់ឃើញពីការប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាដើម្បីគ្រប់គ្រងការផ្សព្វផ្សាយ។ ដូចបានបង្ហាញនៅក្នុងករណីខាងក្រោមនេះ អ្នកសារព័ត៌មានជាច្រើនបានប្រឈមនឹងការជ្រៀតជ្រែកពីសំណាក់មន្ត្រីរដ្ឋាភិបាល ខណៈដែលពួកគេបានផ្សព្វផ្សាយពីការសម្លាប់អ្នកគាំទ្រគណបក្សជំទាស់កាលពីចុងឆ្នាំ២០២២។ អ្នកសារព័ត៌មានម្នាក់ត្រូវបានគេចាត់វិធានការផ្លូវច្បាប់ភ្លាមៗបន្ទាប់ពីការបោះឆ្នោត ទាក់ទងនឹងការអត្ថាធិប្បាយអំពីការបោះឆ្នោតលើប្រព័ន្ធអនឡាញ។

**ការឃ្លាំមើល៖** នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២២ បុគ្គលម្នាក់ដែលគេជឿថាជាមន្ត្រីប៉ូលីសនៅស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ ពាក់ឯកសណ្ឋានស៊ីវិល បានស្នើសុំឈ្មោះអ្នកសារព័ត៌មានរបស់វិទ្យុសំឡេងប្រជាធិបតេយ្យ (VOD) ដែលកំពុងសម្ភាសប្រពន្ធរបស់អ្នកគាំទ្រគណបក្សភ្លើងទៀនដែលត្រូវបានបាញ់សម្លាប់កាលពីប៉ុន្មានថ្ងៃមុន។ បុគ្គលដែលសង្ស័យនេះក៏បានឃ្លាំមើលការសម្ភាសរហូតដល់ចប់។[68]

**វិធានការផ្លូវច្បាប់៖** នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២៣ ប៉ូលីសខេត្តកំពង់ស្ពឺ បានឃុំខ្លួនអ្នកសារព័ត៌មាន និងសហការីនៃគេហទំព័រអ្នកមើលផ្លូវម្នាក់ (Nak Merl Phlov) ឈ្មោះ ស្វាយ សូផាត ទាក់ទងនឹងការអត្ថាធិប្បាយទាក់ទងនឹងការបោះឆ្នោតជាតិខែកក្កដា ឆ្នាំ២០២៣។ នៅក្នុងការផ្សាយផ្ទាល់តាមបណ្តាញសង្គមហ្វេសប៊ុក (Facebook) មុនពេលការចាប់ខ្លួន លោក ស្វាយ សូផាត បានចោទជាសំណួរអំពីឆន្ទៈរបស់ព្រះមហាក្សត្រក្នុងការឡាយព្រះហស្តលេខាលើលិខិតអំពាវនាវឱ្យពលរដ្ឋចេញទៅបោះឆ្នោត និងភាពស្ទាក់ស្ទើររបស់ទ្រង់ ក្នុងការគាំទ្រឱ្យមានការកាត់ទោសប្រហារជីវិតចំពោះឧក្រិដ្ឋជនដែលត្រូវបានកាត់ទោស។ បន្ទាប់មក លោកត្រូវបានចោទប្រកាន់ពីបទប្រមាថចំពោះអង្គព្រះមហាក្សត្រ តាមមាត្រា ៤៣៧ (ស្ទួន) នៃក្រមព្រហ្មទណ្ឌ ហើយត្រូវបានបញ្ជូនទៅឃុំខ្លួនមុនការកាត់ទោស។[69]

---

[67] វ៉ា សូផានុត, "អ្នកសារព័ត៌មានចោទប្រកាន់ប៉ូលីសអន្តោប្រវេសន៍ព្រំដែនថាបានចាប់ខ្លួនគាត់ដើម្បីសាកសួរបន្ទាប់ពីបានថតរូបអ្នកទោសពន្ធក្នុងច្រករបៀង"។ (វីអូឌី, ៩ កុម្ភៈ ២០២៣); គេហទំព័រកងមាស, "ប៉ូលិសអន្តោប្រវេសន៍ឃាត់អ្នកសារព័ត៌មាន បង្ខំឱ្យផ្តិតមេដៃទាំងបំពាន នៅស្រុកលើកដែក សូមថ្នាក់ដឹកនាំជួយពិចារណាផង"។ (គេហទំព័រកងមាស, ២៩ មករា ២០២៣)។

[68] អាស៊ីសេរី, "អ្នកគាំទ្របក្សប្រឆាំងនៅកម្ពុជាត្រូវបានបាញ់សម្លាប់ ចំពេល លោក ហ៊ុន សែន គំរាមចាប់អ្នកប្រឆាំងដាក់ពន្ធនាគារ"។ (អាស៊ីសេរី, ១៧ តុលា ២០២៣); ម៉ិច ដារ៉ា និងមីឆែល ឌីគ្គីស័ន (Michael Dickinson), "ប៉ូលីសបានចោទប្រកាន់ពីបទបាញ់ប្រហារកសិករ ខណៈសំណួរពាក់ព័ន្ធនឹងបញ្ហានយោបាយកើតឡើង"។ (វីអូឌី, ១៩ តុលា ២០២២)។

[69] គីម យុត្តាវ៉ូ, "អ្នកសារព័ត៌មានខេត្តកំពង់ស្ពឺត្រូវបានឃុំខ្លួនពីបទប្រមាថព្រះមហាក្សត្រ"។ (ភ្នំពេញប៉ុស្តិ៍, ២៥ កក្កដា ២០២៣)។

នៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២២ អគ្គលេខាធិការរង នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ("គ.ជ.ប") បាននិយាយថា អ្នកសារព័ត៌មានពលរដ្ឋនឹងត្រូវហាមឃាត់ក្នុងការចុះផ្សាយពីដំណើរការបោះឆ្នោត ព្រោះ *"គ្មានច្បាប់អនុញ្ញាតឱ្យធ្វើដូច្នេះទេ"*។ លោកបន្ថែមថា អ្នកសារព័ត៌មានអាជីពដែលចុះផ្សាយអំពីការបោះឆ្នោត *"ត្រូវតែអព្យាក្រិត្យ រាយការណ៍ត្រឹមត្រូវ និងយុត្តិធម៌ ហើយមិនត្រូវបំផ្លើសព័ត៌មាន ឬធ្វើអត្ថាធិប្បាយលម្អៀងណាមួយលើលទ្ធផលដែលបានប្រកាសដោយ គ.ជ.ប"* នោះទេ។[70] នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៣ គ.ជ.ប បានប្រកាសអំពីពេលវេលា និងលក្ខខណ្ឌតម្រូវសម្រាប់អ្នកសារព័ត៌មានក្នុងស្រុក និងអន្តរជាតិដើម្បីចុះឈ្មោះស្នើសុំប័ណ្ណសារព័ត៌មានពិសេសដើម្បីអាចយកព័ត៌មានអំពីការបោះឆ្នោត នៅថ្ងៃទី២៣ ខែកក្កដា បាន។[71] នៅដើមខែមិថុនា ឆ្នាំ២០២៣ អ្នកនាំពាក្យ គ.ជ.ប លោក ហង្ស ពុទ្ធា បានបញ្ជាក់ជាថ្មីថា អ្នកសារព័ត៌មានដែលមានការទទួលស្គាល់ត្រូវតែអនុវត្តតាមគោលការណ៍ណែនាំរបស់ គ.ជ.ប យ៉ាងម៉ឺងម៉ាត់ ដូចដែលបានបញ្ជាក់ក្នុងសិក្ខាសាលាមួយដែលមានអ្នកសារព័ត៌មានចូលរួមប្រមាណ ៣០នាក់ មកពីស្ថាប័នសារព័ត៌មាននានា។[72] នៅក្នុងបរិយាកាសដែលគ្រប់គ្រងយ៉ាងតឹងរ៉ឹងបែបនេះ អ្នកសារព័ត៌មានជាច្រើនបានប្រឈមមុខនឹងការរឹតបន្តឹងខណៈពេលដែលព្យាយាមចុះយកព័ត៌មាននៅថ្ងៃបោះឆ្នោតដូចដែលបានបង្ហាញនៅខាងក្រោម។

**ករណីក្នុងរាជធានីភ្នំពេញ៖** នៅព្រឹកថ្ងៃបោះឆ្នោត អ្នកថតរូប និងផលិតវីដេអូមួយក្រុម ត្រូវបានហាមឃាត់មិនឱ្យចូលការិយាល័យបោះឆ្នោត នៅវត្តវាលស្បូវ ដើម្បីថតរូបព្រះអង្គម្ចាស់ នរោត្តម ចក្រាវុធ ប្រធានគណបក្សហ៊្វុនស៊ិនប៉ិច ខណៈដែលទ្រង់ត្រៀមនឹងចូលបោះឆ្នោត។ អ្នកទាំងនោះសុទ្ធតែមានប័ណ្ណព័ត៌មានពិសេសរបស់ គ.ជ.ប។ ក្រោយថ្ងៃនោះមក អង្គរក្សម្នាក់របស់ព្រះអង្គម្ចាស់ ចក្រាវុធ ត្រូវបានរាយការណ៍ថាបានគំរាមបោះចោលទូរស័ព្ទដៃរបស់អ្នកផលិតវីដេអូនៃសារព័ត៌មានខេមបូចា លោក អ៊ួន ឈិន ដោយចោទប្រកាន់ថាបានប៉ះពាល់ព្រះអង្គម្ចាស់ពេលកំពុងថតរូប។[73]

ក្នុងហេតុការណ៍ដាច់ដោយឡែកមួយទៀត អ្នកសារព័ត៌មាននៃសំឡេងសហរដ្ឋអាមេរិក (VOA) លោក ស៊ុន ណារិន ត្រូវបានហាមក្នុងការសម្ភាសអ្នកបោះឆ្នោត នៅឯការិយាល័យបោះឆ្នោតផ្សារថ្មី២ បើទោះជាលោកមានប័ណ្ណព័ត៌មានពិសេសចេញដោយ គ.ជ.ប ក៏ដោយ។ មន្ត្រីបោះឆ្នោតម្នាក់ដំបូងហាមគាត់ក្នុងការថតរូប ប៉ុន្តែក្រោយមកក៏អនុញ្ញាតវិញ។ ស្រដៀងគ្នានេះដែរ មន្ត្រីរៀបចំការបោះឆ្នោតនៅការិយាល័យបោះឆ្នោតពីរផ្សេងទៀតក៏បានប្រាប់និពន្ធនាយករងនៃខេមបូចា លោកស្រី LEILA GOLDSTEIN ថាគាត់មិនអាចចូលទៅក្នុងបរិវេណការិយាល័យបោះឆ្នោត ឬថតរូបបាននោះទេ។[74]

---

[70] ប៊ិន សុខហ៊ាន, "ការរៀបចំការផ្សាយព័ត៌មានអំពីការបោះឆ្នោត"។ (ខ្មែរថាមស៍, ២៩ ធ្នូ ២០២២)។

[71] តាំង រិននីត, "គ.ជ.ប កំណត់លក្ខណៈសម្រាប់ការយកព័ត៌មានអំពីការបោះឆ្នោតជាតិ"។ (ខ្មែរថាមស៍, ១៤ កុម្ភៈ ២០២៣)។

[72] ថន វិបុល, "អ្នកជំនាញ អ្នកសារព័ត៌មានចូលរួមសិក្ខាសាលាស្តីពីការផ្សាយព័ត៌មានអំពីការបោះឆ្នោត"។ (ខ្មែរថាមស៍, ៨ មិថុនា ២០២៣)។

[73] ខេមបូចា, "ស្ថានភាពសារព័ត៌មាននៅកម្ពុជា៖ របាយការណ៍ត្រួតពិនិត្យប្រចាំត្រីមាស ពីខែកក្កដា ដល់ ខែកញ្ញា ឆ្នាំ២០២៣"។ លេខផ្សាយ០៩, ទំព័រ១៨។

[74] ដូចខាងលើ, ទំព័រ១៩។

**ករណីក្នុងខេត្តកណ្ដាល៖** ប្រធានការិយាល័យបោះឆ្នោតនៅអនុវិទ្យាល័យតាឡូន បានសាកសួរអ្នកសារព័ត៌មានខេមបូចា កញ្ញា សុវណ្ណ ស្រីពេជ្រ និងអ្នកសារព័ត៌មាននៃសំឡេងសហរដ្ឋអាមេរិក (VOA) ពីរនាក់ផ្សេងទៀតខណៈដែលពួកគេកំពុងសម្ភាសន៍អនុប្រធានគណបក្សភ្លើងទៀន លោក រ៉ុង ឈុន។ មន្ត្រីរូបនោះបានសួរអ្នកទាំងបីថាពួកគេមកពីណា មុននឹងថតរូបពួកគេ ទៅតាមការទាមទាររបស់ប៉ូលិសក្នុងតំបន់នោះ។[75]

*ការដាក់កំហិតខ្លួនឯង*




យោងតាមហេតុការណ៍ដូចបានគូសបញ្ជាក់នៅក្នុងផ្នែកនេះបង្ហាញថា អ្នកសារព័ត៌មានមិនមានសេរីភាពទៀតទេក្នុងការប្រមូលព័ត៌មាន និងរាយការណ៍អំពីបញ្ហាដែលរដ្ឋាភិបាលកំណត់ថាមានលក្ខណៈរសើប។ ជាលទ្ធផលនៃការបំភិតបំភ័យ ការគំរាមកំហែង និងការដាក់ទណ្ឌកម្មព្រហ្មទណ្ឌ ដែលអ្នកសារព័ត៌មានត្រូវទទួលរងដោយគ្រាន់តែបំពេញការងាររបស់ខ្លួន អ្នកជំនាញផ្នែកប្រព័ន្ធផ្សព្វផ្សាយជាច្រើនបានដាក់កំហិតខ្លួនឯង និងជៀសវាងការផ្សាយព័ត៌មានដែលអាចធ្វើឱ្យក្រុមឥស្សរជនដែលកំពុងកាន់អំណាចខឹងសម្បារ។ ក្នុងចំណោមអ្នកសារព័ត៌មានជាបុរសចំនួន ០៦ នាក់ដែលបានផ្តល់សម្ភាសន៍សម្រាប់របាយការណ៍នេះ មាន០៣ នាក់រាយការណ៍ថា បានដាក់កំហិតខ្លួនឯង ឬកំពុងកំហិតខ្លួនឯង។ ជាការកត់សម្គាល់ អ្នកសារព័ត៌មានម្នាក់ក្នុងចំណោមអ្នកសារព័ត៌មានដែលផ្តល់សម្ភាសន៍ បានលើកឡើងថា ខ្លួនបានបញ្ឈប់ការសរសេរអត្ថបទអំពីបញ្ហានយោបាយមុនការបោះឆ្នោត នៅខែកក្កដា ឆ្នាំ២០២៣ ដោយសារតែបារម្ភអំពីសុវត្ថិភាពផ្ទាល់ខ្លួន។ អ្នកសារព័ត៌មានម្នាក់ទៀតក៏បានលើកឡើងថា ខ្លួននឹងមិនចេញផ្សាយអត្ថបទលើប្រធានបទណាមួយដែលអាជ្ញាធរកំណត់ថាមានលក្ខណៈរសើបឡើយ ដោយបានលើកឡើងអំពីការភិតភ័យចំពោះសុវត្ថិភាពផ្ទាល់ខ្លួន និងក្រុមគ្រួសារ។ អ្នកសារព័ត៌មានដែលបានសម្ភាសន៍ផ្សេងទៀតបានបញ្ជាក់ថា ជាទូទៅខ្លួនអាចនឹងបដិសេធក្នុងការសរសេរប្រធានបទដែលមានលក្ខណៈរសើបទាំងឡាយដែលទាក់ទងនឹងអំពើពុករលួយ បញ្ហាដីធ្លី ការតវ៉ា និងបញ្ហានយោបាយ។

---

[75] ដូចខាងលើ, ទំព័រ២០។

ការដាក់កំហិតខ្លួនឯង ក៏បានពង្រីកឥទ្ធិពលដល់សាធារណជន ដែលបង្កឱ្យមានការលំបាកដល់អ្នកសារព័ត៌មានដើម្បីប្រមូលព័ត៌មានទាំងឡាយដែលទាក់ទងនឹងប្រធានបទមានលក្ខណៈរសើបផងដែរ។ អ្នកសារព័ត៌មានបានបង្ហើបអំពីករណីជាក់ស្តែងមួយដោយប្រជាពលរដ្ឋមានភាពភ័យខ្លាចថា នឹងមានការគំរាមកំហែងពីសំណាក់អាជ្ញាធរ ប្រសិនបើពួកគេហ៊ានផ្តល់បទសម្ភាសន៍ដល់អ្នកសារព័ត៌មាន។ ម្នាក់ក្នុងចំណោមអ្នកសារព័ត៌មានពលរដ្ឋជាស្ត្រីពីនាក់បានលើកឡើងថា សមាជិកសហគមន៍មានការភ័យខ្លាចខ្លាំងក្នុងការសំដែងមតិរបស់ខ្លួន បើទោះជាពួកគេមើលឃើញ "រឿងអាក្រក់" កើតឡើងក៏ដោយ។ ស្រដៀងគ្នាទៅនឹងការផ្តល់បទសម្ភាសន៍របស់អ្នកសារព័ត៌មានជាស្ត្រីម្នាក់ទៀតដែលបានកត់សម្គាល់ថា មនុស្សមួយចំនួនបានបដិសេធក្នុងការផ្តល់បទសម្ភាសន៍ទាក់ទងនឹងប្រធានបទនយោបាយ ព្រោះពួកគេគិតភ័យចំពោះការប្រឈមនឹងការចោទប្រកាន់ផ្លូវច្បាប់ ឬការចាប់ខ្លួនដោយសារបង្ហាញពីទស្សនៈរបស់ខ្លួន។

*ការវាយប្រហារ និងការគំរាមកំហែងដោយប្រើហិង្សាលើរាងកាយរបស់អ្នកសារព័ត៌មាន*

ដោយមានតួនាទីជាអ្នកឃ្លាំមើល និងរាយការណ៍ អ្នកសារព័ត៌មានទូទាំងពិភពលោកតែងប្រឈមនឹងការវាយប្រហារ និងការគំរាមកំហែងដល់សុវត្ថិភាពរាងកាយ។ អ្នកសារព័ត៌មានបុរសពីរនាក់ក្នុងចំណោមក្រុមអ្នកសារព័ត៌មានដែលបានផ្តល់សម្ភាសន៍សម្រាប់របាយការណ៍នេះបានលើកឡើងថា ពួកគេមានការព្រួយបារម្ភអំពីសុវត្ថិភាពផ្ទាល់ខ្លួន ឬក្រុមគ្រួសារ ដោយសារតែការបំពេញការងាររបស់ខ្លួន។ អ្នកសារព័ត៌មានម្នាក់បានបញ្ជាក់ថា អាជ្ញាធរមូលដ្ឋានបានគំរាមកំហែង រូបលោកផ្ទាល់ និងក្រុមគ្រួសារ ពាក់ព័ន្ធនឹងការចេញផ្សាយអត្ថបទ។ លោកកត់សម្គាល់ថា អ្នកដែលរិះគន់រដ្ឋាភិបាលត្រូវបានបំពានធ្វើបាបជាញឹកញាប់។ អ្នកសារព័ត៌មានជាបុរសម្នាក់ក៏បានបញ្ជាក់ដែរថា គាត់មិនអាចធ្វើការបំពេញការងារ និងរាយការណ៍ដោយសេរីបានទេ ដោយសារតែមានការគាបសង្កត់ជាបន្តបន្ទាប់។ ដូច្នេះលោកបានជ្រើសរើសការនៅស្ងៀមស្ងាត់និងបញ្ឈប់ការផ្សាយអត្ថបទបន្តទៀត។

របាយការណ៍ឃ្លាំមើលរបស់ ម.ស.ម.ក បានបង្ហាញថាការវាយប្រហាររូបរាងកាយ និងការគំរាមកំហែងប្រឆាំងនឹងអ្នកធ្វើការក្នុងវិស័យសារព័ត៌មាន គឺនៅតែបន្តកើតមានឡើង។ តាមសេចក្តីរាយការណ៍នៅថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២៣ មានជនមិនស្គាល់អត្តសញ្ញាណពីរនាក់ប្រដាប់ដោយដាវ បានវាយប្រហារបង្កជារបួសស្នាមដល់អ្នកសារព័ត៌មាននៃគេហទំព័រដំណឹងក្នុងស្រុកម្នាក់ឈ្មោះ ជុំ សុត្រា នៅទីតាំងផ្ទះរបស់លោក នៅសង្កាត់ទួលតាឯក ក្រុងបាត់ដំបង។ ប្រហែលពីរសប្តាហ៍មុនពេលកើតហេតុ លោកបានស្នើសុំប៉ូលីសនៅមូលដ្ឋានបង្ក្រាបបទល្មើសជួញដូរគ្រឿងញៀនក្នុងតំបន់ស្ថានីយរថភ្លើង។ នៅថ្ងៃបន្ទាប់ លោកបានដាក់ពាក្យបណ្តឹងទៅកាន់ប៉ូលីសខេត្ត។[76]

នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៣ ចាងហ្វាងផ្សាយព័ត៌មានដែលមានអាជ្ញាបណ្ណ និងអ្នកអត្ថាធិប្បាយតាមប្រព័ន្ធផ្សព្វផ្សាយសង្គម លោក ផែង វណ្ណៈ បានផ្ញើសារគំរាមសម្លាប់តាមរយៈសារអេឡិចត្រូនិច (Messenger) ទៅកាន់អ្នកសារព័ត៌មានជនជាតិខ្មែរម្នាក់របស់ឌឹខេមបូឌៀឌេលី (The Cambodia Daily) ដែល

---

[76] ឆោម ពិសី, "អ្នកកាសែតម្នាក់ត្រូវជនអនុវត្តពលកាប់របួសក្រោយរាយការណ៍បង្ក្រាបគ្រឿងញៀន"។ (កោះសន្តិភាព, ០៣ កុម្ភៈ ២០២៣)។

មានទីស្នាក់ការនៅសហរដ្ឋអាមេរិក គឺលោក តាំង សារ៉ាដា ដែលតែងតែចាក់ផ្សាយកម្មវិធីឈ្មោះ អាយឌៀថក (Idea Talk) ដែលជាកម្មវិធីជជែកពិភាក្សាជាភាសាខ្មែរដែលមានវត្តមានរបស់សកម្មជនការពារសិទ្ធិមនុស្ស និងសកម្មជនបក្សជំទាស់ធ្វើជាវាគ្មិន។ នៅថ្ងៃបន្ទាប់ មានជនចម្លែកមុខម្នាក់ត្រូវបានរាយការណ៍ថាបានគោះទ្វារផ្ទះរបស់ លោក សារ៉ាដា ហើយមានរថយន្តពណ៌ខ្មៅមួយនៅចតខាងក្រៅផ្ទះរបស់លោកជាច្រើនម៉ោង។ កាលពីថ្ងៃទី២២ ខែមិថុនា លោក ផៃង វណ្ណៈ បានចេញវីដេអូគំរាមកំហែងស្រដៀងគ្នានេះក្នុងពេលផ្សាយបន្តផ្ទាល់លើទំព័រហ្វេសប៊ុកសាធារណៈរបស់លោក។ វីដេអូនេះត្រូវបានលុបចេញដោយក្រុមហ៊ុនមេតា (Meta) ដោយសារបានបំពានគោលការណ៍របស់ក្រុមហ៊ុនក្នុងការប្រឆាំងនឹងអំពើហិង្សា និងការញុះញង់។ លោក តាំង សារ៉ាដា បានជំរុញឱ្យអាជ្ញាធរកម្ពុជាចាត់វិធានការលើលោក ផៃង វណ្ណៈ ចំពោះការគំរាមកំហែងតាមមធ្យោបាយផ្សព្វផ្សាយជាសាធារណៈ និងឯកជនផ្ទាល់ខ្លួន ប៉ុន្តែហាក់មិនបានផលនោះទេ។[77] បើយោងតាមគេហទំព័រសារព័ត៌មានខេមបូចាដែលបានចុះផ្សាយអំពីករណីនេះ លោក តាំង សារ៉ាដា ធ្លាប់បានរិះគន់នាយករដ្ឋមន្ត្រី ហ៊ុន សែន និងក្រុមគ្រួសាររបស់លោក នៅក្នុងកម្មវិធីអាយឌៀថកមុនពេលទទួលបានការគំរាមសម្លាប់នេះ។[78]

### *បញ្ហាប្រឈមរបស់អ្នកសារព័ត៌មានជាស្ត្រី*

អ្នកសារព័ត៌មានជាស្ត្រីពីរនាក់ដែលផ្តល់សម្ភាសន៍ក្នុងរបាយការណ៍នេះបានបញ្ជាក់ថា ពួកគេមានការប្រឈមនឹងការរើសអើង និងការលំបាកក្នុងការអនុវត្តការងារជាអ្នកសារព័ត៌មានដោយសារតែយេនឌ័រ និងជាតិពន្ធុរបស់ខ្លួន។ អ្នកសារព័ត៌មានជាបុរសបីនាក់ផ្សេងទៀត ក៏បានយល់ស្របផងដែរថា សហការីជាស្ត្រីរបស់ខ្លួនប្រឈមនឹងហានិភ័យខ្ពស់នៃការបៀតបៀន ឬការរំលោភបំពាន ជាពិសេសពេលធ្វើដំណើរផ្លូវឆ្ងាយតែម្នាក់ឯង ឬអំឡុងពេលយប់ដើម្បីទៅយកព័ត៌មាន។ អ្នកសារព័ត៌មានជាស្ត្រីម្នាក់ក្នុងចំណោមអ្នកសារព័ត៌មានជាស្ត្រីមួយចំនួន បានបង្ហាញសម្ពាធពីសំណាក់គ្រួសារដែលធ្វើឱ្យពួកគេលាឈប់ពីការងារជាអ្នកសារព័ត៌មានរបស់ខ្លួន នេះជាមូលហេតុដែលនាំឱ្យពួកគេលាក់បាំងមុខរបរជាអ្នកសារព័ត៌មានពីក្រុមគ្រួសារ និងសាច់ញាតិរបស់ខ្លួន។ អ្នកផ្សេងទៀតបានលើកឡើងថាអ្នកសារព័ត៌មានជាស្ត្រីប្រឈមនឹងការលំបាកច្រើនជាងបុរស ដោយសារស្ត្រីមាន "ភាពទន់ខ្សោយជាងបុរស" ដែលនេះបានបង្ហាញពីផ្នត់គំនិត និងឥរិយាបថយេនឌ័រក្នុងសង្គមនៅតែបន្តមានសូម្បីក្នុងចំណោមក្រុមការងាររបស់ពួកគេ ដែលអ្នកសារព័ត៌មានជាស្ត្រីត្រូវបានទទួលស្គាល់សមភាពស្មើគ្នាដូចអ្នកសារព័ត៌មានជាបុរស។

ទោះបីជាមិនមានភាពជាក់លាក់ណាមួយទាក់ទងនឹងវិស័យសារព័ត៌មាន ប៉ុន្តែការគំរាមកំហែងនៃការបៀតបៀនផ្លូវភេទនិងអំពើហឹង្សាផ្អែកលើយេនឌ័រ ហាក់បីដូចជាបានរារាំងអ្នកសារព័ត៌មានជាស្ត្រី ក្នុងការបំពេញការងារស៊ើបអង្កេត និងការប្រមូលព័ត៌មានដែលជាភាពចាំបាច់ក្នុងការបំពេញការងាររបស់ខ្លួន។ ជាឧទាហរណ៍

[77] ហៃល កំសាន្ត និង អៃ ស៊ី, "អ្នកផ្សាយព័ត៌មានដែលមានអាជ្ញាបណ្ណគំរាមសម្លាប់អ្នកកាសែតជឺខេមបូឌារដៀលីនៅលើគេហទំព័រហ្វេសប៊ុក"។ (ខេមបូចា, ២៦ មិថុនា ២០២៣)។

[78] ខេមបូចា, "ស្ថានភាពសារព័ត៌មាននៅកម្ពុជា៖ របាយការណ៍ត្រួតពិនិត្យប្រចាំត្រីមាស ពីខែមេសា ដល់ ខែមិថុនា ឆ្នាំ២០២៣"។ លេខផ្សាយ០៨,ទំព័រ៧។

អ្នកសារព័ត៌មានជាស្ត្រីម្នាក់ ក្នុងចំណោមអ្នកសារព័ត៌មានជាស្ត្រីផ្សេងទៀតដែលបានផ្តល់បទសម្ភាសន៍អំឡុងពេលនៃរបាយការណ៍នេះ បានលើកឡើងថា គាត់បានទទួលការគំរាមកំហែងពីសំណាក់អាជ្ញាធរមូលដ្ឋាន រួមទាំងអំពើហិង្សាផ្លូវភេទ ដែលធ្វើឱ្យគាត់មិនអាចបំភ្លេចបាន។ អ្នកសារព័ត៌មានជាស្ត្រីម្នាក់ទៀត បានបង្ហាញភាពសោកស្តាយថា មនុស្សមួយចំនួនដែលគាត់បានជួបអំឡុងពេលចុះប្រមូលព័ត៌មាន បានលែបខាយគាត់ ឬប្រើពាក្យសម្តីមិនសមរម្យផ្សេងៗ។ អ្នកសារព័ត៌មានជាស្ត្រីដែលផ្តល់សម្ភាសន៍ចុងក្រោយ បានលើកឡើងថា គ្រប់ពេលដែលនាងចុះបេសកកម្ម ដើម្បីប្រមូលព័ត៌មាន នាងអាចមានអារម្មណ៍សុវត្ថិភាពនៅពេលគាត់បានចុះទៅជាមួយអ្នកផ្សេងទៀត។




អំឡុងពេលនៃរបាយការណ៍ អ្នកសារព័ត៌មានជាស្ត្រីរបស់វីអូឌី (VOD) ម្នាក់បានក្លាយជាប្រធានបទនៃការបៀតបៀនតាមប្រព័ន្ធអនឡាញ។ ករណីមួយដែលគួរកត់សម្គាល់បំផុតនោះគឺកាលពីថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ ២០២៣ លោក ផែង វណ្ណៈ បានជេរប្រមាថមាក់ងាយគាត់នៅលើទំព័រហ្វេសប៊ុករបស់លោក ដោយថានាងមានចរិតថោកទាប ហើយបើអ្នកណារៀបការជាមួយនាងគឺចប់ហើយ។[79] នៅក្នុងលិខិតមួយ នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ ២០២៣ អង្គការសង្គមស៊ីវិលចំនួន ៤០ ស្ថាប័ន បានអំពាវនាវទៅកាន់ក្រសួងពាក់ព័ន្ធទាំងឡាយ ឱ្យចាត់វិធានការជាបន្ទាន់លើលោក ផែង វណ្ណៈ ដោយឱ្យធ្វើការចេញមុខមកសុំទោសជាសាធារណៈចំពោះការសំដែងមតិអសីលធម៌របស់លោក និងរៀនសូត្រអំពីការរាយការណ៍ព័ត៌មានត្រឹមត្រូវអំពីយេនឌ័រ។[80] លោក ផែង វណ្ណៈ បានប្រតិកម្មឆ្លើយតបថាខ្លួនមិនមានហេតុផលចាំបាច់ណាមួយក្នុងការសុំទោសឡើយ[81]។ ក្រសួងមហាផ្ទៃបានស្នើលោក ផែង វណ្ណៈ ឱ្យលុបសារនោះចេញ និងបានណែនាំឱ្យលោកមានការប្រុងប្រយ័ត្នចំពោះការប្រើប្រាស់ភាសាពាក្យពេចន៍លើបណ្តាញសង្គម។ ប៉ុន្តែត្រឹមការណែនាំបែបនេះ មិនមែនជាអន្តរាគមន៍ពិតប្រាកដទេ ព្រោះការបញ្ចេញមតិផ្សេងៗនៅតែបន្តមានលើគេហទំព័រហ្វេសបុករបស់លោក។[82] នៅថ្ងៃទី១៦ ខែកុម្ភៈ លោក ផែង វណ្ណៈ ទទួលស្គាល់ថាបានប្រើប្រាស់ពាក្យអសុរោះដោយមាក់ងាយពិតមែន ប៉ុន្តែគ្រាន់តែជាការអនុវត្តសិទ្ធិខាងការបញ្ចេញមតិយោបល់របស់ខ្លួនក្នុងនាមជាពលរដ្ឋប៉ុណ្ណោះ។[83]

---

[79] តាំង វ៉ាលីវ៉ូហ្ស៊ី, "ការសំដែងមតិដោយប្រើពាក្យសម្តីប្រមាថលើអ្នកសារព័ត៌មានវីអូឌី"។ (ខេមបូឌៀនេស៍, ១៥ កុម្ភៈ ២០២៣)។

[80] ខេមបូចា, "ការចេញលិខិតចំហចំពោះលោកជំទាវ អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ឯកឧត្តម ខៀវ កាញារីទ្ធ រដ្ឋមន្ត្រីក្រសួងព័ត៌មាន លោកជំទាវ ភឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ឯកឧត្តម ជា វ៉ាន់ដេត រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍"។ (សិទ្ធិ, ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៣)។

[81] តាំង វ៉ាលីវ៉ូហ្ស៊ី, "បញ្ចេញមតិជាមួយពាក្យសម្តីប្រមាថលើអ្នកសារព័ត៌មានវីអូឌី"។ (ខេមបូឌៀនេស៍, ១៥ កុម្ភៈ ២០២៣)។

[82] តាំង វ៉ាលីវ៉ូហ្ស៊ី, "ក្រសួងមានអំណាចតិចតួចក្នុងការចាត់ការករណីយាយីតាមអនឡាញវីអូឌី"។ (ខេមបូឌៀនេស៍, ១៦ កុម្ភៈ ២០២៣)។

[83] តាំង វ៉ាលីវ៉ូហ្ស៊ី, "ផែង វណ្ណៈទម្លាយជាមួយអ្នករិះគន់រឿងពាក្យបណ្តឹង" (ខេមបូឌៀនេស៍, ១៧ កុម្ភៈ ២០២៣)

ក្រសួងកិច្ចការនារី បានឆ្លើយតបតាមរយៈសេចក្ដីថ្លែងការណ៍មួយដោយបង្ហាញថាក្រសួងមានការសោកស្ដាយ និងបានបញ្ជាក់ថា ក្រសួងមិនគាំទ្រ "រាល់ភាសាទាំងឡាយណាដែលប្រកបដោយហិង្សា និងអសីលធម៌ ដែលប៉ះពាល់ដល់តម្លៃ និងសេចក្ដីថ្លៃថ្នូររបស់ស្ត្រីទេ"។ ការអំពាវនាវហៅភាគីដែលពាក់ព័ន្ធទាំងអស់ឱ្យចូលរួមស្វែងរកដំណោះស្រាយ ដោយសន្តិវិធីក៏ត្រូវបានធ្វើឡើងផងដែរ។[84] ប៉ុន្តែទោះជាយ៉ាងណា នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៣ នាយករដ្ឋមន្ត្រី ហ៊ុន សែន បានចោទប្រកាន់ចំពោះអង្គការសង្គមស៊ីវិលដែលបានចូលរួមចុះហត្ថលេខាក្នុងលិខិតចំហថា បានអនុវត្តស្តង់ដាពីរផ្សេងគ្នា និងខកខានក្នុងការដាក់ទណ្ឌកម្មទៅលើអតីតមេដឹកនាំគណបក្សជំទាស់គឺ លោក សម រង្ស៊ី ដែលបានប្រមាថមើលងាយប្រពន្ធ និងគ្រួសាររបស់លោក។[85] អង្គការទាំងអស់នោះគ្រាន់តែបង្កើតឡើងក្នុងគោលបំណង ដើម្បីប្រឆាំងនឹងរាជរដ្ឋាភិបាលប៉ុណ្ណោះ និងមិនបានធ្វើអ្វីដើម្បីការពារសមភាពរបស់ស្ត្រីឡើយ។ លោកបានបន្ថែមជាមួយពាក្យសម្ដីព្រមានថា លោកអាចបង្គាប់ឱ្យមានការស៊ើបអង្កេតអំពីហិរញ្ញវត្ថុរបស់ស្ថាប័នទាំងនោះបាន។[86] ប៉ុន្មានថ្ងៃបន្ទាប់ ក្រសួងកិច្ចការនារី បានចេញសេចក្ដីថ្លែងការណ៍ទីពីរ ដោយបានបញ្ជាក់ថា ទោះជាយ៉ាងណាក្ដី រាល់ការវាយប្រហារប្រឆាំងឯកជនភាពបុគ្គលរបស់ស្ត្រី គឺមិនត្រឹមត្រូវនោះទេ ទោះស្ថិតក្នុងកាលៈទេសៈណាក៏ដោយ ហើយការជ្រើសរើសដាក់ទណ្ឌកម្មលើនរណាម្នាក់ដើម្បីបំរើផលប្រយោជន៍នយោបាយ បានបង្ហាញពីការខ្វះក្រមសីលធម៌។[87]

## ៤.២ ស្ថានភាពនៃសេរីភាពខាងការបញ្ចេញមតិរបស់អ្នកការពារសិទ្ធិមនុស្ស

### *ការយាយីតាមប្រព័ន្ធតុលាការចំពោះអ្នកការពារសិទ្ធិមនុស្ស សម្រាប់ការអនុវត្តសិទ្ធិសេរីភាពខាងការបញ្ចេញមតិ*

ក្រៅពីអ្នកសារព័ត៌មាន ក្រុមអ្នកការពារសិទ្ធិមនុស្សនៅតែបន្តទទួលរងនូវការមិនអត់ឱនពីសំណាក់រដ្ឋាភិបាលចំពោះការរិះគន់ និងការមានទស្សនៈផ្ទុយ នៅចន្លោះខែកញ្ញា ឆ្នាំ២០២២ ដល់ខែសីហា ឆ្នាំ២០២៣ ហើយត្រូវបានដៅមុខសញ្ញាសម្រាប់ការអនុវត្តសិទ្ធិសេរីភាពខាងការបញ្ចេញមតិ ដែលជាផ្នែកមួយនៃការធ្វើការងារសិទ្ធិមនុស្សស្របច្បាប់របស់ពួកគេ។ ការយាយីតាមប្រព័ន្ធតុលាការពីសំណាក់តុលាការ នៅតែជាការគំរាមកំហែងដ៏ធំបំផុតចំពោះសេរីភាពខាងការបញ្ចេញមតិរបស់ក្រុមអ្នកការពារសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា នេះបើតាមការដកស្រង់សម្ដីរបស់អ្នកការពារសិទ្ធិមនុស្សដែលបានសម្ភាសន៍សម្រាប់របាយការណ៍នេះ។ ដោយគួបផ្សំជាមួយនឹងការឃ្លាំមើលពីសំណាក់រដ្ឋាភិបាល និងតួអង្គផ្នែកសេដ្ឋកិច្ច ដូច្នេះបាននាំទៅការបង្កើតនូវបរិយាកាសដ៏គ្រោះថ្នាក់មួយក្នុងការអនុវត្តសិទ្ធិសេរីភាពខាងការបញ្ចេញមតិរបស់ពួកគេ។

ការបង្ក្រាបមកលើអ្នកការពារសិទ្ធិមនុស្សកាន់តែមានសភាពខ្លាំងក្លាឡើងនៅចុងខែកក្កដា ឆ្នាំ២០២០ បន្ទាប់ពីមានការចាប់ខ្លួនលោក រ៉ុង ឈុន ដែលជាមេដឹកនាំសហជីពដ៏លេចធ្លោមួយរូបដែលបានបញ្ចេញមតិ

[84] ឡុង គឹមម៉ារីតា, "ក្រសួងកិច្ចការនារីជំរុញឱ្យបញ្ចប់ «ភាសាខុសឆ្គង»"។(ភ្នំពេញប៉ុស្ត, ១៦ កុម្ភៈ ២០២៣)។

[85] ថន វិបុល, "អង្គការមិនមែនរដ្ឋាភិបាលចំនួន ៤០ បានរិះគន់ចំពោះការអនុវត្តស្តង់ដារពីរ"។ (ខ្មែរថាមស៍, ២១ កុម្ភៈ ២០២៣)។

[86] ស៊ិន សារ៉ាត់, "បន្ទាប់ពីវីអូឌីបានបិទមានភាពអភិភាពប្រឆាំងអ្នកសារព័ត៌មាន"។ (ខេមបូចា, ២១ កុម្ភៈ ២០២៣)។

[87] នាង សុគន្ធា និងជា សុខនី, "ក្រសួងជំរុញឲ្យមានការគាំទ្រស្មើគ្នាសម្រាប់ស្ត្រីគ្រប់រូប"។ (ភ្នំពេញប៉ុស្តិ៍, ២១ កុម្ភៈ ២០២៣)។

ទាក់ទងនឹងបញ្ហាព្រំដែនកម្ពុជា-វៀតណាម តាមវិទ្យុ ដែលបញ្ហានេះនៅតែបន្តនៅក្នុងអំឡុងពេលនៃរបាយការណ៍នេះ។ យោងតាមទិន្នន័យដែលប្រមូលបានតាមរយៈការឃ្លាំមើលប្រព័ន្ធផ្សព្វផ្សាយបានបង្ហាញថាការយាយីឥតឈប់ឈរ តាមប្រព័ន្ធតុលាការរបស់រដ្ឋាភិបាលទៅលើអ្នកការពារសិទ្ធិមនុស្ស បាននាំទៅដល់ការចាត់វិធានការផ្លូវច្បាប់លើអ្នកការពារសិទ្ធិមនុស្សចំនួន១០០នាក់ ដោយសារតែការអនុវត្តសេរីភាពខាងការបញ្ចេញមតិចន្លោះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២២ ដល់ ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៣ របស់ខ្លួន៖




- អ្នកការពារសិទ្ធិមនុស្សចំនួន ២៦ នាក់ ត្រូវបានកោះហៅ
- អ្នកការពារសិទ្ធិមនុស្សចំនួន ៥២ នាក់ ត្រូវបានសួរចម្លើយ
- អ្នកការពារសិទ្ធិមនុស្សចំនួន ១៨ នាក់ ត្រូវបានចាប់ខ្លួន
- អ្នកការពារសិទ្ធិមនុស្សចំនួន ៣៤ នាក់ ត្រូវបានឃុំខ្លួន
- អ្នកការពារសិទ្ធិមនុស្សចំនួន ១៦ នាក់ ត្រូវបានបង្ខំឱ្យចុះហត្ថលេខាលើកិច្ចព្រមព្រៀងដោយសន្យាថាពួកគេនឹង 'បញ្ឈប់' ធ្វើសកម្មភាពបែបនេះទៀត។
- អ្នកការពារសិទ្ធិមនុស្សចំនួន ១៤ នាក់ ប្រឈមនឹងការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌ
- អ្នកការពារសិទ្ធិមនុស្សចំនួន ២១ នាក់ ត្រូវបានកាត់ទោស
- អ្នកការពារសិទ្ធិមនុស្សចំនួន ៧ នាក់ ត្រូវបានកាត់ទោស និងត្រូវបានតម្កល់សាលក្រមដោយតុលាការកំពូល។

អំឡុងពេលនៃរបាយការណ៍ អ្នកការពារសិទ្ធិមនុស្សដែលត្រូវបានដៅមុខសញ្ញារួមមាន សកម្មជនដីធ្លី ឬសកម្មជនការពារសិទ្ធិការងារ ដែលនេះឆ្លុះបញ្ចាំងពីការបង្ក្រាបកាន់តែខ្លាំងឡើងចំពោះអ្នកដែលនិយាយអំពីវិវាទដីធ្លី និងសិទ្ធិការងារនៅក្នុងប្រទេសកម្ពុជា ដែលជាបញ្ហាត្រូវបានចាត់ទុកថាជាបញ្ហារសើប ជាពិសេសពីសំណាក់អាជ្ញាធរកម្ពុជា។

***យ៉ាងហោចណាស់មានអ្នកការពារសិទ្ធិមនុស្ស ២១ នាក់ត្រូវបានកាត់ទោស ហើយ ៧ នាក់ ត្រូវបានតុលាការជាន់ខ្ពស់តម្កល់សាលក្រម ចន្លោះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២២ ដល់ ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៣ ដោយសារតែការអនុវត្តសេរីភាពខាងការបញ្ចេញមតិ៖***

***<u>សមាជិកសហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរនៃក្រុមហ៊ុនណាហ្គាវើលដ៍ (LRSU)</u>***

នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២៣ សាលាដំបូងរាជធានីភ្នំពេញបានសម្រេចកាត់ទោស កញ្ញា ឈឹម ស៊ីថរ ប្រធានដឹកនាំសហជីពណាហ្គាវើលដ៍ឱ្យជាប់ពន្ធនាគាររយៈពេលពីរឆ្នាំពីបទ "ញុះញង់" តាមមាត្រា៤៩៤ និង៤៩៥ នៃក្រមព្រហ្មទណ្ឌ ទាក់ទងនឹងសកម្មភាពកូដកម្មរបស់បុគ្គលិកណាហ្គាវើលដ៍។[88] សមាជិកប្រាំបីនាក់ផ្សេងទៀតក៏ត្រូវបានកាត់ទោសក្រោមបទល្មើសដូចគ្នា៖ កញ្ញា ឈឹម សុខន អ្នកស្រី ហៃ សុភាព អ្នកស្រី ឃ្លាំង សុបិន្ត អ្នកស្រី សុន ស្រីពេជ្រ និងកញ្ញា ទូច សេរីមាស ត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគាររយៈពេលមួយឆ្នាំប្រាំមួយខែ និងដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ ចំណែកលោក សុខ ណារិទ្ធ លោក សុខ គង្គា និងអ្នកស្រី រី សុវណ្ណឌី ត្រូវបានព្យួរទោសចំនួនមួយឆ្នាំ។ តុលាការមិនបានផ្តល់សេចក្តីពន្យល់ណាមួយលើមូលហេតុនៃការចេញសេចក្តីសម្រេចនេះទេ។ សមាជិកក្រុមសហជីពទាំងអស់ខាងលើត្រូវបានឃុំខ្លួនដំបូងនៅចន្លោះខែធ្នូ ឆ្នាំ២០២១ និងខែមករា ឆ្នាំ២០២២ មុនពេលត្រូវបានដោះលែងឱ្យនៅក្រៅឃុំនៅខែមីនា ឆ្នាំ២០២២។ កញ្ញា ឈឹម ស៊ីថរ ត្រូវបានចាប់ខ្លួនជាថ្មីក្នុងខែវិច្ឆិកា ឆ្នាំ២០២២ ពីបទបំពានលក្ខខណ្ឌក្នុងការធានាឱ្យនៅក្រៅឃុំដោយរឹតបន្តឹងមិនអនុញ្ញាតឱ្យចាកចេញពីប្រទេសកម្ពុជានោះទេ បើទោះបីជាមេធាវីរបស់កញ្ញាបានបញ្ជាក់ថា កញ្ញាមិនត្រូវបានជូនដំណឹងត្រឹមត្រូវអំពីលក្ខខណ្ឌបែបនេះពីសំណាក់ចៅក្រមឡើយ ហើយកញ្ញាត្រូវបានឃុំខ្លួនតាំងពីពេលនោះមក។[89]

***<u>សកម្មជនការពារសិទ្ធិដីធ្លីនៅខេត្តកោះកុង</u>***

កាលពីថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៣ តុលាការខេត្តកោះកុង បានកាត់ទោសសកម្មជនដីធ្លីនៅមូលដ្ឋានចំនួន១០នាក់ រួមមានលោក ឆាន់ ឈឿន អ្នកស្រី ដេត ហួរ អ្នកស្រី អើប រី អ្នកស្រី អ៊ិប តឹង លោក ហេង ដៃ អ្នកស្រី អ៊ិន ធូ អ្នកស្រី កើត នៅ លោក គង់ ម៉ែន លោក ពូ ហួន និងលោក សុខ ដៃ ឱ្យជាប់ពន្ធនាគាររយៈពេល១ឆ្នាំ ពីបទញុះញង់បង្កអសន្តិសុខសង្គម និងបរិហារកេរ្តិ៍ ពាក់ព័ន្ធនឹងជម្លោះដីធ្លីដ៏រ៉ាំរ៉ៃក្នុងខេត្តនេះ។ ពួក

---

[88] នៅក្នុងខែមេសា ឆ្នាំ២០២១ ក្រុមហ៊ុនកាស៊ីណូណាហ្គាវើលដ៍បានបញ្ឈប់បុគ្គលិកជាង១៣០០ នាក់ ដោយលើកឡើងពីការធ្លាក់ចុះនៃប្រាក់ចំណូលដែលបណ្តាលមកពីជំងឺរាតត្បាតកូវីដ-១៩។ កម្មករដែលត្រូវបានបញ្ឈប់ការងារភាគច្រើនគឺជាសមាជិក និងមេដឹកនាំសហជីព។ បន្ទាប់ពីការព្យាយាមចរចាមិនបានសម្រេចជាច្រើនលើកជាមួយក្រុមហ៊ុនកាស៊ីណូ និងការប្តឹងមិនបានជោគជ័យទៅអាជ្ញាធរពាក់ព័ន្ធ សហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរនៃក្រុមហ៊ុនណាហ្គាវើលដ៍ បានជូនដំណឹងដល់អាជ្ញាធរអំពីផែនការរបស់ពួកគេក្នុងការចាប់ផ្តើមកូដកម្មដោយសន្តិវិធីនៅខែធ្នូ ឆ្នាំ២០២១។ អំឡុងពេលនៃរបាយការណ៍នេះ (ចុងខែកញ្ញា ឆ្នាំ២០២៣) ជម្លោះនៅមិនទាន់ត្រូវបានដោះស្រាយនៅឡើយ។

[89] អង្គការលីកាដូ, "អត្ថបទខ្លី៖ សហជីព LRSU ប្រាំបួននាក់ត្រូវបានកាត់ទោសហើយ ឈឹម ស៊ីថរ តម្រូវឱ្យជាប់ពន្ធនាគារពីរឆ្នាំ"។ (២៥ ឧសភា ២០២៣); អាស៊ីសេរី, "ប្រធានសហជីពកាស៊ីណូណាហ្គាវើលត្រូវកាត់ទោសឱ្យជាប់ពន្ធនាគារ២ឆ្នាំ"។ (អាស៊ីសេរី, ២៥ ឧសភា ២០២៣)។

គេត្រូវបានបង្គាប់ឱ្យសងសំណងជំងឺចិត្តជាទឹកប្រាក់ចំនួន ៤០ លានរៀល ទៅឱ្យដើមចោទឈ្មោះ ហេង ហ៊ុយ ដែលជាឧកញ៉ាដ៏មានឥទ្ធិពល និងជាម្ចាស់ក្រុមហ៊ុនដែលឈូសឆាយដីសហគមន៍តាំងពីឆ្នាំ២០០៦។[90]

**អ្នកស្រី ជេត ហួរ៖** នៅថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២៣ តុលាការកំពូលបានតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ព្រះសីហនុចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២២ ដែលផ្តន្ទាទោសអ្នកស្រី ជេត ហួរ ជាសកម្មជនដីធ្លីឱ្យជាប់ពន្ធនាគាររយៈពេល ៦ ខែ និងពិន័យជាប្រាក់ចំនួនមួយលានរៀល ប៉ុន្តែទោសទាំងពីរនេះត្រូវព្យួរ។ អ្នកស្រី ហួរ ត្រូវបានតុលាការផ្តន្ទាទោសពីបទប្តឹងបរិហារបង្កាច់កេរ្តិ៍បន្ទាប់ពីលោក ហេង ហ៊ុយ បានប្តឹងកាលពីខែកញ្ញា ឆ្នាំ២០២១ ចំពោះការបង្ហោះហ្វេសប៊ុក ដែលអ្នកស្រីបានរិះគន់លោកចំពោះការទន្ទ្រានយកដីប្រជាពលរដ្ឋនៅមូលដ្ឋាន។[91]

**អ្នកស្រី ផាវ ញ៉ឿង និងអ្នកស្រី សេង លីន –** នៅថ្ងៃទី២ ខែសីហា ឆ្នាំ២០២៣ តុលាការខេត្តកោះកុងបានកាត់ទោសសកម្មជនដីធ្លីជាស្ត្រីគឺ អ្នកស្រី ផាវ ញ៉ឿង និងអ្នកស្រី សេង លីន ឱ្យជាប់ពន្ធនាគាររយៈពេល ១ ឆ្នាំ ពីបទបរិហារកេរ្តិ៍ និងញុះញង់បង្កភាពវឹកវរ។ ពួកគាត់ទាំងពីរនាក់ក៏ត្រូវបានតុលាការបង្គាប់ឱ្យបង់ប្រាក់ចំនួន ៤០ លានរៀលទៅដើមបណ្តឹងឈ្មោះ ឆាយ រី ជាអតីតតំណាងសហគមន៍ ដែលពួកគាត់ធ្លាប់បានចោទថាបានដកហូតយកដីក្នុងឆ្នាំ ២០១៩។[92]

**<u>ករណីបុគ្គលិកសមាគមអាដហុកប្រាំនាក់</u>**

នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២២ តុលាការកំពូលបានតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលផ្តន្ទាទោសបុគ្គលិក និងអតីតបុគ្គលិករបស់សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជាចំនួនប្រាំនាក់ ដោយពុំបានបញ្ជាក់លម្អិតអំពីហេតុផលនៅពីក្រោយនៃការចេញសេចក្តីសម្រេចនោះឡើយ។ **លោក នី សុខា លោក យី សុខ សាន្ត អ្នកស្រី លឹម មុនី លោក ណៃ វ៉ង់ដា និងលោក នី ចរិយា** ឬស្គាល់ថាបុគ្គលិកអាដហុកទាំងប្រាំ ត្រូវបានចាប់ខ្លួនក្នុងឆ្នាំ២០១៦ និងចោទប្រកាន់ពីបទសូកប៉ាន់សាក្សី បន្ទាប់ពីសមាគមអាដហុកបានផ្តល់ជំនួយហិរញ្ញវត្ថុដល់ស្ត្រីម្នាក់ ដែលត្រូវគេចោទថាមានទំនាក់ទំនងស្នេហាជាមួយលោក កឹម សុខា មេដឹកនាំគណបក្សជំទាស់។ ដំបូងឡើយពួកគាត់ត្រូវបានសាលាដំបូងរាជធានីភ្នំពេញផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេលប្រាំឆ្នាំក្នុងខែកញ្ញា ឆ្នាំ២០១៨ ដោយសាលាឧទ្ធរណ៍បានតម្កល់សាលក្រមក្នុង

---

90 អង្គការលីកាដូ, "អត្ថបទខ្លី៖ សកម្មជនដីធ្លីខេត្តកោះកុង ១០នាក់ត្រូវបានកាត់ទោស"។ (១៥ សីហា ២០២៣); អាស៊ីសេរី, "តុលាការខេត្តកោះកុងសម្រេចឱ្យសកម្មជនដីធ្លី ១០នាក់ជាប់ពន្ធនាគារ ១ឆ្នាំ និងពិន័យ ៤០ លានរៀល»។ (អាស៊ីសេរី, ១៥ សីហា ២០២៣)។

91 អង្គការលីកាដូ, "អត្ថបទខ្លី៖សកម្មជនដីធ្លីខេត្តកោះកុង៣នាក់ ដែលកំពុងជាប់ឃុំ ត្រូវបានផ្តន្ទាទោស"។ (០៤ សីហា ឆ្នាំ២០២៣); អ៊ឹង ស៊ី, "សកម្មជនដីធ្លីខេត្តកោះកុងត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទញុះញង់"។ (ខេមបូចា, ១៧ សីហា ២០២៣)។

92 អង្គការលីកាដូ, ដូចខាងលើ។

ខែឧសភា ឆ្នាំ២០២២។ ករណីនេះរងការរិះគន់ជាច្រើនថាការផ្តន្ទាទោសនោះពុំបានបង្ហាញវត្តមានសាក្សី ឬផ្តល់ភស្តុតាងដែលគួរឱ្យទុកចិត្តបង្ហាញលើការចោទប្រកាន់នោះ។[93]

**លោក ចេង បៅរ៉ុង**

នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២២ សាលាឧទ្ធរណ៍ព្រះសីហនុបានតម្កល់ការចោទប្រកាន់លើ លោកចេង បៅរ៉ុង អ្នកជួយសង្គ្រោះការរត់ពន្ធមនុស្សជនជាតិចិន និងជាមេដឹកនាំក្រុមសប្បុរសធម៌កម្ពុជា ចិន ដែលពុំមែនជាក្រុមផ្លូវការជួយជនរងគ្រោះនៃអំពើរត់ពន្ធមនុស្ស ការងារដោយបង្ខំ និងទារុណកម្មនៅកន្លែងបោកបញ្ឆោតស្ថិតក្នុងខេត្តព្រះសីហនុ។ សាលាឧទ្ធរណ៍បានសម្រេចព្យួរការផ្តន្ទាទោសនេះ ដោយបានចេញសេចក្តីសម្រេចឱ្យគាត់អនុវត្តទោសក្នុងពន្ធនាគាររយៈពេល១០ខែ ជំនួសទោសជាប់ពន្ធនាគាររយៈពេលពីរឆ្នាំ។ ដំបូងឡើយ ចេង បៅរ៉ុង ត្រូវបានចាប់ខ្លួនក្នុងខែមីនា ឆ្នាំ២០២២ និងចោទប្រកាន់ពីបទញុះញង់ឱ្យមានការរើសអើង ការធ្វើសេចក្តីថ្លែងមិនពិត ការរារាំងដោយខុសច្បាប់លើការបំពេញមុខងាររបស់មន្ត្រីរាជការសាធារណៈ និងការប្រើប្រាស់ដោយខុសច្បាប់នូវវិញ្ញាបនបត្រប្រកបវិជ្ជាជីវៈ បន្ទាប់ពីបានលើកឡើងអំពីករណីជនជាតិចិនម្នាក់ជាជនរងគ្រោះនៃអំពើរត់ពន្ធមនុស្សដែលបានអះអាងថាខ្លួនត្រូវបានគេបង្ខំឱ្យបូមឈាម។ ចេង បៅរ៉ុង និងជំនួយការរបស់លោក ដែលជាគ្រូពេទ្យ និងជាជនរងគ្រោះត្រូវបានផ្តន្ទាទោស។ ប៉ុន្តែទីបំផុតលោកត្រូវបានដោះលែងវិញនៅថ្ងៃទី០២ ខែមករា ឆ្នាំ២០២៣។[94]

អ្នកការពារសិទ្ធិមនុស្សប្រាំបីនាក់ក្នុងចំណោម១០នាក់ ដែលបានផ្តល់សម្ភាសន៍សម្រាប់របាយការណ៍នេះបានលើកឡើងថាធ្លាប់ទទួលរងការរឹតត្បិត ឬការរំលោភបំពានសេរីភាពខាងការបញ្ចេញមតិពីសំណាក់អាជ្ញាធរ ឬភាគីទីបីនៅពេលពួកគេអនុវត្តការងារតស៊ូមតិ។ ប៉ុន្តែមានតែម្នាក់ប៉ុណ្ណោះបានដាក់ពាក្យបណ្តឹងទៅកាន់អាជ្ញាធរពាក់ព័ន្ធ ឬតុលាការ។ ករណីគួរឱ្យកត់សម្គាល់ខ្លាំងនោះ គឺអ្នកការពារសិទ្ធិមនុស្សទីមួយបានលើកឡើងថាជារឿយៗមន្ត្រីមូលដ្ឋានប្រើពាក្យសម្តីគំរាមកំហែង និងសុំរបៀបវារៈកម្មវិធីប្រជុំនានារបស់សហគមន៍។ ជានិច្ចកាលពួកគេក៏បានសួរសកម្មជនដែលចាកចេញពីផ្ទះទៅចូលរួមសកម្មភាពខាងក្រៅផងដែរ។ អ្នកផ្តល់សម្ភាសទីពីរបានលើកឡើងថាធ្លាប់ត្រូវបានចោទពីការញុះញង់មនុស្សឱ្យតវ៉ាលើបញ្ហាដីធ្លី និងព្រៃឈើ។ លោកក៏ធ្លាប់ត្រូវបានមន្ត្រីនគរបាលស្នើឱ្យ "កែតម្រូវ" ព័ត៌មានទាក់ទងនឹងការស៊ើបអង្កេតរបស់លោកក្នុងករណីរំលោភបំពានសិទ្ធិមនុស្ស។ អ្នកការពារសិទ្ធិមនុស្សទី៣ បានលើកឡើងថា អ្នកស្រីធ្លាប់ត្រូវបានអាជ្ញាធរឃុំខ្លួនពាក់ព័ន្ធនឹងការងាររបស់ខ្លួន។ បន្ទាប់មកអ្នកស្រីបានព្យាយាមដាក់ពាក្យបណ្តឹងទៅកាន់ភូមិ និងឃុំ ប៉ុន្តែពុំទទួលបាន

93 បុគ្គលិកវីអូឌី, "ព័ត៌មានខ្លី៖ តុលាការកំពូលបដិសេធបណ្តឹងឧទ្ធរណ៍បុគ្គលិកអាដហុកទាំងប្រាំនាក់ ដែលឈានដល់ការបិទបញ្ចប់សំណុំរឿងដែលផ្ទុះការចាប់អារម្មណ៍ខ្លាំង"។ (វីអូឌី, ១៨ វិច្ឆិកា ឆ្នាំ២០២២); ឃួន ណារីម, "តុលាការកំពូលតម្កល់ការផ្តន្ទាទោសនូវបទសូកប៉ាន់សាក្សីលើបុគ្គលិកអាដហុកទាំងប្រាំនាក់"។(ខេមបូចា, ១៨ វិច្ឆិកា ឆ្នាំ២០២២)។

94 ម៉ិច ដារ៉ា, "អ្នកជួយសង្គ្រោះជនជាតិចិនក្នុងករណីឆបោកត្រូវបានដោះលែងពីពន្ធនាគារបន្ទាប់ពីជាប់ទោស ១០ខែ"។ (វីអូឌី, ២១ ធ្នូ ២០២២); យ៉ាន់ ហ័ង, "អ្នកជួយសង្គ្រោះក្នុងករណីឆបោកត្រូវបានដោះលែងបន្ទាប់ពីសាលាឧទ្ធរណ៍ទម្លាក់ការចោទប្រកាន់" (វីអូឌី, ២១ ធ្នូ ២០២២)។

លទ្ធផល។ អ្នកការពារសិទ្ធិមនុស្សទីបួនបានលើកឡើងថា អ្នកស្រីធ្លាប់រងការប្តឹងពីបទបរិហារកេរ្តិ៍បន្ទាប់ពីបានរិះគន់ការកាប់ឆ្ការយកដីពីសំណាក់ក្រុមហ៊ុនដំកៅស៊ូនៅលើទំព័រហ្វេសប៊ុករបស់អ្នកស្រី។ ក្នុងករណីដូចគ្នានេះ អ្នកទីប្រាំបានលើកឡើងថាឧកញ៉ាម្នាក់បានគំរាមកំហែងព្យាយាមឱ្យគាត់លុបសារបង្ហោះលើហ្វេសប៊ុករិះគន់លើការដាំបង្គោលព្រំដីលើដីសហគមន៍ពីសំណាក់ក្រុមហ៊ុនរបស់គាត់។

បន្ថែមលើករណីខាងលើ អ្នកការពារសិទ្ធិមនុស្សម្នាក់ក្នុងចំណោមអ្នកការពារសិទ្ធិមនុស្សផ្សេងទៀតបានផ្តល់សម្ភាសនៅចន្លោះពីខែធ្នូ ឆ្នាំ២០២២ ដល់ខែមីនា ឆ្នាំ២០២៣ បាននិយាយថាបុគ្គលដែលតស៊ូមតិជួយដល់ពលរដ្ឋដែលបានបាត់បង់ដីធ្លី និងផ្ទះសម្បែងអាចប្រឈមនឹងការជាប់ពន្ធនាគារ។ ខ្លួនលោកផ្ទាល់ធ្លាប់ត្រូវបានចាប់ខ្លួននៅ ខែកញ្ញា ឆ្នាំ២០២០ ដោយសាររៀបចំផែនការធ្វើបាតុកម្មដោយសន្តិវិធីដើម្បីទាមទារយុត្តិធម៌សង្គមនៅទីលានប្រជាធិបតេយ្យក្នុងរាជធានីភ្នំពេញ។ បន្ទាប់មកអាជ្ញាធរបានចោទប្រកាន់លោកពីបទញុះញង់ឱ្យបង្កភាពវឹកវរដល់សង្គម និងបានបញ្ជូនគាត់ទៅឃុំខ្លួនបណ្តោះអាសន្ន។ លោកត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល ២០ខែ ក្នុងខែតុលា ឆ្នាំ២០២១ ប៉ុន្តែទោសរបស់លោកត្រូវបានព្យួរ។ ទោះបីជាលោកត្រូវបានដោះលែងវិញ ក្នុងខែវិច្ឆិកា ឆ្នាំ២០២១ ក្តី តែសាលាឧទ្ធរណ៍បានតម្កល់ទោសរបស់លោក ក្នុងខែសីហា ឆ្នាំ២០២២ និងដោយតុលាការកំពូលក្នុងខែឧសភា ឆ្នាំ២០២៣។ អ្នកផ្តល់សម្ភាសម្នាក់ទៀតបានគូសបញ្ជាក់ថាអ្នកការពារសិទ្ធិមនុស្សបាននឹងកំពុងប្រឈមនឹងការយាយី និងការរឹតត្បិតជាច្រើនដោយសារការងារស្របច្បាប់។ លោកបានលើកឡើងថាលោកធ្លាប់ត្រូវបានចោទប្រកាន់ "ការចាប់ខ្លួន ការឃុំខ្លួន និងបង្ខាំងដោយខុសច្បាប់" ក្នុងឆ្នាំ២០១៤ ដោយសារការឃ្លាំមើលការតវ៉ាទាក់ទងនឹងសិទ្ធិដីធ្លីក្នុងខេត្តព្រះវិហារ។ បន្ទាប់ពីដំណើរការនីតិវិធីជាច្រើនឆ្នាំមក ចុងក្រោយការចោទប្រកាន់ទាំងនេះត្រូវបានទម្លាក់នៅដើមឆ្នាំ២០២១។ អ្នកការពារសិទ្ធិមនុស្សទីបីបានផ្តល់សម្ភាសក្នុងអំឡុងពេលនោះថាធ្លាប់រងការប្តឹងពីឈ្មួញឈើម្នាក់ក្នុងឆ្នាំ២០១៩ ដែលហាក់មិនលើកទឹកចិត្តដល់សមាជិកសហគមន៍ ក្នុងការបន្តសកម្មភាពរបស់ខ្លួនដើម្បីការពារព្រៃឈើឡើយ។

> **«អ្នកការពារសិទ្ធិមនុស្សជាញឹកញាប់រងការចោទថាជាអ្នកជំរុញឱ្យកសិករ និងសហគមន៍មូលដ្ឋានក្រោកឈរតវ៉ា។ នៅពេល [អាជ្ញាធរ] ឮពាក្យសកម្មជនសិទ្ធិមនុស្ស សកម្មជនបរិស្ថាន សកម្មជនដីធ្លី... ពួកគេគឺជាគោលដៅដែលត្រូវប្រឈមនឹងការចាប់ខ្លួន»។**
>
> អ្នកការពារសិទ្ធិមនុស្សបានសម្ភាសដោយ ម.ស.ម.ក ពីខែវិច្ឆិកា ឆ្នាំ២០២២ ដល់ ខែមីនា ឆ្នាំ២០២៣

### *ការវាយដំលើរូបរាងកាយលើអ្នកការពារសិទ្ធិមនុស្ស*

បន្ថែមលើការយាយីតាមផ្លូវតុលាការដែលពួកគេតែងតែប្រឈមនោះ អ្នកការពារសិទ្ធិមនុស្សនៅកម្ពុជាធ្វើការងារក្នុងបរិយាកាសគ្រោះថ្នាក់ និងពុំមានសុវត្ថិភាព។ ក្នុងអំឡុងពេលនៃរបាយការណ៍នេះ មានការកត់ត្រានូវករណីវាយដំលើរាងកាយលើអ្នកការពារសិទ្ធិមនុស្សម្នាក់។



**លោក ហឿន ស៊ីណាត៖** នៅរសៀលថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២២ ជនមិនស្គាល់អត្តសញ្ញាណបីនាក់ជិះម៉ូតូមួយគ្រឿងបានវាយប្រហារលើលោក ហឿន ស៊ីណាត សកម្មជនដីធ្លីមកពីឃុំស្រែប្រាំង ខេត្តត្បូងឃ្មុំ ខណៈលោក ចូលរួមកម្មវិធីសិក្ខាសាលាមួយរៀបចំដោយសមាគមសម្ព័ន្ធសហគមន៍កសិករកម្ពុជាក្នុងរាជធានីភ្នំពេញ។ ក្រុមអ្នកវាយប្រហារទាំងនោះបានវាយលើផ្ទៃមុខលោកស៊ីណាតជាច្រើនដង បណ្តាលឱ្យរយះចង្កាឆ្វេង និងរងរបួសកន្លែងផ្សេងទៀតជាច្រើន។ លោកបានដាក់ពាក្យបណ្តឹងទៅកាន់ប៉ុស្តិ៍នគរបាលសង្កាត់ផ្សារដើមថ្កូវនៅថ្ងៃវាយប្រហារនោះ។[95]

នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៣ ជាគម្រប់ខួប១១ ឆ្នាំ នៃឃាតកម្មលើលោក ឈុត វុទ្ធី សកម្មជនបរិស្ថានដែលត្រូវបានបាញ់សម្លាប់ខណៈធ្វើដំណើរអមអ្នកសារព័ត៌មានពីរនាក់ស៊ើបអង្កេតបទល្មើសព្រៃឈើនៅជិតតំបន់ការពារមួយក្នុងខេត្តកោះកុង។ លោក វុទ្ធី ជានាយកអង្គការក្រុមការពារធនធានធម្មជាតិ ដែលគេស្គាល់ដោយសារការចូលរួមរបស់លោកក្នុងការការពារព្រៃឈើ និងធនធានធម្មជាតិរបស់ប្រទេសកម្ពុជា និងលាតត្រដាងនូវបទល្មើសផ្នែកបរិស្ថានក្នុងនោះរួមទាំងករណីផ្សេងៗដែលជាប់ពាក់ព័ន្ធជាមួយអាជ្ញាធរកម្ពុជាផងដែរ។ ភ្លាមៗករណីឃាតកម្មលើលោក ត្រូវបានសាលាដំបូងខេត្តកោះកុងប្រកាសសាលក្រមក្នុងខែតុលា ឆ្នាំ២០១២ ដោយពុំមានការស៊ើបអង្កេតដោយតម្លាភាព និងឯករាជ្យពីសំណាក់អាជ្ញាធរ ដែលធ្វើឱ្យលោកវុទ្ធី និងគ្រួសាររបស់លោកពុំទទួលបានយុត្តិធម៌។[96] នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៣ សកម្មជនជាយុវជនប្រមាណ២០នាក់បាននាំគ្នាដើរហែក្បួនក្នុងរាជធានីភ្នំពេញដើម្បីរំលឹកវិញ្ញាណក្ខន្ធក្នុងថ្ងៃគម្រប់ខួប១១ឆ្នាំនៃឃាតកម្មលើលោក ឈុត វុទ្ធី។ ពួកគេព្រមទាំងបានដាក់ញត្តិទៅក្រសួងយុត្តិធម៌ទាមទារឱ្យបើកការស៊ើបអង្កេតករណីឃាតកម្មនោះ

[95] ប៉ា សុខេង, "សកម្មជនដីធ្លីនៅខេត្តត្បូងឃ្មុំរងការវាយដំក្នុងរាជធានីភ្នំពេញ"។ (វីអូឌី, ១៨ តុលា ២០២២)។
[96] ម.ស.ម.ក, "សេចក្តីថ្លែងការណ៍៖ ម.ស.ម.ក សូមចូលរួមមរណៈទុក្ខគម្រប់ខួបពីរឆ្នាំនៃសកម្មជនបរិស្ថាន លោកឈុត វុទ្ធី និងថ្កោលទោសចំពោះវប្បធម៌អំពើហិង្សា និងនិទណ្ឌភាពដែលបន្តកើតមានឡើងនៅកម្ពុជា"។ (ម.ស.ម.ក, ២៦ មេសា ២០១៤)។

ឡើងវិញ និងបានរិះគន់ខ្លាំងចំពោះការដៅមុខសញ្ញាលើសកម្មជនបរិស្ថាននៅក្នុងរយៈពេលពីរបីឆ្នាំចុងក្រោយនេះ។[97]

ករណីស្រដៀងគ្នានេះ ក្នុងខែកក្កដា គម្រប់ខួបប្រាំពីរឆ្នាំនៃឃាតកម្មលើលោក កែម ឡី ជាអ្នកវិភាគនយោបាយ និងអ្នកការពារសិទ្ធិមនុស្សដ៏លេចធ្លោ។ សកម្មជនរូបនេះគេស្គាល់លោកដោយសារលោកហ៊ាននិយាយនូវអ្វីដែលអ្នកដទៃមិនហ៊ាននិយាយ ដែលត្រូវបានឃាតករបាញ់សម្លាប់នៅស្ថានីយប្រេងឥន្ធនៈមួយកន្លែងក្នុងរាជធានីភ្នំពេញក្នុងខែកក្កដា ឆ្នាំ២០១៦ ដោយពុំមានការស៊ើបអង្កេតឱ្យបានហ្មត់ចត់ និងឯករាជ្យ ហើយឃាតករសម្លាប់លោកនៅពុំទាន់នាំខ្លួនមកផ្តន្ទាទោសនៅឡើយ។[98] ការវិវត្តព្រឹត្តិការណ៍នានាក្នុងអំឡុងពេលនៃរបាយការណ៍នេះបង្ហាញថាករណីនោះនៅតែចម្រូងចម្រាសខ្លាំង។ នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៣ សាលាដំបូងរាជធានីភ្នំពេញបានកាត់ទោសលោក គឹម សុខ អ្នកវិភាគនយោបាយដែលនិរទេសខ្លួនទៅក្រៅប្រទេសដោយកំបាំងមុខឱ្យជាប់ពន្ធនាគាររយៈពេល១៨ ខែ និងពិន័យប្រាក់ចំនួនប្រាំបីលានរៀល។ លោកធ្លាប់រងការចោទប្រកាន់ពីបទបរិហារកេរ្តិ៍ និងញុះញង់បន្ទាប់ពីបាននិយាយថាឃាតកម្មលើលោក កែម ឡី ជាប់ពាក់ព័ន្ធជាមួយគណបក្សប្រជាជនកម្ពុជា។ លោកក៏ត្រូវបានបង្គាប់ឱ្យបង់ប្រាក់ជំងឺចិត្តចំនួន៥០លានរៀលដល់រដ្ឋាភិបាលផងដែរ។[99] នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣ សកម្មជនយុវជនបរិស្ថាន សមាជិកគណបក្សជំទាស់ និងតំណាងអង្គការសង្គមស៊ីវិលប្រមាណចំនួន ១០០នាក់ បានប្រមូលផ្តុំគ្នានៅស្ថានីយប្រេងឥន្ធនៈទីកន្លែងដែលលោក កែម ឡី ត្រូវឃាតករបាញ់សម្លាប់ ដើម្បីអំពាវនាវឱ្យរដ្ឋាភិបាលផ្តល់យុត្តិធម៌ដល់លោក កែម ឡី។ យ៉ាងតិចមានមន្ត្រីអាជ្ញាធរ ១៥នាក់ ស្លៀកពាក់ស៊ីវិលបានឃ្លាំមើលព្រឹត្តិការណ៍នោះ។ លោក ជិន ម៉ាលីន អ្នកនាំពាក្យក្រសួងយុត្តិធម៌បានលើកឡើងថា យុត្តិធម៌បានផ្តល់រួចហើយតាមរយៈការផ្តន្ទាទោស លោក អឿត អាង អតីតទាហានឱ្យជាប់ពន្ធនាគារអស់មួយជីវិតចំពោះអំពើឃាតកម្ម ក្នុងឆ្នាំ ២០១៧ នោះ និងបានបដិសេធការអះអាងថាឃាតករដែលត្រូវបានផ្តន្ទាទោសនោះត្រូវបានគេប្រើឱ្យមកទទួលទោសជំនួស។[100]

ករណីដែលពុំទាន់ត្រូវបានដោះស្រាយ ឬគួរឱ្យសោកស្តាយទាំងពីរនេះ ជាការរំឭកនឹកដល់គ្រោះថ្នាក់ដែលអ្នកការពារសិទ្ធិមនុស្សបន្តប្រឈមដោយសារការធ្វើការងារដោយស្របច្បាប់ និងការអនុវត្តសេរីភាពមូលដ្ឋានរបស់ពួកគេ និងនិទណ្ឌភាពដែលកំពុងកើតមានរាលដាលនៅប្រទេសកម្ពុជា និងផ្តល់លទ្ធភាពដល់ការវាយប្រហារលើអ្នកការពារសិទ្ធិមនុស្សបន្តកើតឡើង។ ជាលទ្ធផល អ្នកការពារសិទ្ធិមនុស្សជាច្រើនពុំមានសេរីភាព

---

[97] ក្លូង វណ្ណថា, "សកម្មជនទាមទារឱ្យធ្វើការស៊ើបអង្កេតក្នុងករណីឃាតកម្មលោក ឈុត វុទ្ធី"។ (ខេមបូឌាណេស, ២៦ មេសា ២០២៣); ដើរ៉ាល វ្លីន, "សកម្មជនកម្ពុជាប្រារព្ធពិធីរំឭកវិញ្ញាណក្ខន្ធលោក ឈុត វុទ្ធី ក្នុងគម្រប់ខួប១១ ឆ្នាំនៃឃាតកម្មលោក"។ (ម៉ុនហ្គាបាយ, ២៨ មេសា ២០២៣)។

[98] ម.ស.ម.ក, "សលាកប័ត្រព័ត៌មាននិទណ្ឌភាពនៅកម្ពុជា"។ (ម.ស.ម.ក, កក្កដា ២០២១)។

[99] អ៊ូច សូនី, "លោក គឹម សុខ ត្រូវបានតុលាការផ្តន្ទាទោសដោយសារផ្តល់សម្ភាសលើករណីឃាតកម្មលោក កែម ឡី មានការស៊ើបអង្កេតឡើងវិញក្នុងករណីពីរផ្សេងទៀត"។ (វីអូឌី ១៨ មករា ២០២៣); ប៊ុត រស្មីគង្គា, "លោក គឹម សុខ ត្រូវបានតុលាការផ្តន្ទាទោសកំបាំងមុខពីបទបរិហារកេរ្តិ៍ និងញុះញង់"។ (ខ្មែរថាមស៍ ១៩ មករា ២០២៣)។

[100] ឃួន ណារីម, "សកម្មជនស្នើជាថ្មីម្តងទៀតឱ្យស្វែងរកយុត្តិធម៌ក្នុងឱកាសខួបប្រាំពីរឆ្នាំនៃឃាតកម្មលោក កែម ឡី"។ (ខេមបូចា ១០ កក្កដា ២០២៣)។ អង្គការលីកាដូ, "អស់រយៈពេល៧ឆ្នាំ ការអំពាវនាវឱ្យមានយុត្តិធម៌ទៅលើឃាតកម្មលោកបណ្ឌិត កែម ឡី នៅតែបន្ត"។ (១០ កក្កដា ២០២៣)។

ក្នុងការអនុវត្តការងាររបស់ខ្លួនដោយសេរីឡើយ និងបារម្ភពីផលវិបាក។ អ្នកការពារសិទ្ធិមនុស្សចំនួន៧នាក់ ក្នុងចំណោម១០នាក់ដែលបានផ្តល់សម្ភាសសម្រាប់របាយការណ៍នេះបានលើកឡើងថា ធ្លាប់ខ្លាច ឬព្រួយបារម្ភពីសន្តិសុខផ្ទាល់ខ្លួននៅពេលធ្វើការងារសិទ្ធិមនុស្ស។ ការណ៍គួរឱ្យបារម្ភនោះ ក្នុងចំណោមអ្នកផ្តល់សម្ភាសជាបុរសម្នាក់ថែមទាំងបានលើកឡើងពីករណីឃាតកម្មជាក្តីបារម្ភចម្បងរបស់លោក ដោយបន្ថែមថា លោកមិនហ៊ានលើកឡើងចំឈ្មោះរបស់មន្ត្រីជាន់ខ្ពស់នៅពេលធ្វើការងារតស៊ូមតិនោះទេ។ អ្នកផ្សេងទៀតបាននិយាយថាខ្លាចរងការព្យាបាទពីជនមានអំណាច ឬត្រូវបានមន្ត្រីពុករលួយ និងឈ្មួញទុច្ចរិតកំណត់មុខសញ្ញា។ ដោយសារហេតុនោះ លោកបដិសេធធ្វើការតស៊ូមតិលើបញ្ហាជាច្រើនពាក់ព័ន្ធនឹងការកាប់ឈើខុសច្បាប់ និងការកាប់ឆ្ការដីព្រៃ។

បរិយាកាសមិនសុវត្ថិភាពនេះ បានធ្វើឱ្យអ្នកការពារសិទ្ធិមនុស្សជាច្រើនសម្របខ្លួន និងផ្លាស់ប្តូរឥរិយាបថការងាររបស់ខ្លួន ដើម្បីបន្តបំពេញការងារសំខាន់របស់ពួកគេក្នុងមធ្យោបាយដ៏មានសុវត្ថិភាពទៅតាមលទ្ធភាព។ អ្នកការពារសិទ្ធិមនុស្សម្នាក់ដែលបានផ្តល់សម្ភាសសម្រាប់របាយការណ៍នេះបានលើកឡើងថាលោកត្រឹមតែផ្តល់សេចក្តីថ្លែងទូទៅប៉ុណ្ណោះនៅពេលនិយាយជាសាធារណៈ ដោយមិនផ្តោតលើប្រធានបទ ឬបញ្ហាជាក់លាក់នោះទេ។ អ្នកផ្សេងទៀតដែលសារភាពពីការដាក់កំហិតខ្លួនឯងបានបញ្ជាក់ថា អ្នកការពារសិទ្ធិមនុស្សត្រូវតែមានការប្រុងប្រយ័ត្នខ្លាំងនៅពេលបង្ហាញទស្សនៈផ្ទាល់ខ្លួន ហើយមូលដ្ឋានពួកគេតស៊ូមតិត្រូវផ្អែកលើច្បាប់ជាតិ និងច្បាប់អន្តរជាតិ។ អ្នកការពារសិទ្ធិមនុស្សជាស្ត្រីម្នាក់បានលើកឡើងថាអ្នកស្រីព្យាយាមស្វែងរកទីកន្លែងស្ងាត់ និងសុវត្ថិភាពដែលស្ថិតនៅឆ្ងាយពីភូមិរបស់អ្នកស្រីដើម្បីពិភាក្សាអំពីបញ្ហានានាដែលប៉ះពាល់សហគមន៍ ដោយលើកហេតុផលថាមានការតាមឃ្លាំមើលច្រើនពីរដ្ឋាភិបាល។ ទោះបីមានការលំបាកទាំងនេះក្តី មានតែអ្នកផ្តល់សម្ភាសន៍ ២នាក់ប៉ុណ្ណោះបានលើកឡើងថា បានបដិសេធការដឹកនាំសកម្មភាពតស៊ូមតិទាក់ទងនឹងបញ្ហាសិទ្ធិមនុស្សដោយចាត់ទុកថាជាការងារប្រឈមខ្លាំងពេក។ ប៉ុន្តែ អ្នកផ្តល់សម្ភាសបីនាក់បានសង្កត់ធ្ងន់ពីភាពចាំបាច់ក្នុងការបញ្ចៀសការនិយាយអំពីបញ្ហានយោបាយ ឬការជាប់ពាក់ព័ន្ធជាមួយគណបក្សជំទាស់។

អ្នកការពារសិទ្ធិមនុស្សម្នាក់បានផ្តល់សម្ភាសន៍ បានលើកឡើងថា លោកធ្លាប់រងនូវការប្រមាថជាច្រើនដងនៅលើបណ្តាញសង្គម ព្រមទាំងទទួលបានការគំរាមសម្លាប់ទៀតផង នៅពេលមួយដែលលោកចុះបំពេញបេសកកម្ម។ ប៉ុន្តែលោកថ្លែងថា ការណ៍នេះមិនបានរារាំងលោកក្នុងការបន្តការងារតស៊ូមតិផ្នែកសិទ្ធិមនុស្សឡើយ លោកបានលើកឡើងថា៖ *"ជាអ្នកការពារប្រយោជន៍សង្គម ចៀសមិនផុតពីការជួបប្រទះនូវករណីទាំងនោះទេ។ ខ្ញុំស៊ាំទៅហើយ"*។ អ្នកផ្តល់សម្ភាសផ្សេងទៀតបាននិយាយថាគ្រួសាររបស់លោកប្រឈមការគំរាមព្រោះតែភាពសកម្មរបស់លោក ដោយលើកឡើងបន្ថែមថា អ្នកតស៊ូមតិដើម្បីជួយពលរដ្ឋដែលបាត់បង់ដីធ្លី និងផ្ទះសម្បែងអាចប្រឈមនឹងគ្រោះថ្នាក់ ដូចជា "បាត់បង់អាយុជីវិត" ជាដើម។ អ្នកផ្តល់សម្ភាសទីបីបាននិយាយថាសហគមន៍របស់អ្នកស្រីមិនហ៊ានល្បាតព្រៃនៅពេលយប់ដើម្បីទប់ស្កាត់ការកាប់ឈើខុសច្បាប់ឡើយ ព្រោះថាជនល្មើសសហការជាមួយឧក្រិដ្ឋជននៅមូលដ្ឋានមានប្រដាប់កាំភ្លើង។ ជាចុងក្រោយ អ្នកផ្តល់សម្ភាសទីបួនបានលើកឡើងថាមានការបារម្ភអំពីសុវត្ថិភាពរបស់លោក និងសមាជិកបណ្តាញរបស់លោក។

# សេរីភាពបញ្ចេញមតិរបស់អ្នកការពារសិទ្ធិមនុស្សជាស្ត្រី



នៅក្នុងបរិយាកាសប្រទូសចំពោះសំឡេងរិះគន់ អ្នកការពារសិទ្ធិមនុស្សជាស្ត្រីគេចមិនផុតពីការជួបនូវបញ្ហាប្រឈមជាច្រើនដែលសកម្មជននានាប្រឈមនៅប្រទេសកម្ពុជានោះទេ។ ក្នុងចំណោមអ្នកការពារសិទ្ធិមនុស្សជាស្ត្រី ដែលប្រឈមនឹងចំណាត់ការផ្លូវច្បាប់ដោយសារការអនុវត្តសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួនក្នុងអំឡុងពេលនៃរបាយការណ៍នេះ គឺកញ្ញា ឈឹម ស៊ីថរ សកម្មជនសហជីពដ៏លេចធ្លោ ព្រមទាំងអ្នកស្រីដេត ហួរ អ្នកស្រី ផាវ ញ៉ឿង និងអ្នកស្រី សេង លីន *(សម្រាប់ព័ត៌មានលម្អិតបន្ថែម សូមមើលផ្នែក ការយាយីតាមផ្លូវតុលាការលើអ្នកការពារសិទ្ធិមនុស្សចំពោះការអនុវត្តសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន*)។ ខាងក្រោមនេះគឺជាករណីពីរផ្សេងទៀតដែលបង្ហាញពីការកំណត់គោលដៅរបស់រដ្ឋាភិបាលលើអ្នកការពារសិទ្ធិមនុស្សជាស្ត្រី។

**អ្នកនាង សេង ធារី៖** នៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២២ សាលាឧទ្ធរណ៍ភ្នំពេញបានច្រានចោលសំណើសុំដោះលែងអ្នកនាង សេង ធារី សកម្មជនសិទ្ធិមនុស្ស ខ្មែរ–អាម៉េរិក ដើម្បីឱ្យអ្នកនាងមានលទ្ធភាពចូលរួមសវនាការឧទ្ធរណ៍របស់ខ្លួនដោយស្ថិតនៅក្រៅឃុំបានឡើយ។ តុលាការបានផ្តល់ការពន្យល់តិចតួចចំពោះសេចក្តីសម្រេចរបស់ខ្លួន ហើយអ្នកនាងពុំត្រូវបានអនុញ្ញាតឱ្យចូលរួមសវនាការឡើយ។ អ្នកនាង ធារី ត្រូវបានតុលាការកាត់ទោសដាក់ពន្ធនាគាររយៈពេលប្រាំមួយឆ្នាំក្នុងខែមិថុនា ឆ្នាំ២០២២ ពីបទរួមគំនិតក្បត់ និងញុះញង់ដែលជាផ្នែកនៃការជំនុំជម្រះក្តីទ្រង់ទ្រាយធំក្នុងសំណុំរឿងរបស់សមាជិកគណបក្សសង្គ្រោះជាតិកម្ពុជា។[101] នៅក្នុងកិច្ចប្រជុំលើកទី៩៦ ពីថ្ងៃទី២៥ ខែមីនា ដល់ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២៣ ក្រុមការងារនៃអង្គការសហប្រជាជាតិស្តីពីការឃុំខ្លួនតាមអំពើចិត្តបានចេញសេចក្តីសន្និដ្ឋានថា ការចាប់ និងឃុំខ្លួនអ្នកនាង សេង ធារី ធ្វើឡើងតាមអំពើចិត្ត និងដោយសារការអនុវត្តសេរីភាពខាងគំនិត ការបញ្ចេញមតិ និងការជួបជុំដោយសន្តិវិធី និងសមាគមរបស់អ្នកនាង។ ក្រុមការងារអង្គការសហប្រជាជាតិបានអំពាវនាវដល់រដ្ឋាភិបាលកម្ពុជាឱ្យដោះ

[101] យួន ណារីម, "សាលាឧទ្ធរណ៍បដិសេធដោះលែងសកម្មជនសិទ្ធិមនុស្សអ្នកនាង សេង ធារី"។ (ខេមបូចា, ០២ កញ្ញា ២០២២)។

លែងអ្នកនាងជាបន្ទាន់ និងផ្តល់សិទ្ធិដល់អ្នកនាងក្នុងការទទួលបានសំណង និងការខាតបង់ផ្សេងៗ[102] ប៉ុន្តែពុំទទួលបានលទ្ធផល។

**អ្នកស្រី ប្រាក់ សោភា៖** នៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០២៣ មានសេចក្តីរាយការណ៍ថា អ្នកស្រី ប្រាក់ សោភា អ្នកការពារសិទ្ធិដីធ្លីដ៏លេចធ្លោ រស់នៅភូមិសំរោងត្បូង ក្នុងរាជធានីភ្នំពេញ បានភៀសខ្លួនទៅកាន់ប្រទេសថៃ ហើយបានដាក់ពាក្យស្នើសុំឋានៈជាជនភៀសខ្លួនជាមួយភ្នាក់ងារទទួលបន្ទុកជនភៀសខ្លួនអង្គការសហប្រជាជាតិ UNHCR ។ អ្នកស្រីសោភា ជាសកម្មជននិយាយមិនសំចៃមាត់ ដែលសហគមន៍អ្នកស្រីស្ថិតលើប្រាំងបឹងតាមោក ដែលត្រូវប្រឈមនឹងការបណ្តេញចេញ ដើម្បីបើកផ្លូវសម្រាប់គម្រោងអភិវឌ្ឍន៍អចលនទ្រព្យ។ អ្នកស្រីបានចាកចេញពីប្រទេសកម្ពុជាដើម្បីគេចពីការចាប់ខ្លួនបន្ទាប់ពីទទួលបានព័ត៌មានថានឹងមានពាក្យបណ្តឹងតុលាការលើកទីបួនលើអ្នកស្រី។ អ្នកស្រីក៏បាននិយាយដែរថា អ្នកស្រីតែងតែត្រូវបានជនមិនស្គាល់អត្តសញ្ញាណស្លៀកសម្លៀកបំពាក់ស៊ីវិលតាមឃ្លាំមើល។ អ្នកស្រី ប្រាក់ សោភា និងសមាជិកសហគមន៍បឹងតាមោកផ្សេងទៀត ប្រឈមនឹងការយាយីតាមផ្លូវតុលាការជាយូរមកហើយដោយសារការតវ៉ាជំទាស់នឹងគម្រោងចាក់ដីលុបបឹងតាមោក។[103]

អ្នកការពារសិទ្ធិមនុស្សជាស្ត្រីកម្ពុជាក៏ជួបប្រទះនឹងបញ្ហាប្រឈមជាច្រើនទៀតផងដែរ ដែលមានឫសគល់កើតចេញពីបទដ្ឋានសង្គម ដែលប៉ះពាល់ដល់សេរីភាពខាងការបញ្ចេញមតិ។ អ្នកការពារសិទ្ធិមនុស្សជាស្ត្រី ៦នាក់ ដែលបានផ្តល់សម្ភាសន៍សម្រាប់របាយការណ៍នេះបានលើកឡើងថាពួកគេប្រឈមនឹងបញ្ហាដោយសារតែយេនឌ័ររបស់ខ្លួន។ អ្នកផ្តល់សម្ភាសន៍ ៥នាក់ បានលើកឡើងថាធ្លាប់រងការរើសអើងក្នុងនោះមានបីនាក់បាននិយាយថាខ្លួនក៏ធ្លាប់ត្រូវបានគេរើសអើងដោយសារជាតិពិន្ទុរបស់ខ្លួនផងដែរ។ អ្នកផ្តល់សម្ភាសម្នាក់បានបង្ហាញថា សមាជិកសហគមន៍របស់អ្នកស្រីមិនមានជំនឿចិត្តលើអ្នកការពារសិទ្ធិមនុស្សជាស្ត្រីក្នុងអំឡុងពេលកិច្ចប្រជុំ ខណៈអ្នកផ្សេងទៀតបាននិយាយថា អ្នកការពារសិទ្ធិមនុស្សជាស្ត្រីរងការមាក់ងាយពីសំណាក់បុរសដែលពុំមែនជាជនជាតិដើមភាគតិច និងអ្នកភូមិជាស្ត្រីដូចគ្នា។ ជាចុងក្រោយ ព្រមទាំងបានលើកឡើងថាប្រឈមនឹងការរើសអើងពីមន្ត្រីរដ្ឋាភិបាល ដោយសារតែអ្នកស្រីជាស្ត្រីមេម៉ាយ។ ករណីដូចគ្នានេះ អ្នកផ្តល់សម្ភាសម្នាក់ក្នុងចំណោមអ្នកការពារសិទ្ធិមនុស្សជាស្ត្រីច្រើននាក់បាននិយាយថា អ្នកស្រីមិនទទួលបានការលើកទឹកចិត្តពីគ្រួសាររបស់អ្នកស្រីទេ។ អ្នកការពារសិទ្ធិមនុស្សជាស្ត្រីបីនាក់ទៀតក៏បានគូសបញ្ជាក់ផងដែរថា យេនឌ័ររបស់ពួកគេធ្វើឱ្យកាន់តែប្រឈមក្នុងការចូលរួមក្នុងគំនិតផ្តួចផ្តើមការពារព្រៃឈើ និងដីធ្លីក្នុងតំបន់ ដូចជា ការល្បាតសហគមន៍

---

[102] ក្រុមប្រឹក្សាសិទ្ធិមនុស្ស ក្រុមការងារស្តីពីការឃុំខ្លួនតាមអំពើចិត្ត, "សេចក្តីសន្និដ្ឋានអនុម័តដោយក្រុមការងារស្តីពីការឃុំខ្លួនតាមអំពើចិត្តនៅក្នុងកិច្ចប្រជុំលើកទី៩៦, ២៧ មីនា-០៥ មេសា ២០២៣"។ (A/HRC/WGAD/2023/5)។

[103] ផុន សុជីវ័ត្ន, "សកម្មជននៅបឹងតាមោករត់ភៀសខ្លួនទៅកាន់ប្រទេសថៃ ស្វែងការជ្រកកោនក្នុងឋានៈជាជនភៀសខ្លួន"។ (ខេមបូចា ២១ សីហា ២០២៣)។

ដោយអ្នកផ្តល់សម្ភាសម្នាក់ធ្វើការកត់សម្គាល់ថាអ្នកការពារសិទ្ធិមនុស្សជាស្ត្រីប្រឈមនឹងហានិភ័យខ្ពស់ដោយសារការប្រមាថមាក់ងាយ។

បន្ថែមលើករណីខាងលើ បុរសអ្នកការពារសិទ្ធិមនុស្សចំនួនបីនាក់ដែលបានផ្តល់សម្ភាសសម្រាប់របាយការណ៍នេះបានបង្ហាញថាអ្នកការពារសិទ្ធិមនុស្សជាស្ត្រីកង្វះការគាំទ្រ ឬការលើកទឹកចិត្តពីគ្រួសាររបស់ពួកគេ។ អ្នកផ្តល់សម្ភាសម្នាក់បានលើកឡើងថាអ្នកការពារសិទ្ធិមនុស្សជាស្ត្រីជារឿយៗរងការរើសអើងពីសំណាក់បុរស និងបានគូសបញ្ជាក់ថា មានអ្នកចូលរួមជាស្ត្រីតិចជាងបុរសក្នុងសកម្មភាពនានារៀបចំឡើងដោយអង្គការមិនមែនរដ្ឋាភិបាល។ អ្នកផ្តល់សម្ភាសម្នាក់ទៀតបានប្រាប់ថាអ្នកការពារសិទ្ធិមនុស្សជាស្ត្រីងាយប្រឈមនឹងការបំពានលើរាងកាយ និងផ្លូវភេទ ដោយបន្ថែមថាជាការប្រឈមសម្រាប់ពួកគេក្នុងការធ្វើដំណើរទៅកាន់គោលដៅឆ្ងាយដើម្បីបំពេញការងារ។

## ៤.៣.ស្ថានភាពនៃការទទួលព័ត៌មាន




*ការចេញផ្សាយសាលក្រម និងការរក្សាទុកបណ្ណសារ*

សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ មានន័យថា ការប្រកាសសាលក្រមទាំងក្នុងដំណើរការនីតិវិធីរដ្ឋប្បវេណី និងព្រហ្មទណ្ឌត្រូវធ្វើឡើងជាសាធារណៈ។ តម្លាភាពនៃនីតិវិធីតុលាការ មានបញ្ហាមួយកើតឡើងទាក់ទងនឹងសិទ្ធិក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ព្រោះមានបញ្ហាក្នុងការទទួលព័ត៌មាន៖ សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ គឺជាគន្លឹះសំខាន់ដែលធានានូវតម្លាភាព និងគណនេយ្យភាព ព្រោះសិទ្ធិនេះកំណត់នូវលទ្ធភាពរបស់ចៅក្រមក្នុងការធ្វើសកម្មភាពតាមអំពើចិត្ត ប៉ុន្តែទោះជាយ៉ាងណា តម្លាភាពនៃប្រព័ន្ធតុលាការនៅតែជាបំណងប្រាថ្នាដែលចង់បានខ្លាំងនៅកម្ពុជា។ លើកលែងតែក្រុមប្រឹក្សាធម្មនុញ្ញដែលតែងតែចេញផ្សាយសេចក្តីសម្រេចរបស់ខ្លួនទៀងទាត់[104] និងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)

[104] គេហទំព័ររបស់ក្រុមប្រឹក្សាធម្មនុញ្ញកម្ពុជា។

ដែលបានផ្សព្វផ្សាយសាលក្រមរបស់ខ្លួនយ៉ាងទូលំទូលាយ ចំណែកសាលក្រមចេញពីតុលាការផ្សេងៗនៅតែពិបាកស្វែងរកក្នុងអំឡុងពេលនៃរបាយការណ៍នេះ។

*តាមរយៈបណ្តុំគោលការណ៍ដែលបានធ្វើបច្ចុប្បន្នភាព ដើម្បីការពារ និងលើកកម្ពស់សិទ្ធិមនុស្សតាមរយៈវិធានការលុបបំបាត់និទណ្ឌភាពអង្គការសហប្រជាជាតិបានចែងថា "មនុស្សគ្រប់រូបមានសិទ្ធិមិនអាចលុបបំបាត់បានក្នុងការដឹងការពិតអំពីព្រឹត្តិការណ៍អតីតកាលទាក់ទងនឹងការប្រព្រឹត្តឧក្រិដ្ឋកម្មឃោរឃៅ និងអំពីកាលៈទេសៈ និងហេតុផលដែលនាំទៅកេការប្រព្រឹត្តនូវឧក្រិដ្ឋកម្មទាំងនោះ តាមរយៈការរំលោភបំពានក្នុងទ្រង់ទ្រាយធំ ឬជាលក្ខណៈប្រព័ន្ធ"។*[105] ដើម្បីផ្តល់ប្រសិទ្ធភាពដល់ការអនុវត្តសិទ្ធិដឹងការពិតនេះ អង្គការសហប្រជាជាតិបានអំពាវនាវដល់រដ្ឋនានាឱ្យចាត់វិធានការផ្សេងៗ ដោយបញ្ចូលការធានានូវការរក្សាទុក និងការទទួលបានបណ្ណសារពាក់ព័ន្ធនឹងការរំលោភបំពានសិទ្ធិមនុស្ស និងច្បាប់មនុស្សធម៌។[106]

នៅខែសីហា ឆ្នាំ២០២១ រដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិបានចុះហត្ថលេខាលើសេចក្តីបន្ថែមនៃកិច្ចព្រមព្រៀងស្តីពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)។ តាមរយៈសេចក្តីបន្ថែមនេះ អ.វ.ត.ក មានភារកិច្ចកាត់ទោសមេដឹកនាំខ្មែរក្រហម និងអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងរបបខ្មែរក្រហមពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ នៅកម្ពុជា ដោយបានទទួលសិទ្ធិអំណាចដែលនៅសល់ ដែលនឹងចូលជាធរមាននៅពេលបញ្ចប់មុខងាររបស់ខ្លួន។ នៅក្នុងមាត្រា៣ នៃឧបសម្ព័ន្ធបន្ថែម ដែលផ្តោតលើបណ្ណសារ អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាយល់ស្របគ្នាថា ការរក្សាទុកបណ្ណសាររបស់ អ.វ.ត.ក គឺ "សំខាន់" ហើយបណ្ណសារទាំងនោះត្រូវតែ "អាចចូលប្រើប្រាស់បានយ៉ាងទូលំទូលាយតាមដែលអាចធ្វើទៅបាន"។[107]បន្ទាប់ពី អ.វ.ត.ក បានប្រកាសសេចក្តីសម្រេចចុងក្រោយរបស់ខ្លួននៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២២ អ្នកនាំពាក្យ អ.វ.ត.ក លោក នេត្រ ភក្ត្រា បានបញ្ជាក់ថា ការបង្កើតប្រព័ន្ធគ្រប់គ្រង និងរក្សាទុកបណ្ណសាររបស់ អ.វ.ត.ក ជាកិច្ចការដែលនៅសល់របស់ អ.វ.ត.ក ដែលនឹងត្រូវអនុវត្តក្នុងរយៈពេលបីឆ្នាំខាងមុខ។[108]

ការវិវត្តគួរឱ្យកត់សម្គាល់ទាក់ទងនឹងបណ្ណសាររបស់ អ.វ.ត.ក បានធ្វើឡើងក្នុងអំឡុងពេលនៃរបាយការណ៍។ នៅថ្ងៃទី១ ខែមករា ឆ្នាំ ២០២៣ អ.វ.ត.ក បានក្លាយជាសមាជិកនៃក្រុមប្រឹក្សាអន្តរជាតិស្តីពីបណ្ណសារ (ICA) ជាជំហានឆ្ពោះទៅការអនុវត្តមាត្រា ៣ នៃឧបសម្ព័ន្ធបន្ថែម និងពង្រឹងសមត្ថភាពរបស់ខ្លួនក្នុងការធ្វើឱ្យការកាន់កាប់របស់ខ្លួនកាន់តែទូលំទូលាយតាមដែលអាចធ្វើទៅបាន។[109] នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៣ ប្រទេសជប៉ុនបានសម្រេចចិត្តផ្តល់វិភាគទានចំនួន ២២០,០០០ ដុល្លាសម្រាប់ទ្រទ្រង់ផ្នែកបណ្ណសាររបស់ អ.វ.ត.ក ដើម្បី

---

105 អង្គការសហប្រជាជាតិ, "បណ្តុំគោលការណ៍ដែលបានធ្វើបច្ចុប្បន្នភាពដើម្បីការការពារ និងការលើកកម្ពស់សិទ្ធិមនុស្សតាមរយៈសកម្មភាពដើម្បីលុបបំបាត់និទណ្ឌភាព"។ (ឯកសារ អ.ស.ប E/CN.4/2005/102/Add.1 ០៨ កុម្ភៈ ២០០៥) គោលការណ៍ទី២។

106 ដូចខាងលើ, គោលការណ៍ទី៥

107 អ.វ.ត.ក, "កិច្ចព្រមព្រៀងបន្ថែមរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ទាក់ទងនឹងការកាត់ទោសតាមច្បាប់កម្ពុជា អំពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ស្តីពីការរៀបចំអន្តរកាល និងការបញ្ចប់ការងាររបស់អង្គជំនុំជម្រះវិសាមញ្ញ"។ (អ.វ.ត.ក, សីហា ២០២១), មាត្រា ៣។

108 ឡាយ សាមាន, "ទទួលបានយុត្តិធម៌៖ សាលាក្តីខ្មែរក្រហមបិទសំណុំរឿងចុងក្រោយ"។ (ភ្នំពេញប៉ុស្តិ៍, ២២ កញ្ញា ២០២២)។

109 អ.វ.ត.ក, "អ.វ.ត.ក ចូលរួមក្រុមប្រឹក្សាអន្តរជាតិស្តីពីបណ្ណសារ"។ (១១ មករា ២០២៣)។

គាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន។[110] នៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៣ អ.វ.ត.ក បានបើកសម្ពោធមជ្ឈមណ្ឌលធនធានមួយក្នុងរាជធានីភ្នំពេញ។ មជ្ឈមណ្ឌលនេះមានជាតុផ្សំផ្សេងទៀតនៃបណ្ណាល័យនិងមជ្ឈមណ្ឌលស្រាវជ្រាវដែលបើកចំហជាសាធារណៈ និងបណ្ណសារឌីជីថល និងការថតចម្លងច្បាប់ដើមស្របតាមស្តង់ដាអន្តរជាតិ។ បន្ទាប់ពីពិធីសម្ពោធ សកម្មភាពជាបន្តបន្ទាប់ដូចជាការបង្ហោះវីដេអូខ្លីនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម ដើម្បីផ្សព្វផ្សាយព័ត៌មានអំពីការងាររបស់អង្គជំនុំជម្រះក្នុងចំណោមសាធារណជន។[111]

### *ការរឹតបន្តឹងការចូលប្រើគេហទំព័រថ្មី*




យោងតាមវិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយដែលមានទីស្នាក់ការនៅរាជធានីភ្នំពេញ រាជរដ្ឋាភិបាលបានបិទខ្ទប់ក្នុងការប្រើប្រាស់គេហទំព័រសរុបចំនួន៤៣ នៅឆ្នាំ២០២២ ដោយរួមបញ្ចូលគេហទំព័រ ចំនួន៦របស់អង្គភាពសារព័ត៌មានថ្មី។[112] ការតាមដាននៅក្នុងប្រព័ន្ធផ្សព្វផ្សាយរបស់ ម.ស.ម.ក បានបង្ហាញថាការបិទខ្ទប់នេះនៅតែបន្តកើតមាននៅក្នុងឆ្នាំ២០២៣ ដែលហាក់បីដូចជាកើនឡើងច្រើនជាងមុន។ នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៣ ប៉ុន្មានម៉ោងមុនថ្ងៃបិទវីអូឌី មន្ត្រីមួយរូបមកពីនិយ័តករទូរគមនាគមន៍កម្ពុជា (ទ.ទ.ក) បានបង្កើតក្រុមតេឡេក្រាមមួយ បង្ហាញពីអ្នកផ្គត់ផ្គង់សេវាអ៊ីនធឺណិតទាំងអស់ដែលបានចុះបញ្ជីនៅក្នុងប្រទេស។ មន្ត្រីរូបនេះ បានបង្គាប់ឱ្យអ្នកផ្គត់ផ្គង់សេវាអ៊ីនធឺណិតទាំងអស់នោះបិទខ្ទប់ក្នុងការចូលទៅកាន់គេហទំព័ររបស់វីអូឌីជាភាសាអង់គ្លេស និងភាសាខ្មែរឱ្យបានមុនម៉ោង១០នាទីព្រឹក។ ពួកគេបានធ្វើការបិទខ្ទប់បើទោះបីជានៅក្នុងនោះមានចន្លោះប្រហោងផ្នែកបច្ចេកទេសខ្លះៗ ដែលអនុញ្ញាតឱ្យអ្នកប្រើប្រាស់ អ៊ីនធឺណិតមួយចំនួនអាចចូលទៅកាន់គេហទំព័រនៅប៉ុន្មានថ្ងៃបន្ទាប់ក៏បាន។ សកម្មជនសិទ្ធិមនុស្ស បានលើកឡើងពីក្តីបារម្ភចំពោះការបិទខ្ទប់គេហទំព័ររបស់វីអូឌីក្នុងរយៈពេលដ៏ឆាប់រហ័សបែបនេះ និងព្រមានថារាជរដ្ឋាភិបាលក៏កំពុងរៀបចំ

---

[110] បុគ្គលិកភ្នំពេញប៉ុស្តិ៍, "ជប៉ុនផ្តល់មូលនិធិចំនួន ២២០,០០០ ដុល្លារដល់ អ.វ.ត.ក."។ (ភ្នំពេញប៉ុស្តិ៍, ២៧ មករា ២០២៣)។
[111] អ.វ.ត.ក, "អ.វ.ត.ក សម្ពោធមជ្ឈមណ្ឌលធនធាន និងបើកដំណើរការវីដេអូខ្លីស្តីពីការអប់រំ និងផ្សព្វផ្សាយ"។ (២៧ កញ្ញា ២០២៣)។
[112] Jack Brook, "អ្នកផ្គត់ផ្គង់សេវាអ៊ីនធឺណិតនៅកម្ពុជាបានប្រាប់ឱ្យបិទខ្ទប់ស្ថាប័នផ្សព្វផ្សាយឯករាជ្យ"។ (Nikkei Asia, ២០ កុម្ភៈ ២០២៣)។

ផែនការរឹតបន្តឹងការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិតនៅក្នុងដំណើរការនៃការបោះឆ្នោតថ្នាក់ជាតិ នៅខែកក្កដា ឆ្នាំ២០២៣។[113]

នៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៣ ទ.ទ.ក បានចេញលិខិតមួយជូនដំណឹងទៅអ្នកផ្គត់ផ្គង់សេវាអ៊ីនធឺណេតធ្វើការបិទខ្ទប់ក្នុងការចូលទៅកាន់គេហទំព័រ និងគណនីផ្សព្វផ្សាយសង្គមរបស់ខេមបូឌាដេលី វិទ្យុអាស៊ីសេរី និងកំណត់ត្រា ដោយមិនបង្អង់។ លិខិតនោះ បានបង្ហាញថាការរាយការណ៍របស់ពួកគេអាចធ្វើឱ្យមាន "ការភាន់ច្រឡំ និងប៉ះពាល់ដល់កិត្តិយស និងកិត្យានុភាពរបស់រដ្ឋាភិបាល"។ អង្គភាពសារព័ត៌មាននោះក៏ត្រូវបានចោទប្រកាន់ថាមិនបានបំពេញតាមលក្ខខណ្ឌរបស់ក្រសួងព័ត៌មានក្នុងការធ្វើអាជីវកម្ម។[114] ខេមបូឌាដេលី និងវិទ្យុអាស៊ីសេរី កំពុងប្រតិបត្តិការពីក្រៅប្រទេស បន្ទាប់ពីពួកគេមិនមានជម្រើសអ្វីក្រៅពីបិទប្រតិបត្តិការរបស់ខ្លួននៅប្រទេសកម្ពុជាកាលពីឆ្នាំ២០១៧។ ចំពោះកំណត់ត្រា គេហទំព័រនេះត្រូវបានដាក់ឱ្យប្រើប្រាស់នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៣ ដោយមជ្ឈមណ្ឌលកម្ពុជាសម្រាប់ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យដើម្បីធ្វើការផ្ទុកទិន្នន័យជាភាសាអង់គ្លេស និងភាសាខ្មែរដែលបានផ្សព្វផ្សាយជាសាធារណៈសម្រាប់ប្រើប្រាស់។ នៅក្នុងនោះមានបណ្ដុំទិន្នន័យសំខាន់ៗចំនួនពីររួមមាន "រាជកិច្ច" និង "បញ្ហាសង្គម"។ នៅក្នុងផ្នែករាជកិច្ច ចងក្រងឯកសារទាក់ទងនឹងសេចក្ដីសម្រេចចម្បងៗរបស់រាជរដ្ឋាភិបាល ចំណែកឯផ្នែកបញ្ហាសង្គម ធ្វើការប្រមូល និងវិភាគទិន្នន័យដែលទាក់ទងទៅនឹងវិវាទដីធ្លីនៅទូទាំងប្រទេស។[115]

អង្គការអ្នករាយការណ៍គ្មានព្រំដែន បានប្រតិកម្មចំពោះការហាមប្រាមមួយនេះដោយអំពាវនាវឱ្យរដ្ឋាភិបាលផ្លាស់ប្ដូរការបង្គាប់ឱ្យបិទខ្ទប់ភ្លាមៗនេះ និងបញ្ឈប់ការវាយប្រហារម្ដងហើយម្ដងទៀតលើសេរីភាពសារព័ត៌មាន។ នាយកការិយាល័យប្រចាំនៅតំបន់អាស៊ីប៉ាស៊ីហ្វិករបស់អង្គការនេះ ក៏បានធ្វើការរិះគន់យ៉ាងធ្ងន់ធ្ងរទៅរដ្ឋាភិបាលថា "បន្ទាប់ពីបិទទាំងស្រុងនូវអង្គភាពសារព័ត៌មានសេរីនៅក្នុងប្រទេសកម្ពុជា រដ្ឋាភិបាលរបស់លោក ហ៊ុន សែន ឥឡូវនេះកំពុងដាក់គោលដៅលើប្រព័ន្ធផ្សព្វផ្សាយដែលដំណើរការនៅក្រៅប្រទេសដើម្បីបិទការផ្សព្វផ្សាយព័ត៌មានកុំឱ្យមានប្រសិទ្ធភាព"។[116] លោក Shawn Crispin ដែលជាអ្នកតំណាងជាន់ខ្ពស់ប្រចាំតំបន់អាស៊ីអាគ្នេយ៍នៃគណៈកម្មាធិការការពារអ្នកសារព័ត៌មាន បាននិយាយដោយចំៗថា "ការបញ្ជាឱ្យបិទនូវដំណើរការរបស់ខេមបូឌា ដេលី វិទ្យុអាស៊ីសេរី និងកំណត់ត្រា គឺជាការប៉ុនប៉ងដ៏សាហាវមួយក្នុងការទប់ស្កាត់ការរាយការណ៍ព័ត៌មានដោយសេរីអំពីការបោះឆ្នោតសកលនាពេលខាងមុខនៅក្នុងប្រទេស"។ លោកបានបន្ថែម

---

113 ដូចខាងលើ។

114 អាស៊ីសេរី, "រដ្ឋាភិបាលរបស់ ហ៊ុន សែន បញ្ជាឱ្យវិទ្យុអាស៊ីសេរី, គេហទំព័ររបស់អង្គភាពសារព័ត៌មានផ្សេងទៀតបិទខ្ទប់"។(អាស៊ីសេរី, ១៧ មករា ២០២៣); នឿន ដារីន, លាស់ លីបលីប, "រដ្ឋាភិបាលបិទគេហទំព័រសារព័ត៌មានមួយចំនួន នៅមុនការបោះឆ្នោត"។ (វីអូអេ, ១៧ កក្កដា ២០២៣)

115 ផុន សុទ្ធីរ័ត្ន, "វេបសាយទិន្នន័យថ្មីមួយដាក់ដំណើរការដើម្បីឱ្យប្រជាពលរដ្ឋអាចទទួលបានព័ត៌មានសាធារណៈ"។ (ខេមបូចាព័ត៌មាន, ២១ មិថុនា ២០២៣)

116 RSF, "ប្រទេសកម្ពុជា៖ ប៉ុន្មានថ្ងៃមុនការបោះឆ្នោតជាសកល, រដ្ឋាភិបាលបិទខ្ទប់ប្រព័ន្ធផ្សព្វផ្សាយតាមអ៊ីនធឺណិតជាច្រើន"។ (២១ កក្កដា ២០២៣)

ថាកម្ពុជានឹងក្លាយជាប្រទេសដែលគ្រាន់តែមានឈ្មោះថាជាប្រទេសប្រជាធិបតេយ្យ ប្រសិនបើអាជ្ញាធរនៅតែបង្កបញ្ហាជាមួយអង្គភាពសារព័ត៌មាន ហើយធ្វើការគាបសង្កត់លើពួកគេ។[117]

### *អ្នកសារព័ត៌មានជួបការលំបាកក្នុងទទួលបានព័ត៌មានពីមន្ត្រីសាធារណៈ*

សម្ភាសន៍ដែលធ្វើឡើងជាមួយអ្នកសារព័ត៌មានសម្រាប់របាយការណ៍នេះ បង្ហាញថាអ្នកសារព័ត៌មានដែលធ្វើការរាយការណ៍ពីករណីបរិស្ថានជួបប្រទះការលំបាកមួយចំនួននៅពេលដែលព្យាយាមស្វែងរកព័ត៌មាន។ អ្នកសារព័ត៌មានជាបុរសទាំង ៦នាក់ ដែលត្រូវបានសម្ភាសន៍ បាននិយាយថាពួកគេពិបាកស្វែងរកព័ត៌មានដែលចាំបាច់ក្នុងការសរសេរនូវអត្ថបទរបស់ពួកគេ។ ក្នុងចំណោមអ្នកទាំងអស់នោះ ៤នាក់ បាននិយាយថាពួកគេមានការលំបាកក្នុងការទទួលព័ត៌មានពីអាជ្ញាធរដែលពាក់ព័ន្ធ។ មួយនាក់បានកត់សម្គាល់ថាអាជ្ញាធរមិនសហការជាមួយអ្នកសារព័ត៌មាន បដិសេធផ្តល់បទសម្ភាសន៍ ឬហាមឃាត់ដាច់ខាតមិនឱ្យអ្នកសារព័ត៌មានរាយការណ៍អំពីព្រឹត្តិការណ៍ជាក់លាក់ណាមួយ។ អ្នកផ្តល់សម្ភាសន៍ម្នាក់ទៀតបាននិយាយថា មន្ត្រីរដ្ឋាភិបាលជារឿយៗច្រានចោលការស្នើសុំព័ត៌មាន និងចោទរូបគេថាបានផ្សព្វផ្សាយបញ្ហាក្នុងស្រុកដើម្បី "ផ្គាប់ចិត្តជនបរទេស"។ អ្នកផ្តល់សម្ភាសន៍ទីបី បានប្រឈមមុខនឹងបញ្ហាស្រដៀងគ្នានេះ និងបានបញ្ជាក់ពីភាពញឹកញាប់ជាងនេះថាមន្ត្រីរដ្ឋាភិបាល និងអ្នកនាំពាក្យចោទប្រកាន់អ្នកសារព័ត៌មានឯករាជ្យថាបានបម្រើផលប្រយោជន៍ជនបរទេស ឬក្រុមប្រឆាំង។ នៅក្នុងសម្តីរបស់អ្នកផ្តល់សម្ភាសន៍ទីបួន "មានភាពងាយស្រួលក្នុងការទៅសម្ភាសន៍ប្រជាពលរដ្ឋ ប៉ុន្តែពិបាកក្នុងការទៅសម្ភាសន៍អាជ្ញាធរ"។

> *"អ្វីដែលខ្ញុំគិតថាលំបាកបំផុតនៅក្នុងអាជីពជាអ្នកសារព័ត៌មានជិត១០ឆ្នាំ គឺការស្វែងរកប្រភពនៃព័ត៌មាន ហើយជាពិសេសទៅទៀតនោះ គឺទទួលបានការឆ្លើយតបពីរដ្ឋាភិបាល។"*
>
> អ្នកសារព័ត៌មានសម្ភាសន៍ដោយម.ស.ម.ក ចាប់ពីខែវិច្ឆិកា២០២២ ដល់ខែមីនា ឆ្នាំ២០២៣

នៅខែមីនា ឆ្នាំ២០២២ រដ្ឋមន្ត្រីក្រសួងព័ត៌មាន លោក ខៀវ កាញារីទ្ធ បានជំរុញឱ្យអ្នកនាំពាក្យរបស់រដ្ឋាភិបាលឆ្លើយតបនឹងសំណើ "ឱ្យទាន់ពេលវេលា ដើម្បីផ្សព្វផ្សាយព័ត៌មានឱ្យបានទូលំទូលាយដល់សាធារណជន និងប្រជាពលរដ្ឋនៅថ្នាក់មូលដ្ឋាន"។ លោកក៏អំពាវនាវឱ្យមន្ត្រីសារព័ត៌មានរបស់រដ្ឋាភិបាលកុំធ្វើការរើសអើងទៅកាន់សមាជិកនៃអង្គភាពសារព័ត៌មាន។[118] ទោះបីជាយ៉ាងណាក៏ដោយ ម.ស.ម.ក បានកត់សម្គាល់ថា អ្នកនាំពាក្យដែលអ្នកសារព័ត៌មានឯករាជ្យទាក់ទងទៅនៅក្នុងអំឡុងពេលនៃរបាយការណ៍ ជារឿយៗមិនអាច ឬមិនចង់ផ្តល់នូវព័ត៌មាន ឬមតិយោបល់ទៅលើករណីរសើបនោះទេ។[119]

---

117 Committee to Protect Journalists, "ប្រទេសកម្ពុជាបិទខ្ទប់គេហទំព័រ, គណនីផ្សព្វផ្សាយសង្គមចំនួន៣មុនការបោះឆ្នោតនៅថ្ងៃអាទិត្យ"។ (២០ កក្កដា ២០២៣)

118 "រដ្ឋមន្ត្រីព័ត៌មានកម្ពុជាប្រាប់ទៅអ្នកនាំពាក្យរដ្ឋាភិបាលធ្វើការជាមួយសារព័ត៌មានឯករាជ្យ"។ (អាស៊ីសេរី, ២៥ មីនា ២០២៣)

119 កត់សម្គាល់ឃើញនៅ៖ ស៊ើង និមល់, Leila Goldstein, "ក្រុមហ៊ុន Meta ច្រានចោលអនុសាសន៍ដែលឱ្យព្យួរគណនីហ្វេសប៊ុកអតីតនាយករដ្ឋមន្ត្រី ហ៊ុន សែន"។ (ខេមបូចា, ៣១ សីហា ២០២៣); អាស៊ីសេរី, "ហ៊ុន សែន រក្សាការតំឡើងតំណែងក្នុងវិស័យយោធាសម្រាប់កូនៗច្បង"។ (RFA, ២២ មីនា ២០២៣); ប្រាក់ ចាន់ថុល, "ក្រសួងអប់រំបញ្ជាឱ្យសាលាបិទជាបណ្តោះអាសន្ននៅក្នុងរយៈពេល

ពាក់ព័ន្ធនឹងបញ្ហានេះ នៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៣ អ្នកនាំពាក្យក្រសួងមហាផ្ទៃ លោក ខៀវ សុភ័គ បានគំរាមអ្នកសារព័ត៌មានខេមបូចា លោក ឃួន ណារីម ក្នុងអំឡុងពេលនៃបទសម្ភាសន៍មួយតាមទូរស័ព្ទថា លោកអាចជាប់គុកដោយសារតែសួរសំណួរអំពីគណបក្សភ្លើងទៀនដែលជាគណបក្សប្រឆាំង។ កាលពីដើមខែឧសភា លោក សុភ័គ បានបដិសេធផ្តល់ព័ត៌មានទៅឱ្យលោក ណារីម ម្តងរួចមកហើយអំពីលទ្ធផលនៃកិច្ចប្រជុំមួយរវាងក្រសួងមហាផ្ទៃ និងថ្នាក់ដឹកនាំគណបក្សភ្លើងទៀន ដោយជំនួសមកវិញដោយការសួរលោកពីមូលនិធិរបស់ខេមបូចា ហើយនិយាយដែលបង្កប់ន័យថាគាត់ជា "អ្នកសារព័ត៌មានស៊ីឈ្នួលធ្វើការឱ្យបរទេស"។[120]

លើសពីនេះទៅទៀត នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២២ តំណាងរបស់ក្រសួងព័ត៌មានជាច្រើនរូបបានហាមប្រាមអ្នកសារព័ត៌មានមកពី **វីអូឌី និងវីអូអេ** ក្នុងការចូលរួមសន្និសីទកាសែតរបស់លោក ហ៊ុន សែន ដែលជានាយករដ្ឋមន្ត្រីនៅពេលនោះ ដោយមិនបានពន្យល់បន្ទាប់ពីកិច្ចប្រជុំកំពូលអាស៊ាន។ អ្នកសារព័ត៌មានត្រូវបានជូនដំណឹងជាមុនថា ពួកគេនឹងអាចសួរសំណួរអំពីកិច្ចប្រជុំកំពូល ក្នុងអំឡុងពេលនៃការរៀបចំ។ លោក ផុស សុវណ្ណ អគ្គនាយកនៃក្រសួងព័ត៌មានបានពន្យល់នៅថ្ងៃបន្ទាប់ថា ការហាមប្រាមនេះគឺដោយសារអ្នកសារព័ត៌មានមកពីអង្គភាពទាំងអស់នោះមិនដែលចូលរួមនៅក្នុងសន្និសីទកាសែតទេ ហើយនៅពេលដែលពួកគេចូលរួម ពួកគេ "យកតែពីរបីចំណុចប៉ុណ្ណោះ" ចេញពីសុន្ទរកថាដើម្បីសរសេរអត្ថបទ។[121] ស្រដៀងគ្នានេះដែរ នៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ មន្ត្រីរដ្ឋសភាបានបង្ខំអ្នកយកព័ត៌មាននៃសំឡេងសហរដ្ឋអាមេរិក (VOA) លោក លីប លីប ឱ្យចេញពីសន្និសីទសារព័ត៌មានស្តីពីការបោះឆ្នោតជ្រើសរើសលោក ហ៊ុន ម៉ាណែត ជានាយករដ្ឋមន្ត្រី។ ដំបូងឡើយ លោក លីប លីប ត្រូវបានអនុញ្ញាតឱ្យចូលក្នុងបន្ទប់សារព័ត៌មាន ហើយគ្មានការពន្យល់ណាមួយត្រូវបានផ្តល់ឱ្យសម្រាប់ការបណ្តេញលោកចេញនោះឡើយ។[122] ហេតុការណ៍នេះ បង្ហាញឱ្យឃើញពីការរើសអើងនៅក្នុងសង្គមចំពោះអ្នកសារព័ត៌មានដែលធ្វើការនៅក្នុងអង្គភាពសារព័ត៌មានដែលជាប្រចាំរាយការណ៍ពីបញ្ហារសើប។

---

ពេលនៃកិច្ចប្រជុំកំពូលអាស៊ាន"។(Kiripost, ១៣ កញ្ញា ២០២២); Colin Meyn, "បៃឌិន ដាក់សម្ពាធលើលោក ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជាចំពោះបញ្ហាសកម្មជនជាប់ពន្ធនាគារ និងសេរីភាពនយោបាយ។" (The Hill, ១៣ វិច្ឆិកា ២០២២); AFP, "ប្រទេសកម្ពុជាបានជំរុញឱ្យបញ្ឈប់ការបណ្តេញចេញ។" (Taipei Times, ១ មេសា ២០២៣)។

120 ខេមបូចា, "ស្ថានភាពសារព័ត៌មាននៅកម្ពុជា៖ របាយការណ៍ត្រួតពិនិត្យប្រចាំត្រីមាស ពីខែមេសា ដល់ខែមិថុនា ឆ្នាំ២០២៣"។, លេខផ្សាយ០៨, ទំព័រ១០។

121 Saut Sok Prathna, "អ្នកសារព័ត៌មានវីអូឌី និងវីអូអេបានហាមប្រាមមិនឱ្យយកសន្ទរកថានាយករដ្ឋមន្ត្រីក្រោយកិច្ចប្រជុំកំពូលអាស៊ាន។" (*វីអូឌី*, ១៥ វិច្ឆិកា ២០២២)

122 ខេមបូចា, "ស្ថានភាពសារព័ត៌មាននៅកម្ពុជា៖ របាយការណ៍ត្រួតពិនិត្យប្រចាំត្រីមាស ពីខែកក្កដា ដល់ ខែកញ្ញា ឆ្នាំ២០២៣"។ លេខផ្សាយ០៩, ទំព័រ១៤។

### *ដំណើរការឆ្ពោះទៅរកការអនុម័តច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន*

នៅឆ្នាំ២០០៧ រាជរដ្ឋាភិបាលបានទទួលស្គាល់ជាលើកដំបូងពីភាពចាំបាច់នៃច្បាប់ដែលចែងពីសេរីភាពសារព័ត៌មានហើយបានរៀបចំសេចក្តីព្រាងគោលនយោបាយស្តីពីការទទួលព័ត៌មាននៅឆ្នាំ២០០៧។[123]

ទោះបីជាយ៉ាងណាក៏ដោយ មួយទស្សវត្សរ៍កន្លះក្រោយមក សេចក្តីព្រាងគោលនយោបាយនេះមិនទាន់បានក្លាយទៅជាច្បាប់មួយចែងពីការទទួលបានព័ត៌មាននៅឡើយ។ ក្រសួងពាក់ព័ន្ធបានបញ្ចប់នូវការកែសម្រួលសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាននៅខែសីហា ឆ្នាំ២០១៩។[124] នៅខែឧសភា ឆ្នាំ២០២១ ក្រសួងព័ត៌មានបានសន្យាបញ្ចប់ការពិគ្រោះយោបល់លើសេចក្តីព្រាងច្បាប់នេះជាមួយក្រសួងយុត្តិធម៌ក្នុងពេលឆាប់ៗ និងនិយាយថាសេចក្តីព្រាងនេះនឹងត្រូវដាក់ជូនទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋសភាជាតិ ដើម្បីអនុម័តឱ្យបានមុនបំណាច់ឆ្នាំ២០២១។[125] នៅចុងឆ្នាំ២០២១ ក្រសួងព័ត៌មានបាននិយាយថាដំណើរការនៃការព្រាងច្បាប់នេះគឺស្ថិតនៅក្នុងដំណាក់កាលចុងក្រោយ ហើយការបញ្ចប់នៃសេចក្តីព្រាងច្បាប់នេះនឹងត្រូវបានពន្លឿនដើម្បីបានដាក់ជូនទីស្តីការគណៈរដ្ឋមន្ត្រី។[126]

**CSOs calling for prompt info access law drafting**

**Lay Samean** | Publication date 16 June 2022 | 21:23 ICT



Civil society organisation representatives submitted a petition to Prime Minister Hun Sen's Cabinet in Chaktomuk commune of the capital's Daun Penh district on June 16. Heng Chivoan

A group of 33 civil society organisations (CSOs) urged the intervention of Prime Minister Hun Sen to expedite the draft law on "access to information".

នៅខែមិថុនា ឆ្នាំ២០២២ អង្គការសង្គមស៊ីវិលចំនួន៣៣បានដាក់ញត្តិជូន លោក ហ៊ុន សែន ដែលជានាយករដ្ឋមន្ត្រីនៅក្នុងពេលនោះ ដើម្បីអំពាវនាវឱ្យអ្នកធ្វើច្បាប់ ឬតំណាងរាស្ត្រ ទទួលយកធាតុចូលរបស់ពួកគេទៅពិចារណា[127] កែសម្រួលសេចក្តីព្រាងច្បាប់ និងពន្លឿនឱ្យសេចក្តីព្រាងច្បាប់នេះក្លាយទៅជាច្បាប់។[128] ជាការកត់សម្គាល់ អង្គការសង្គមស៊ីវិលទាំងអស់នោះស្នើសុំឱ្យដកមាត្រា ២០ (៧) និង មាត្រា១៥ (៤)

---

123 ម៉ូនាស្រី (MoNASRI), "សិទ្ធិទទួលបានព័ត៌មាន៖ ក្របខណ្ឌគោលនយោបាយដាក់លាក់មួយសម្រាប់ប្រទេសកម្ពុជា"។ (២២ កក្កដា ២០០៧) ទំព័រទី៤;វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ, "សេចក្តីណែនាំទូទៅអំពីសិទ្ធិទទួលបានព័ត៌មាននៅប្រទេសកម្ពុជា"។ (សីហា ២០១០) ទំព័រទី១១។

124 វ៉ន ដារ៉ា, "ច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាននឹងត្រូវបានបញ្ចប់នៅក្នុងខែបន្ទាប់"។ (ភ្នំពេញប៉ុស្តិ៍, ២១ សីហា ២០១៩)។

125 វី សុខចាន់, "ច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាននឹងត្រូវបានអនុម័តនៅឆ្នាំនេះក្រសួងបានសន្យា"។ (ភ្នំពេញប៉ុស្តិ៍, ២៨ ឧសភា ២០២១)។

126 សរ សុជាតិ, "សេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មានស្ថិតនៅក្នុងដំណាក់កាលចុងក្រោយ និងត្រូវបានពន្លឿន"។ (ខ្មែរថាមស៍, ៥ វិច្ឆិកា ២០២១)។

127 ឃួន ណារីម, "អង្គការសង្គមស៊ីវិលអំពាវនាវឱ្យអនុម័តច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន"។ (ខេមបូចា, ១៦ មិថុនា ២០២២)។

128 ឡាយ សាមាន, "ការអំពាវនាវរបស់អង្គការសង្គមស៊ីវិលឱ្យបញ្ចប់សេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មានក្នុងពេលឆាប់ៗ" (ភ្នំពេញប៉ុស្តិ៍, ១៦ មិថុនា ២០២២)។

នៃសេចក្តីព្រាងច្បាប់ដែលអនុញ្ញាតឱ្យស្ថាប័នសាធារណៈបដិសេធការបញ្ចេញ "ព័ត៌មានសម្ងាត់ផ្សេងទៀត" និងកំណត់ រយៈពេល ៤០ថ្ងៃ មុននឹងការស្នើសុំម្តងទៀតអាចធ្វើឡើង។ ពួកគេក៏ជំរុញឱ្យកែសម្រួលខ្លឹមសារនៅក្នុងមាត្រាចំនួន៦ផ្សេងទៀត ដើម្បីបង្កើនការការពារអ្នកសារព័ត៌មាន។[129] ជាការឆ្លើយតប ក្រសួងព័ត៌មានបានរៀបចំកិច្ចប្រជុំដើម្បីត្រួតពិនិត្យសេចក្តីព្រាងច្បាប់នេះនៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២២ និងនិយាយថាដំណើរការទាំងស្រុងអាចនឹងមានភាពយឺតយ៉ាវ។[130] នៅខែកញ្ញា ឆ្នាំ២០២២ អ្នកនាំពាក្យក្រសួងព័ត៌មានលើកឡើងពីហេតុផលចំនួនបីដែលធ្វើឱ្យមានការពន្យារការអនុម័តសេចក្តីព្រាងច្បាប់នេះ៖ ភាគីពាក់ព័ន្ធនៅតែផ្តល់ធាតុចូល ភាពចាំបាច់ក្នុងការធ្វើឱ្យប្រាកដថាច្បាប់នេះអនុលោមតាមក្របខ័ណ្ឌច្បាប់ជាតិ និងអន្តរជាតិ និងបញ្ហាប្រឈមដែលបង្កឡើងដោយការរាតត្បាតនៃជំងឺកូវីដ។ លោកក៏បានរំលឹកឡើងវិញនូវការប្តេជ្ញាចិត្តរបស់ក្រសួងព័ត៌មានក្នុងការបញ្ចប់សេចក្តីព្រាងច្បាប់ និងទទួលបានការអនុម័តឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។[131]

នៅចុងខែតុលា ឆ្នាំ២០២២ ក្រសួងព័ត៌មានបានប្រកាសថា សេចក្តីព្រាងច្បាប់ត្រូវបានបញ្ជូនទៅដល់ទីស្តីការគណៈរដ្ឋមន្ត្រីដើម្បីធ្វើការពិនិត្យ ប៉ុន្តែមិនបានផ្តល់ព័ត៌មានអំពីកាលប្បវត្តិ ឬពេលវេលាជាក់លាក់នៃការអនុម័តច្បាប់នេះនោះទេ។[132] នៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០២៣ អតីតនាយករដ្ឋមន្ត្រី ហ៊ុន សែន បាននិយាយថា លោករំពឹងថាច្បាប់នេះនឹងត្រូវបានអនុម័ត "បន្ទាប់ពីការបោះឆ្នោត [ខែកក្កដា ឆ្នាំ២០២៣] ឬប្រហែលជាមុនឆ្នាំ២០២៤ ឬ ឆ្នាំ ២០២៥ ជាក់ជាមិនខាន" និងបានស្តីបន្ទោសផងដែរពីការពន្យារពេលជាបន្តបន្ទាប់លើកិច្ចការដែលត្រូវពិនិត្យទៅលើធាតុចូលដែលស្នើដោយអង្គការសង្គមស៊ីវិល។ ត្រង់ចំណុចនេះ នៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៣ អ្នកនាំពាក្យក្រសួងព័ត៌មានត្រូវបានគេដកស្រង់សម្តីថារដ្ឋាភិបាលនឹងមិនបញ្ចូលមតិរបស់អង្គការសង្គមស៊ីវិលណាដែលមើលឃើញថា "មិនសមរម្យ" ទេ។ លោកបានបន្ថែមថាកង្វល់របស់អង្គការសង្គមស៊ីវិលគឺ "មិនមានអ្វីគួរឱ្យចាប់អារម្មណ៍នោះទេ" ពីព្រោះអង្គការទាំងអស់នោះ "តែងតែមានទស្សនៈអវិជ្ជមានកន្លងមក"។ លោក ឡាំ សុជាតិ នាយកប្រតិបត្តិនៃវិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយបាននិយាយថា ការលើកឡើងរបស់លោក ហ៊ុន សែន គឺដើម្បីផ្គាប់ចិត្តក្រុមអង្គការសង្គមស៊ីវិល និងសាធារណជន មុនការបោះឆ្នោតឆ្នាំ ២០២៣ ចូលមកដល់ ហើយលោកបានមើលឃើញថាការពន្យារពេលក្នុងការអនុម័តសេចក្តីព្រាងច្បាប់ក៏បាន

[129] យួន ណារីម, "នាយករដ្ឋមន្ត្រីអះអាងថា ច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាននឹងត្រូវអនុម័តក្រោយការបោះឆ្នោត"។ (ខេមបូចា, ១៧ មករា ២០២៣); យួន ណារីម, "អង្គការសង្គមស៊ីវិលអំពាវនាវឱ្យអនុម័តច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន"។ (ខេមបូចា, ១៦ មិថុនា ២០២២)។

[130] ខ្មែរថាមស៍, "ការត្រួតពិនិត្យមួយផ្សេងទៀតនៃសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មានត្រូវបានសម្របសម្រួល"។ (ខ្មែរថាមស៍, ៣ កក្កដា ២០២២); ភ្នំពេញប៉ុស្តិ៍, "សេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មានត្រូវបានផ្អាកសម្រាប់ការវាយតម្លៃឡើងវិញ"។ (ភ្នំពេញប៉ុស្តិ៍, ២ កក្កដា ២០២២)។

[131] វ៉ន ដារ៉ា, "ក្រសួងពន្យល់ពីវឌ្ឍនភាពនៃសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន"។ (ភ្នំពេញប៉ុស្តិ៍, ២ កញ្ញា ២០២២)។

[132] យួន ណារីម, "ច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មានដែលទន្ទឹមរង់ចាំយូរមកហើយកំពុងរង់ចាំការយល់ព្រមពីគណៈរដ្ឋមន្ត្រី"។ (ខេមបូចា, ២៨ តុលា ២០២២)។

ឆ្លុះបញ្ចាំងពីកង្វះខាតគណបក្សនយោបាយដែលមានភាពប្រកួតប្រជែងខ្ពស់ ធ្វើការជំរុញឱ្យមានការអនុម័តនៅក្នុងរដ្ឋសភាជាតិ។[133]

[133] អ៊ុំ ប៊ុនធឿន, "នាយករដ្ឋមន្ត្រី៖ ច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មានប្រហែលជាមុនឆ្នាំ ២០២៤-២០២៥ ដោយសារតែតម្រូវការនៃការបញ្ចូលធាតុចូលទាំងអស់"។ (ភ្នំពេញប៉ុស្តិ៍, ១៥ មករា ២០២៣); ឃួន ណារីម, "នាយករដ្ឋមន្ត្រីអះអាងថា ច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាននឹងត្រូវអនុម័តក្រោយការបោះឆ្នោត"។ (ខេមបូចា, ១៧ មករា ២០២៣)។

## V. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

សិទ្ធិសេរីភាពខាងការបញ្ចេញមតិ និងសេរីភាពសារព័ត៌មាន បន្តត្រូវបានគម្រាមកំហែងក្នុងអំឡុងពេលនៃរបាយការណ៍ ដោយមានអ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្សបានក្លាយជាជនរងគ្រោះនៃកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការបិទសំឡេងរិះគន់ និងគ្រប់គ្រងការសរសេររឿងរ៉ាវមុនការបោះឆ្នោតជាសកលនៅខែកក្កដា ឆ្នាំ២០២៣។ ការយាយីតាមប្រព័ន្ធតុលាការ ការវាយប្រហារលើរូបរាងកាយ ការដាក់កំហិតខ្លួនឯង និងការបំភិតបំភ័យ គ្រាន់តែជាការគំរាមកំហែងមួយចំនួន ដែលអ្នកហ៊ានលើកឡើងអំពីបញ្ហារសើប ឬបញ្ចេញមតិរិះគន់រាជរដ្ឋាភិបាលបានជួបប្រទះ។ បើនិយាយពីសិទ្ធិទទួលព័ត៌មាននៅក្នុងប្រទេសកម្ពុជាត្រូវតែមានការកែលម្អនៅក្នុងផ្នែកជាច្រើនដើម្បីសម្រេចឱ្យបាននូវការអនុវត្តសិទ្ធិមួយនេះ។ ខណៈពេលដែលសេចក្តីព្រាងច្បាប់របស់រាជរដ្ឋាភិបាលស្តីពីសិទ្ធិទទួលព័ត៌មានស្ថិតនៅក្នុងជំហានត្រឹមត្រូវមួយឆ្ពោះទៅរកការអនុម័ត យើងឃើញថាមានបញ្ហាមួយចំនួនដែលរារាំងក្នុងការគោរព និងការពារសិទ្ធិនេះបានពេញលេញ ហើយផ្លូវដែលប្រទេសកម្ពុជាត្រូវដើរ គឺនៅវែងឆ្ងាយនៅឡើយមុននឹងសិទ្ធិទទួលព័ត៌មានត្រូវបានធានា។

សិទ្ធិមនុស្សអាចត្រូវបានធានា ហើយលទ្ធិប្រជាធិបតេយ្យអាចរីកចម្រើនទៅបាន លុះត្រាតែប្រជាពលរដ្ឋគ្រប់ៗរូបមានសេរីភាពក្នុងអនុវត្តសិទ្ធិសេរីភាពខាងការបញ្ចេញមតិ ដែលត្រូវទន្ទឹមនឹងការអនុវត្តសិទ្ធិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាន ដែលជាកត្តាដ៏សំខាន់មួយសម្រាប់ការអនុវត្តសិទ្ធិផ្សេងទៀត។ នៅឆ្នាំ១៩៩១ ប្រទេសកម្ពុជាបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ដោយប្តេជ្ញាការពារសិទ្ធិមនុស្ស សេរីភាពមូលដ្ឋាន និងលើកកម្ពស់លទ្ធិប្រជាធិបតេយ្យនៅក្នុងប្រទេសរបស់ខ្លួន។ ៣០ឆ្នាំក្រោយមកការសន្យានេះមិនទាន់ត្រូវបានបំពេញនៅឡើយទេ ហើយប្រជាជនកម្ពុជានៅតែចង់បានសង្គមមួយយុត្តិធម៌ ដែលសិទ្ធិរបស់ខ្លួនរួមបញ្ចូលទាំងសិទ្ធិសេរីភាពខាងការបញ្ចេញមតិ ត្រូវបានធានា។[134] ដូច្នេះហើយ រឿងសំខាន់ដែលរាជរដ្ឋាភិបាលត្រូវដោះស្រាយជាបន្ទាន់ នូវស្ថានភាពធ្លាក់ចុះនៃសេរីភាពខាងការបញ្ចេញមតិនៅប្រទេសកម្ពុជា។ វិធានការជាក់ស្តែង គឺត្រូវការជាចាំបាច់ដើម្បីប្រែក្លាយការប្តេជ្ញាចិត្តទាំងនេះឱ្យក្លាយជាការពិត។

ដូច្នេះ ម.ស.ម.ក សូមជំរុញលើកទឹកចិត្តឱ្យរាជរដ្ឋាភិបាលចាត់វិធានការជាក់ស្តែង ដើម្បីបំពេញកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិរបស់ខ្លួន និងសូមផ្តល់នូវអនុសាសន៍ដូចខាងក្រោម៖

| | |
|---|---|
| ១ | លុបចោលអនុក្រឹត្យស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ ឱ្យស្របតាមកាតព្វកិច្ចរបស់កម្ពុជាដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់សិទ្ធិមនុស្សអន្តរជាតិ ដើម្បីធានាថាសេរីភាពខាងការបញ្ចេញមតិ និងសិទ្ធិទទួលព័ត៌មានរបស់បុគ្គលគ្រប់រូបត្រូវបានការពារនៅក្នុងប្រទេសកម្ពុជា។ |
| ២ | ពិនិត្យមើលច្បាប់ដែលធ្វើឱ្យប៉ះពាល់សេរីភាពខាងការបញ្ចេញមតិទាំងអស់ ដើម្បីកែសម្រួលឱ្យស្របតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ ដូចជាច្បាប់ស្តីពីរបបសារព័ត៌មាន ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពី |

134 ម.ស.ម.ក, "កំណត់ត្រាសង្ខេប៖ ការបំពេញកាតព្វកិច្ចរបស់កម្ពុជាចំពោះកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសក្នុងរយៈពេល៣០ឆ្នាំក្រោយមក"។ (ម.ស.ម.ក, តុលា ២០២១)។

| | |
|---|---|
| | ការបោះឆ្នោត និងបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌស្តីពីការប្រមាថចំពោះអង្គព្រះមហាក្សត្រ ការញុះញង់ និងបរិហារកេរ្តិ៍។ |
| ៣ | បញ្ចូលធាតុចូលពីភាគីពាក់ព័ន្ធ និងអង្គការសង្គមស៊ីវិលទៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានដើម្បីធានាថាសេចក្តីព្រាងច្បាប់ចុងក្រោយស្របតាមស្តង់ដារសិទ្ធិមនុស្សអន្តរជាតិ និងអនុម័តឱ្យទាន់ពេលវេលា។ |
| ៤ | ផ្តល់អាជ្ញាបណ្ណសារព័ត៌មានក្នុងរយៈពេលឆាប់បំផុតទៅឱ្យអង្គភាពសារព័ត៌មានចំនួន៥ឡើងវិញបន្ទាប់ពីត្រូវបានដកហូតក្នុងអំឡុងពេលនៃរបាយការណ៍នេះ។ |
| ៥ | បញ្ឈប់រាល់ការយាយីតាមប្រព័ន្ធតុលាការលើអ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្ស ដោយសារការអនុវត្តសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន និងធានានូវបរិយាកាសអំណោយផលដែលអាចឱ្យពួកគេធ្វើការស្របច្បាប់ដោយសេរី ដោយគ្មានការភ័យខ្លាច ឬឧបសគ្គ ការរារាំង ឬការយាយីតាមប្រព័ន្ធតុលាការ និងការយាយីតាមរូបភាពផ្សេងៗទៀត។ |
| ៦ | ដោះលែងជាបន្ទាន់នូវអ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្សទាំងអស់ដែលកំពុងជាប់ពន្ធនាគារដោយសារតែការអនុវត្តសេរីភាពខាងការបញ្ចេញមតិ និងទម្លាក់ការចោទប្រកាន់ទៅលើពួកគេ។ |
| ៧ | ត្រូវធានាថា ការវាយប្រហារ និងបទល្មើសដែលប្រព្រឹត្តទៅលើអ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្សត្រូវបានស៊ើបអង្កេតយ៉ាងច្បាស់លាស់ ហ្មត់ចត់ និងឯករាជ្យ ហើយជនល្មើសត្រូវបាននាំយកទៅកាត់ទោសដើម្បីបញ្ឈប់និទណ្ឌភាពចំពោះឧក្រិដ្ឋកម្មដែលប្រព្រឹត្តលើអ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្ស ហើយឱ្យពួកគេធ្វើការដោយសុវត្ថិភាព។ |
| ៨ | ត្រូវបញ្ឈប់ការគំរាមកំហែង និងការបំភិតបំភ័យអ្នកសារព័ត៌មានដែលរាយការណ៍អំពីបញ្ហាទាំងឡាយដែលមានលក្ខណៈរសើប ដូចជារឿងនយោបាយ ជម្លោះដីធ្លី ឬអំពើពុករលួយជាដើម ដើម្បីធានាថាអ្នកសារព័ត៌មានអាចបំពេញតួនាទីដ៏សំខាន់របស់ខ្លួនក្នុងការរាយការណ៍ដល់សាធារណជនលើបញ្ហាទាំងឡាយណាដែលពាក់ព័ន្ធនឹងផលប្រយោជន៍សាធារណៈ ដោយមិនគិតពីរបៀបដែលរាជរដ្ឋាភិបាលយល់ឃើញបែបណានោះឡើយ។ |
| ៩ | លើកទឹកចិត្តប្រព័ន្ធផ្សព្វផ្សាយពហុនិយម និងចម្រុះបែប ដោយអនុញ្ញាតឱ្យប្រព័ន្ធផ្សព្វផ្សាយឯករាជ្យអាចស៊ើបអង្កេត និងរាយការណ៍រាល់បញ្ហាដែលមានសារៈសំខាន់សម្រាប់សាធារណជនដោយគ្មានការខ្លាចពីការតបតពីរដ្ឋាភិបាល បង្កើតបានជាទិដ្ឋភាពប្រព័ន្ធផ្សព្វផ្សាយបើកចំហមួយដែលអនុញ្ញាតឱ្យធ្វើការផ្សព្វផ្សាយ និងស្វែងរកបានដោយសេរី និងជាសាធារណៈនូវទស្សនៈ និងគំនិតចម្រុះបែប។ |
| ១០ | លុបចោលលក្ខខណ្ឌដែលតម្រូវឱ្យអង្គភាពសារព័ត៌មានត្រូវតែមានអាជ្ញាបណ្ណពីក្រសួងព័ត៌មាន មុននឹងអាចបោះពុម្ពផ្សាយ និងបង្កើតនូវស្ថាប័នគ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយឯករាជ្យដាច់ដោយឡែកមួយពីរាជរដ្ឋាភិបាល ដើម្បីធានាថាបទប្បញ្ញត្តិពាក់ព័ន្ធនឹងប្រព័ន្ធផ្សព្វផ្សាយត្រូវបានធ្វើឡើងដោយគោរពសេរីភាពសារព័ត៌មាន និងមិនលម្អៀងទាំងអស់។ |

| | |
|---|---|
| ១១ | ត្រូវធានាថាគ្រប់នាយកដ្ឋានរបស់រដ្ឋាភិបាល ស្ថាប័នសាធារណៈ និងស្ថាប័នឯកជនដែលមានមុខងារសាធារណៈទាំងអស់ប្រកាន់ខ្ជាប់នូវគោលការណ៍នៃការបង្ហាញព័ត៌មានជាអតិបរមា និងយល់ព្រមរាល់សំណើសុំឱ្យបង្ហាញព័ត៌មាន ជាពិសេសសំណើពីអ្នកសារព័ត៌មានស្នើសុំទិន្នន័យដែលគ្រប់គ្រងដោយរដ្ឋាភិបាល ដើម្បីឱ្យព័ត៌មានមានសារៈសំខាន់ចំពោះផលប្រយោជន៍សាធារណៈអាចផ្សព្វផ្សាយបានដោយសេរីនៅក្នុងប្រទេស និងបង្កើនតម្លាភាព និងគណនេយ្យភាពចំពោះសកម្មភាពរាជរដ្ឋាភិបាល។ |
| ១២ | ត្រូវចាត់វិធានការណ៍ជាបន្ទាន់ឱ្យបានពេញលេញ ដើម្បីលុបបំបាត់រាល់អាកប្បកិរិយារើសអើងចំពោះអ្នកសារព័ត៌មានជាស្ត្រី និងអ្នកការពារសិទ្ធិមនុស្សជាស្ត្រី តាមរយៈវគ្គបណ្តុះបណ្តាលស្តីពីការយល់ដឹងផ្នែកយេនឌ័រ និងយុទ្ធនាការអប់រំផ្សេងៗ ដើម្បីអាចអនុវត្តសេរីភាពខាងការបញ្ចេញមតិ និងធ្វើការងារស្របច្បាប់របស់ពួកគេដោយគ្មានការរើសអើង។ |

## VI. ឧបសម្ព័ន្ធ

### កម្រងសំណួរសម្រាប់សម្ភាសន៍

**កម្រងសំណួរសម្រាប់អ្នកសារព័ត៌មាន**

១. តើអ្នកគិតថាអ្វីជាការគម្រាមកំហែងធំបំផុតទៅលើសេរីភាពសារព័ត៌មាន និងការទទួលព័ត៌មាននៅប្រទេសកម្ពុជានាពេលសព្វថ្ងៃនេះ?

២. តើអ្នកធ្លាប់ទទួលរងនូវការរឹតត្បឹត/រំលោភបំពានលើសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិក្នុងនាមជាអ្នកសារព័ត៌មានពីសំណាក់រាជរដ្ឋាភិបាល ឬភាគីទីបីដែរឬទេ? បើអ្នកធ្លាប់ តើអ្នកបានដាក់ពាក្យបណ្តឹងដែរឬទេ? បើបានដាក់ពាក្យបណ្តឹង តើអ្នកទទួលការឆ្លើយតបចំពោះពាក្យបណ្តឹងនោះដែរឬទេ?

៣. តើអ្នកមានអារម្មណ៍ថាអ្នកអាចធ្វើការដោយសេរី និងគ្មានការភ័យខ្លាចពីការគាបសង្កត់ដែរ ឬទេ?

៤. តើអ្នកបានធ្វើអ្វីខ្លះដើម្បីសម្របខ្លួនទៅនឹងបរិយាកាសដែលមានគ្រោះថ្នាក់កាន់តែធ្ងន់ធ្ងរឡើងៗ សម្រាប់អ្នកសារព័ត៌មាន?

៥. តើអ្នកមានការលំបាកក្នុងការទទួលព័ត៌មានសម្រាប់ការសរសេរអត្ថបទរបស់អ្នកដែរ ឬទេ? បើមាន តើអ្នកអាចផ្តល់ឧទាហរណ៍ខ្លះបានដែរ ឬទេ?

៦. តើមានប្រធានបទណាខ្លះដែលអ្នកមិនព្រមយកមកសរសេរដែរឬទេ? បើមាន ហេតុអ្វី?

៧. តើអ្នកធ្លាប់ជួបនូវផលលំបាកនៅពេលដែលអ្នកអនុវត្តសេរីភាពក្នុងការបញ្ចេញមតិក្នុងនាមជាអ្នកសារព័ត៌មានដោយសារយេនឌ័ររបស់អ្នកដែរឬទេ? (សម្រាប់សម្ភាសជាមួយស្ត្រី)។

**កម្រងសំណួរសម្រាប់អ្នកការពារសិទ្ធិមនុស្ស៖**

១. តើអ្នកគិតថាអ្វីជាការគម្រាមកំហែងធំបំផុតទៅលើសេរីភាពខាងការបញ្ចេញមតិ នៅប្រទេសកម្ពុជានាពេលសព្វថ្ងៃនេះ?

២. តើអ្នកធ្លាប់ទទួលរងនូវការរឹតត្បឹត/រំលោភបំពានលើសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិក្នុងនាមជាអ្នកការពារសិទ្ធិមនុស្ស ពីសំណាក់រាជរដ្ឋាភិបាល ឬភាគីទីបីដែរឬទេ? បើអ្នកធ្លាប់ តើអ្នកបានដាក់ពាក្យបណ្តឹងដែរឬទេ? បើបានដាក់ពាក្យបណ្តឹង តើអ្នកទទួលការឆ្លើយតបចំពោះពាក្យបណ្តឹងនោះដែរឬទេ?

៣. តើអ្នកមានអារម្មណ៍ថាអ្នកអាចធ្វើការដោយសេរី និងគ្មានការភ័យខ្លាចពីការគាបសង្កត់ដែរ ឬទេ?

៤.តើអ្នកបានធ្វើអ្វីខ្លះដើម្បីសម្របខ្លួនទៅនឹងបរិយាកាសដែលមានគ្រោះថ្នាក់កាន់តែធ្ងន់ធ្ងរឡើងៗ សម្រាប់អ្នកការពារសិទ្ធិមនុស្ស?

៥. តើបញ្ហាសិទ្ធិមនុស្សណាខ្លះដែលអ្នកមិនព្រមធ្វើការតស៊ូមតិដែរឬទេ? បើមាន ហេតុអ្វី?

៦. តើអ្នកធ្លាប់ជួបនូវផលលំបាកនៅពេលដែលអ្នកអនុវត្តសេរីភាពក្នុងការបញ្ចេញមតិក្នុងនាមជាអ្នកអ្នកការពារសិទ្ធិមនុស្ស ដោយសារយេនឌ័ររបស់អ្នកដែរឬទេ? (សម្រាប់សម្ភាសជាមួយស្ត្រី)។